ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

ប្រវត្តិវិទ្យា

សំណួរ និង ចម្លើយ

ពីឆ្នាំ ២០១៤ ដល់ ២០២២

ត្រៀមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

រៀបរៀងដោយ ម៉ែត ជីវិន

អារម្ភកថា

សួស្តី លោកគ្រូ អ្នកគ្រូ ប្អូនៗសិស្សានុសិស្ស និងប្រិយមិត្តអ្នកអានទាំងអស់គ្នាជាទីស្រឡាញ់!

សៀវភៅ ប្រវត្តិវិទ្យា សំណួរ និង ចម្លើយ ពីឆ្នាំ ២០១៤ ដល់ ២០២២ ដែលលោកគ្រូ អ្នកគ្រូ ប្អូនៗ សិស្សានុសិស្ស និងប្រិយមិត្តកំពុងកាន់អាននេះ ខ្ញុំបាទបានចងក្រងជាពិសេសសម្រាប់សិស្សប្អូន ថ្នាក់ទី១២ ដើម្បីត្រៀមខ្លួនប្រឡងសញ្ញាបត្រទុតិយភូមិ ទទួលបាននិទ្ទេសA លើមុខវិជ្ជាប្រវត្តិវិទ្យា នេះ និងក្នុងគោលបំណងទុកជាឯកសារ សិក្សាស្វែងយល់ពីគំរូវិញ្ញាសាចាស់ៗ និងជំណោះស្រាយ ដើម្បីជាមូលដ្ឋានក្នុងការសិក្សាអំពី កម្រិតវិញ្ញាសាស្តង់ដា ឬវិញ្ញាសាស្តង់ដាធ្លាប់ចេញប្រឡងរួច ហើយ ដើម្បីមានភាពងាយស្រួលក្នុងការកំណត់ផ្នែកសំខាន់ៗ ក្នុងមេរៀនដែលត្រូវរៀនដោយយកចិត្តទុកដាក់ និង សិក្សាស៊ីជម្រៅ ។

ខ្ញុំបាទសូមអធ្យាស្រ័យ ចំពោះកំហុសអចេតនាដែលមាននៅក្នុងសៀវភៅមួយនេះ ខ្ញុំបាទនឹងរងចាំទទួលមតិស្ថាបនាកែលំអរបន្ថែម ពីសំណាក់លោកគ្រូ អ្នកគ្រូ សិស្ស និស្សិត និងអ្នកសិក្សាគ្រប់មជ្ឈដ្ឋានទាំងអស់ដោយក្តីគោរព ។

រៀបរៀងដោយ

ម៉ែត ជីវិន

Telegram : 093 900 369

(សូមជូនពរសំណាងល្អក្នុងការប្រឡង)

មាតិកា

មេរៀនទី១ ប្រទេសកម្ពុជាក្រោមអាណាព្យាបាលបារាំង (១៨៦៣-១៩៥៣)-------ទំព័រទី០១

មេរៀនទី២ របបសង្គមរាស្ត្រនិយម (១៩៥៣-១៩៧០)----------ទំព័រទី០៥

មេរៀនទី៣ របបសាធារណរដ្ឋខ្មែរ (១៩៧០-១៩៧៥)----------ទំព័រទី១១

មេរៀនទី៤ កម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)----------ទំព័រទី១៨

មេរៀនទី៥ សាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា (១៩៧៩-១៩៩៣)------ទំព័រទី២៣

មេរៀនទី៦ ព្រះរាជាណាចក្រកម្ពុជាទី២ (១៩៩៣-បច្ចុប្បន្ន)----------ទំព័រទី៣០

ប្រវត្តិសាស្ត្រកម្ពុជា----------ទំព័រទី៤៣

ប្រវត្តិសាស្ត្រតំបន់ និងពិភពលោក----------ទំព័រទី៤៧

វិញ្ញាសាទី១----------ទំព័រទី៥៦

វិញ្ញាសាទី២----------ទំព័រទី៦០

វិញ្ញាសាទី៣----------ទំព័រទី៦៣

វិញ្ញាសាទី៤----------ទំព័រទី៦៧

វិញ្ញាសាទី៥----------ទំព័រទី៧១

សំណូរ និង ចម្លើយជ្រើសរើស----------ទំព័រទី៧៥

🕮 មេរៀនទី១ ប្រទេសកម្ពុជាក្រោមអាណាព្យាបាលបារាំង (១៨៦៣-១៩៥៣)

(ដកស្រង់ចេញពីការបង្រៀនក្នុងផេកក្រសួងអប់រំ)

✍ចងក្រងឡើងដោយ ម៉ែត ជីវិន✍

✦✦✦ ✦✦ ⊙ ✦✦✦✦✦

﴿ប្រធានសំណួរ﴾

១. (២០១៥) តើប្រទេសកម្ពុជាទទួលបានឯករាជ្យពេញលេញនៅឆ្នាំណា?

២.(២០១៥) តើការទទួលបានឯករាជ្យនេះ មានអត្ថន័យដូចម្តេចខ្លះចំពោះកម្ពុជា?

៣.(២០១៥) ចូរពណ៌នាពីមូលហេតុដែលកម្ពុជាទទួលយកអាណានិគមនិយមបារាំង?

៤.(២០១៦) តើអាណាព្យាបាលបារាំងពីឆ្នាំ ១៨៦៣ ដល់ឆ្នាំ ១៩៥៣ មានចំណុចវិជ្ជមាន អវិជ្ជមានអ្វីខ្លះសម្រាប់ប្រទេសកម្ពុជា?

៥.(២០១៧) តើស្តេចខ្មែរអង្គណាដែលទាមទារបានសម្រេចឯករាជ្យពីបារាំង?

៦.(២០១៧) ហេតុអ្វីបានជាកម្ពុជាចាំបាច់ស្វែងរកកិច្ចការពារពីបារាំងដោយចុះសន្ធិសញ្ញាអាណាព្យាបាលជាមួយបារាំង?

៧.(២០១៨) អាណាព្យាបាលបារាំងនាំមកអ្វីខ្លះដល់កម្ពុជា?

៨.(២០១៨) ចូរអត្ថាធិប្បាយពីចំណុចវិជ្ជមាន និងអវិជ្ជមាននៃរបបអាណាព្យាបាលបារាំង?

៩.(២០២១) តើវត្តមានអាណាព្យាបាលបារាំងបាននាំមកនូវផលវិជ្ជមាន និងផលអវិជ្ជមានអ្វីខ្លះចំពោះកម្ពុជា?

១០.(២០២២)តើអាណានិគមនិយមបារាំងបាននាំអ្វីខ្លះ ដល់កម្ពុជា ?

---------- អត្ថាកំណែ ----------

១. ប្រទេសកម្ពុជាទទួលបានឯករាជ្យពេញលេញនៅឆ្នាំ១៩៥៣ (ថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣) ។

២.ឯករាជ្យឆ្នាំ១៩៥៣ មានអត្ថន័យជាប្រវត្តិសាស្ត្រចំពោះកម្ពុជាដូចជា ៖

- ជាថ្ងៃដែលប្រជាជនកម្ពុជារួចផុតពីការគាបសង្កត់ ការបង្ខំឲ្យបង់ពន្ធយ៉ាងធ្ងន់ធ្ងរសព្វសារពើពីសំណាក់បារាំង។
- ប្រជាជនមានសិទ្ធិសេរីភាព នឹងមានសិទ្ធិក្នុងការសម្រេចជោគវាសនាប្រទេសជាតិដោយខ្លួនឯង។
- ប្រជាជនកម្ពុជារក្សាបានវប្បធម៌ ទំនៀមទម្លាប់ ជំនឿ សាសនា របស់ជាតិខ្លួន។

- ប្រទេសកម្ពុជារួចផុតពីអាណាព្យាបាលបារាំង ។
- ប្រទេសកម្ពុជាទទួលបានឯករាជ្យ អធិបតេយ្យភាព នឹងបូរណភាពទឹកដី ។
- កម្ពុជាបានដឹកនាំអភិវឌ្ឍជាតិខ្លួនស្របតាមឆន្ទៈនឹងគោលបំណងរបស់ប្រជាជន ។
- កម្ពុជាបានឈរស្មើមុខស្មើមាត់លើឆាកអន្តរជាតិ ។

៣.មូលហេតុដែលកម្ពុជាទទួលយកអាណានិគមនិយមបារាំងមានដូចជា ៖

❖ នយោបាយ

- សៀម-យួន គាបសង្កត់ នឹងឈ្លានពានកម្ពុជា
- ខ្មែរយកមហាអំណាចអឺរ៉ុបដើម្បីជាបង្អែកការពារប្រទេស
- ធ្វើឲ្យមានឯកភាពអំណាចរាជបល្ល័ង្ក

❖ សេដ្ឋកិច្ច

- សេដ្ឋកិច្ចខ្មែរធ្លាក់ចុះ ដោយសារការគាបសង្កត់ពីសំណាក់សៀម-យួន
- បារាំងបើកប្រាក់បៀវត្ស ឲ្យមន្ត្រីរាជការ នឹងរាជវង្ស ព្រះមហាក្សត្រខ្ពស់
- បារាំងជាអ្នកពាណិជ្ជកម្មក្នុង នឹងក្រៅប្រទេសព្រមទាំងជាអ្នកកាន់កាប់ពន្ធដារ

❖ សង្គម

- រៀបចំប្រព័ន្ធតុលាការថ្នាក់ឃុំ ដល់ខេត្តក្រុង
- រៀបចំប្រព័ន្ធរដ្ឋបាល ថ្នាក់មូលដ្ឋានខេត្ត ក្រុង
- សង្គមខ្មែរមានអស្ថិរភាព

(សិស្សអាចមាន មតិពាក់ព័ន្ធនឹង៖ វប្បធម៌ អក្សរសាស្ត្រខ្មែរ ការអប់រំ...)

៤.៧.៨.៩.១០ (មានចម្លើយដូចគ្នា)

៤. អាណាព្យាបាលបារាំងពីឆ្នាំ ១៨៦៣ ដល់ឆ្នាំ ១៩៥៣ មានចំណុចវិជ្ជមាន អវិជ្ជមាន សម្រាប់ប្រទេសកម្ពុជាដូចខាងក្រោម ៖

៧. អាណាព្យាបាលបារាំងនាំមកនូវផលវិជ្ជមាន និងអវិជ្ជមានដល់កម្ពុជាដូចជា ៖

៨. អត្ថាធិប្បាយពីចំណុចវិជ្ជាមាន និងអវិជ្ជមាននៃរបបអាណាព្យាបាលបារាំង ៖

៩. វត្តមានអាណាព្យាបាលបារាំងបាននាំមកនូវផលវិជ្ជមាន និងផលអវិជ្ជមានចំពោះកម្ពុជា៖

១០.អាណានិគមនិយមបារាំងបាននាំនូវផលវិជ្ជមាន និងអវិជ្ជមានដល់កម្ពុជាដូចជា ៖

❖ ចំណុចវិជ្ជមាន

- បារាំងបានជួយការពារទឹកដី ពូជសាសន៍ខ្មែរឲ្យបានគង់វង្ស
- បារាំងបានជួយកំណែទម្រង់រដ្ឋបាល ប្រព័ន្ធសេដ្ឋកិច្ច អប់រំសិក្សាធិការ រៀបចំសង្គមខ្មែរ ឲ្យមានរបៀបរៀបរយ មានសណ្តាប់ធ្នាប់បានរីកចម្រើនល្អប្រសើរជាងមុន
- បារាំងបានជួយសាងសង់ផ្លូវថ្នល់ ស្ពាន មន្ទីរពេទ្យ សារមន្ទីជាតិ ហេដ្ឋារចនាសម្ព័ន្ធ សាលារៀន បណ្តុះបណ្តាលធនធានមនុស្ស
- តាមរយៈសាលចុងបូព៌ាប្រទេស បារាំងបានសិក្សាស្រាវជ្រាវ ចងក្រងជួសជុលប្រាង្គ ប្រាសាទ អភិរក្សវប្បធម៌ អរិយធម៌ខ្មែរ ព្រមទាំងបានផ្សព្វផ្សាយទៅលើឆាកអន្តរជាតិធ្វើ ឲ្យ ពិភពលោកស្គាល់ប្រទេសកម្ពុជា
- ក្នុងនាមអាណាព្យាបាលខ្មែរបារាំងបានយកទឹកដីពីសៀមឈ្លានពានមកឲ្យខ្មែរវិញដូចជា
  - ថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ១៩០៤ យកខេត្តត្រាត កោះកុង ម្លូព្រៃ ទន្លេពៅ និងស្ទឹងត្រែង
  - ថ្ងៃទី ២៣ ខែមីនា ឆ្នាំ១៩០៧ យកខេត្តសៀមរាប បាត់ដំបង សិរីសោភណ្ឌ
  - ឆ្នាំ ១៩០៨ បារាំងបានគូសផែនទីឈ្មោះ « ដងរែក » ទុកជាប្រយោជន៍ដល់កម្ពុជា។ ផែនទីនេះនាំឲ្យខ្មែរឈ្នះក្តីក្នុងរឿងក្តីក្តាំប្រាសាទព្រះវិហារ។

❖ ចំណុចអវិជ្ជមាន

- បារាំងបានធ្វើឲ្យប្រជាជនកម្ពុជាកាន់តែក្រីក្រដោយសារតែការដិះដាន់កេងប្រវ័ញ្ច ប្រមូលពន្ធដារយ៉ាងធ្ងន់ធ្ងរសព្វសារពើ
- បារាំងបានធ្វើឲ្យមានគម្លាតគ្នារវាងអ្នកទីក្រុង និងអ្នកជនបទ អ្នកមាន និងអ្នកក្រ បង្កើតទំនាស់វណ្ណៈក្នុងសង្គមខ្មែរយ៉ាងធ្ងន់ធ្ងរ
- បារាំងបានកេណ្ឌប្រជាពលរដ្ឋខ្មែរឲ្យទៅច្បាំងស្លាប់ ក្នុងសមរភូមិសង្គ្រាមលោកលើកទី១ និងសង្គ្រាមលោកលើកទី២
- បារាំងបានប្រមូលយកវត្ថុកេតនកណ្ឌខ្មែរទៅប្រទេសបារាំង
- បារាំងបានកាត់ដីខ្មែរឲ្យប្រទេសជិតខាងស្រេចតែចិត្តដោយពុំសួរយោបល់ខ្មែរដូចជា៖
  - ថ្ងៃទី ២៣ ខែមីនា ឆ្នាំ១៩០៧ កាត់ខេត្តត្រាតឲ្យទៅសៀម
  - ថ្ងៃទី ៣១ ខែមករា ឆ្នាំ១៩៣៩ កាត់បញ្ជូល កោះត្រល់ ដាក់ចូលក្នុងដែនរដ្ឋបាលកូសាំងស៊ីន
  - ថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ១៩៤៩ កាត់កម្ពុជាក្រោម (កូសាំងស៊ីន) ឲ្យទៅអំណាច

ស្តេចបារដោយវៀតណាម។

៥. ស្តេចខ្មែរដែលទាមទារឯករាជ្យពីបារាំងបានសម្រេចគឺ ព្រះបាទ នរោត្តម សីហនុ។

៦. បានជាកម្ពុជាចាំបាច់ស្វែងរកកិច្ចការពារពីបារាំងដោយចុះសន្ធិសញ្ញាអាណាព្យាបាលជាមួយបារាំងព្រោះ ៖

- ប្រទេសកម្ពុជាកាន់តែទន់ខ្សោយ ហើយទឹកដីខ្មែរកាន់តែរួមតូចទៅៗនឹងមានវិបត្តិផ្ទៃក្នុង
- ប្រទេសសៀមនឹងយួន(អាណ្ណាម)នៅតែប៉ុនប៉ងរំលាយជាតិសាសន៍ខ្មែរ ឈ្លានពានទឹកដីខ្មែរ ដោយយកទន្លេមេគង្គធ្វើជាព្រំប្រទល់នៃប្រទេសទាំងពីរ
- ចង់បានមហាអំណាចអឺរ៉ុបណាមួយ(បារាំង)មកជួយការពារទឹកដី ពូជសាសន៍ខ្មែរ
- ដោយមានការណែនាំពីបុព្វជិតសាសនាកាតូលិកនាម មីស (MICHE) ធ្វើឲ្យព្រះបាទអង្គដួងពឹង បារាំង ។

(មានចម្លើយត្រឹមត្រូវផ្សេងៗទៀត)

ទស្សនៈ លោកគា គង្គ ប៊ុនឈឿន

- ក្នុងមួយជីវិតឥតប្រាថ្នាអ្វី ក្រៅពីសេរីដើម្បីសរសេរ
  បើនិពន្ធតាមបញ្ជាគេ ដូចយកម្ជុលដេរបិទមាត់ខ្លួនឯង ។
- តម្លៃទឹកខ្មៅនៅត្រង់សច្ចៈ ទោះគុកច្រវាក់មិនញញើតក្រែង
  បើឃើញភ្លើងហើយបែរថាផ្សែង គឺក្បត់ខ្លួនឯងមុនក្បត់អ្នកអាន ។
- សុខចិត្តក្រីក្រមិនទ្រុឌទ្រុស មិនលក់អក្ខរាដូរវីឡាឡាន
  មិនលួនអោនក្បាលធ្វើមុំចង្រ្កាន ទោះជាចាកឋានខានឃើញអង្គរ ។
- បើទ្រាំនៅស្រុកចុកមាត់បិទក្នែក ព្រមធ្វើជាសេកចាំតែបន្ទរ
  ឬធ្វើអន្លង់ចាំតែទូងស្គរ មុខជាលើផ្នូរក្មេងលួចខាកស្តោះ ។

និពន្ធដោយ គង់ ប៊ុនឈឿន (កវីស្នឹងសង្កែ)

🕮 មេរៀនទី២ របបសង្គមរាស្ត្រនិយម (១៩៥៣ - ១៩៧០)

(ដកស្រង់ចេញពីការបង្រៀនក្នុងផេកក្រសួងអប់រំ)

✍ចងក្រងឡើងដោយ ម៉ែត ជីវិន✍

✦✦✦ ✦✦ ⊙ ✦✦✦✦✦

《ប្រធានសំណួរ》

១. (២០១៦) ចូរពណ៌នាពីសមិទ្ធផលសង្គមរាស្ត្រនិយមពីឆ្នាំ១៩៥៣ដល់១៩៧០ ។

២.(២០១៧) ចូរពណ៌នាពីនយោបាយអព្យាក្រឹត នៅក្នុងរបបសង្គមរាស្ត្រនិយម (១៩៥៣-១៩៧០) ។

៣.(២០១៨) ចូរពណ៌នាពីសម័យសង្គមរាស្ត្រនិយម (១៩៥៥-១៩៧០) ។

៤.(២០១៩) ចូរពណ៌នាពីចលនាតស៊ូទាមទារឯករាជ្យពីបារាំងនៅកម្ពុជា ។

៥.(២០១៩) អ្វីទៅជាគោលនយោបាយអព្យាក្រឹត? ចូរអ្នកពណ៌នា ។

អត្ថាធិប្បាយ

---

១. ពណ៌នាពីសមិទ្ធផល នៃរបបសង្គមរាស្ត្រនិយម ៖

❖ វិស័យនយោបាយ

- ប្រារព្ធសមាជជាតិ ធ្វើឲ្យមានការអភិវឌ្ឍជាតិលើគ្រប់វិស័យស្របតាមឆន្ទៈប្រជាជន
- ការអនុវត្តនយោបាយអព្យាក្រឹត បានធ្វើឲ្យប្រទេសជាតិមានសុខសន្តិភាពរយៈពេល ១៥ឆ្នាំ (១៩៥៥-១៩៧០) ស្របពេលដែលប្រទេសជិតខាងជួបនឹងសង្គ្រាម
- កម្ពុជាបានចូលជាសមាជិកអង្គការសហប្រជាជាតិ (១៤ ធ្នូ ១៩៥៥)
- កម្ពុជាឈ្នះក្តី ក្នុងរឿងក្តីក្តាំងប្រាសាទព្រះវិហារ (១៥ មិថុនា ១៩៦២)

❖ វិស័យសេដ្ឋកិច្ច

- កសិកម្ម ៖ ការអនុវត្តនយោបាយទឹក បានបង្កើតប្រព័ន្ធធារាសាស្ត្រខ្នាត់ខ្នែង ការពង្រីកដីដាំ ដុះធ្វើឲ្យមានកំណើនទិន្នផល
- ឧស្សាហកម្ម ៖ កំណើនរោងចក្រឧស្សាហកម្មជាច្រើនដូចជា រោងចក្រក្រដាសវាយនកណ្តា ក្តារបន្ទះ ស៊ីម៉ង់ដ៍ ស្រាបៀរ តម្លើងត្រាក់ទ័រ បារក្រចៅ...
- ពាណិជ្ជកម្ម ៖ នាំចេញនូវផលិតផលកសិកម្ម ដូចជា ស្រូវ អង្ករ ម្រេច កប្បាស បារក្រចៅ

- ធនាគារ-ហិរញ្ញវត្ថុ ៖ លេចឡើងនៅធនាគារឯកជនជាច្រើន នឹងប្រាក់រៀលក្លាយជារូបិយវត្ថុ ជាតិប្រើប្រាស់ជាផ្លូវការ
- វិស័យសមាគម៖ សាងសង់ផ្លូវជាតិ ផ្លូវដែក ស្ពាន កំពង់ផែ អាកាសយានដ្ឋាន...

❖ វិស័យអប់រំ វប្បធម៌

- អប់រំសិក្សាធិការ ៖ បង្កើតសាលារៀនពីទីក្រុងរហូតដល់ជនបទ ពីមតេយ្យដល់ឧត្តមសិក្សា មានកំណើនធនធានមនុស្ស
- ផ្នែកកីឡា ៖ បង្កើតពហុកីឡដ្ឋានជាតិ ពហុកីឡដ្ឋានតាមខេត្ត ស្រុក សាលារៀន នឹងកន្លែង សម្រាប់កីឡាករហ្វឹកហាត់ស្នាក់នៅ
- សាសនា ៖ បង្កើតវត្តអារាមជាច្រើន នឹងពុទ្ធិកបឋមសិក្សា ដល់មធ្យមសិក្សា
- សិល្បៈ ៖ បង្កើតសាលាសិល្បៈ រោងមហាស្រព នៅតាមទីរួមខេត្ត នឹងធ្វើការជួសជុលប្រាង្គ ប្រាសាទបុរាណ អភិរក្សសម្បត្តិវប្បធម៌

❖ វិស័យសង្គម

- សុខភាពជាបញ្ហាចម្បង ដូចនេះរាជរដ្ឋាភិបាលបានបង្កើតមន្ទីរពេទ្យជាច្រើន ព្រមទាំងចាត់វិធានការចាក់ថ្នាំការពារ នឹងអនាម័យលំនៅដ្ឋាន
- បង្កើតច្បាប់រក្សាសន្តិសុខ សណ្តាប់ធ្នាប់សង្គម
- បង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ និងមជ្ឈមណ្ឌលអប់រំស្ត្រីពេស្យា
- ផ្តល់សិទ្ធិឲ្យស្ត្រីក្នុងការបោះឆ្នោត និងឈរឈ្មោះបោះឆ្នោត (៦ មករា ១៩៥៨)

២.៥. នយោបាយអព្យាក្រឹត នៅក្នុងរបបសង្គមរាស្ត្រនិយម ៖

➢ នយោបាយអព្យាក្រឹត

❖ នយោបាយអព្យាក្រឹត គឺជាការរួមរស់ដោយសន្តិសហវិជ្ជាមានជាមួយបណ្តាលប្រទេសនានា លើពិភពលោក ដោយនៅកណ្តាលមិនប្រកាន់មនោគមវិជ្ជាសេរី មនោគមវិជ្ជាកុម្មុយនីស្ត ។

❖ មូលហេតុនៃការអនុវត្តនយោបាយអព្យាក្រឹត

- អនុវត្តទៅតាមសេចក្តីសម្រេចនៃសន្និសីទក្រុងហ្សឺណែវឆ្នាំ ១៩៥៤ ដែលស្នើដោយចិន នឹងសូវៀត
- កម្ពុជាចង់រួមរស់ដោយសន្តិសហវិជ្ជមានជាមួយបណ្តាប្រទេសនានាលើពិភពលោក

ពិសេសជាមួយប្រទេសជិតខាង។

❖ ការពង្រឹងនយោបាយអព្យាក្រឹត

- ថ្ងៃទី ១៨ ខែមីនា ឆ្នាំ១៩៥៥ ក្នុងដំណើរទស្សនកិច្ចនៅឥណ្ឌា សម្តេច នរោត្តម សីហនុ បានចុះហត្ថលេខាជាមួយលោក នេរូ លើសេចក្តីប្រកាសរួមគឺជាការរួមរស់ជាមួយគ្នា ដោយសន្តិភាព
- ថ្ងៃទី ១៨-២៤ ខែមេសា ឆ្នាំ១៩៥៥ ក្នុងសន្និសីទទំកំពូលនៃទ្វីបអាស៊ី-អាហ្វ្រិកនៅក្រុង បានឌុង សម្តេច នរោត្តម សីហនុ បានធ្វើសេចក្តីអះអាងពីកម្មវិធីនយោបាយអព្យាក្រឹត របស់កម្ពុជា នឹងការរួមរស់ជាមួយគ្នាដោយសន្តិភាព
- ថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ១៩៥៥ ក្នុងពេលកម្ពុជាចូលជាសមាជិកអង្គការសហប្រជាតិ តំណាង រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសពីមាគ៌ាអព្យាក្រឹតភាពនៃកម្ពុជា
- ថ្ងៃទី ១-៦ ខែកញ្ញា ឆ្នាំ១៩៦១ សម្តេចនរោត្តម សីហនុ បានចុះហត្ថលេខាលើធម្មនុញ្ញ នៃចលនាមិនចូលបក្សសម្ព័ន្ធ នៅប្រទេស យូហ្គោស្លាវី

❖ លទ្ធផលនៃការប្រកាន់នយោបាយអព្យាក្រឹត

- ជំហានដំបូង
  - មានការអភិវឌ្ឍប្រទេសលើគ្រប់វិស័យ
  - ប្រទេសកម្ពុជាមានសុខសន្តិភាពរយៈពេល១៥ឆ្នាំ
  - កម្ពុជាមានឈ្មោះល្បីសុះសាយក្នុងតំបន់
  - ក្រុមអ្នកប្រឆាំងពុំហ៊ានប៉ះពាល់ នឹងទទួលស្គាល់គុណសម្បត្តិនយោបាយអព្យាក្រឹត
- ជំណាក់កាលសង្រ្គាមត្រជាក់
  - ឥទ្ធិពលនៃសង្រ្គាមត្រជាក់ មហាអំណាចមនោគមវិជ្ជាទាំងពីរ ពុំទុកកម្ពុជាក្នុងមាគ៌ សន្តិភាព មាគ៌ាអព្យាក្រឹត
  - សហរដ្ឋអាមេរិក ថៃ វៀតណាមខាងត្បូង វៀតណាមខាងជើង ធ្វើសកម្មភាពប្រឆាំង នឹងនយោបាយអព្យាក្រឹត ដែលធ្វើឲ្យកម្ពុជាអនុវត្តនយោបាយអព្យាក្រឹតមិនចំទិសដៅ នឹងនាំកម្ពុជាទៅធ្លាក់ក្នុងភ្លក់ភ្លើងនៃសង្រ្គាម។
    (មានចម្លើយត្រឹមត្រូវផ្សេងៗទៀត)

✍ កំណត់សម្គាល់ ៖ ប្រសិនបើសិស្សឆ្លើយលក្ខណៈទូទៅដូចជា និយមន័យ,ទាក់ទងនឹងសន្និសីទបានខ្លះ ,ចលនាមិនចូលបក្សសម្ព័ន្ធ,នឹងលទ្ធផលនៃនយោបាយអព្យាក្រឹត (ត្រូវបានពិន្ទុ៥)

៣. ការពណ៌នាពីសម័យសង្គមរាស្ត្រនិយម (១៩៥៥-១៩៧០)

❖ ការបង្កើតរបបសង្គមរាស្ត្រនិយម

- រដ្ឋធម្មនុញ្ញឆ្នាំ ១៩៤៧ បានបញ្ញត្តពីអំណាចព្រះមហាក្សត្រដោយ រាល់ទស្សនៈនយោបាយ របស់ព្រះមហាក្សត្រត្រូវដាក់ឲ្យសភាអនុម័ត ទើបយកទៅអនុវត្ត
- សភាតែងតែជំទាស់រាល់គំនិតទស្សនៈនយោបាយរបស់ព្រះមហាក្សត្រ
- ព្រះរាជា ពុំចង់ឃើញការខ្វែងគំនិតគ្នា នឹងការបែកបាក់គ្នា ក្នុងរង្វង់អ្នកដឹកនាំ
- ព្រះរាជាចង់ឲ្យប្រជាជន អ្នកនយោបាយគ្រប់និន្នាការ រួបរួមគ្នាស្ថិតក្រោមម្លប់រាជបល្ល័ង្កតែមួយ
- ដូច្នេះហើយ បានជាព្រះអង្គដាក់រាជ្យ នៅថ្ងៃទី ៣ ខែមីនា ឆ្នាំ១៩៥៥ ហើយបង្កើតអង្គការ សង្គមរាស្ត្រនិយម ថ្ងៃទី ២៣ ខែមីនា ឆ្នាំ១៩៥៥ ដោយចូលរួមបោះឆ្នោតនៅថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ១៩៥៥ ទទួលបានជោគជ័យ ៨៣.៨៧ ភាគរយ។ សង្គមរាស្ត្រនិយមក៏បានកើតឡើង។

❖ សមាជជាតិ

- ជាវេទិកាលទ្ធិប្រជាធិបតេយ្យ ដែលតម្រូវឲ្យប្រជាជនគ្រប់ស្រទាប់វណ្ណៈគ្រប់និន្នការនយោបាយ ចូលរួមបញ្ចេញមតិយោបល់ជាមួយថ្នាក់ដឹកនាំជាតិ ដើម្បីប្រយោជន៍រួមរបស់ជាតិ
- សមាជជាតិត្រូវបានប្រារព្ធឡើងមួយឆ្នាំពីរដង ដោយទទួលបានផ្លែផ្កាជាវិជ្ជមាន

❖ នយោបាយអព្យាក្រឹត នៅកម្ពុជា៖

- គោរពតាមស្មារតីសន្និសីទក្រុងហ្សឺណែវ ឆ្នាំ១៩៥៤
- ដើម្បីរក្សាសន្តិភាពនៅកម្ពុជា
- ដើម្បីរួមរស់ដោយសន្តិសហវិជ្ជមាន
- មានសន្តិភាព រយៈពេល១៥ឆ្នាំ
- ទប់ទល់នឹងឥទ្ធិពលសង្គ្រាមត្រជាក់
- ឥទ្ធិពលនៃសង្គ្រាមត្រជាក់ ធ្វើឲ្យនយោបាយអព្យាក្រឹតដួលរលំ

- ❖ សមិទ្ធផល ៖ មានការរីកចម្រើនលើគ្រប់វិស័យដូចជា
  - វិស័យនយោបាយ
    - ការប្រារព្ធសមាជជាតិ ធ្វើឲ្យមានការអភិវឌ្ឍជាតិលើគ្រប់វិស័យស្របតាមឆន្ទៈប្រជាជន
    - ការអនុវត្តនយោបាយអព្យាក្រឹត ធ្វើឲ្យប្រទេសជាតិបានសុខសន្តិភាពរយៈពេល ១៥ឆ្នាំ (១៩៥៥-១៩៧០)
    - កម្ពុជាបានចូលជាសមាជិកអង្គការសហប្រជាជាតិ (១៤ ធ្នូ ១៩៥៥)
    - កម្ពុជាឈ្នះក្តី ក្នុងរឿងក្តីក្តាំប្រាសាទព្រះវិហារ (១៥ មិថុនា ១៩៦២)
  - វិស័យសេដ្ឋកិច្ច ៖ រីកចម្រើនផ្នែក កសិកម្ម ពាណិជ្ជកម្ម ឧស្សាហកម្ម និងភាពរីកចម្រើនផ្នែក អហារ័ណ នីហារ័ណជាតិ
  - គមនាគមន៍ ៖ ផ្លូវទឹក ផ្លូវគោក និង ផ្លូវអាកាស
  - វិស័យធនាគារ ៖ប្រាក់រៀលត្រូវបានចរាចរណ៍នៅទូទាំងប្រទេស
  - វិស័យវប្បធម៌ ៖ រីកចម្រើនផ្នែក សិក្សាធិការ កីឡា សិល្បៈ
  - សង្គមកិច្ច ៖ ផ្តោតលើបញ្ហាពីរ គឺសុខាភិបាល និងការអនុវត្តច្បាប់។

៤. ពណ៌នាពីចលនាតស៊ូទាមទារឯករាជ្យពីបារាំងនៅកម្ពុជាមាន ៖

- ❖ ការតស៊ូដោយហិង្សា
  - គឺជាចលនាតស៊ូដោយប្រើអាវុធ ប្រយុទ្ធបង្ហូរឈាមដើម្បីទាមទារឯករាជ្យ ដោយចលនាតស៊ូរបស់ខ្មែរ ឥស្សរៈ ដែលក្រុមនេះបានពង្រីកក្រុមខ្លួនទូទាំងប្រទេស។
- ❖ ការតស៊ូដោយអហិង្សា
  - គឺជាចលនាតស៊ូដោយសន្តិវិធី តាមរយៈមធ្យោបាយការទូត ពោលគឺ តាមរយៈនយោបាយក្រៅ ប្រទេសជាមួយបារាំង កាណាដា សហរដ្ឋអាមេរិក ថៃ តាមរយៈនយោបាយការទូត និងការសែត
  - ព្រះបាទនរោត្តមសីហនុ បានមានបន្ទូលថា « បើបារាំងមិនប្រគល់ឯករាជ្យឲ្យកម្ពុជាទេ... នោះ ប្រទេសកម្ពុជាក្លាយជាប្រទេសកុម្មុយនីស្ត »
  - សកម្មភាពក្នុងប្រទេសព្រះអង្គបានគង់នៅតំបន់ស្វយ័តក្នុងខេត្តសៀមរាប បាត់ដំបង កំពង់ធំ ដោយមិនយាងមកភ្នំពេញ ហើយទ្រង់បានបង្កើត កងជីវពល នារីភ្លាហាន ដើម្បី

ឲ្យប្រជារាស្ត ក្រោកឡើងទាមទារឯករាជ្យបរិបូរណ៍។

(មានចម្លើយត្រឹមត្រូវផ្សេងៗទៀត)



បទ: ពង្សាវតារខ្មែរ

ខ្មែរអើយចូរចាំជាក់ថា តាមពង្សាវតារ
បញ្ជាក់ច្រាប់ថា ពូជខ្មែរថ្កើង
ទឹកដីខ្មែរធំ ទូលំទូលាយ
សព្វសាយរុងរឿង គេតែងលើកតម្កើង
តម្កល់ជាតិយើង ចាត់ទុកឡើងជាជាតិច្បង ។
អារ្យធម៌ខ្ពង់ខ្ពស់ឆើតឆាយ បានចេញផ្សព្វផ្សាយ
គ្រប់ទិសទាំងឡាយ ចុងបូព៌ា
សាសនា សិល្បៈ ចម្លាក់ វិចិត្រ គំនិតសិក្សា
តន្ត្រី ទស្សនវិជ្ជា អាចយកសិក្សា
ជាគោលការណ៍ ដែលខ្មែរផ្សាយទៅ ។
ខ្មែរអើយចូរស្តាប់សាវតារ ដែលបានចរចា
បញ្ជាក់ច្រាប់ថា ពូជខ្មែរថ្កើង
តាំងចិត្តអោយធំ ខិតខិតប្រឹងវិញ
បញ្ចេញតម្កើង តម្លៃនៃជាតិខ្មែរយើង
អោយបានរុងរឿង ជាថ្មីឡើងតាមសាវតារ ។

📖 មេរៀនទី៣ របបសាធារណរដ្ឋខ្មែរ (១៩៧០ - ១៩៧៥)

(ដកស្រង់ចេញពីការបង្រៀនក្នុងផេកក្រសួងអប់រំ)

✍ចងក្រងឡើងដោយ ម៉ែត ជីវិន✍

✦✦✦ ✦✦ ⊙ ✦✦✦✦✦

﴿ប្រធានសំណួរ﴾

១. (២០១៥) តើរដ្ឋប្រហារទម្លាក់សម្តេច នរោត្តម សីហនុ កើតឡើងនៅឆ្នាំណា?

២.(២០១៥) តើរដ្ឋប្រហារនេះ បាននាំមកអ្វីខ្លះសម្រាប់ប្រទេសកម្ពុជា?

៣.(២០១៦) ចូរពណ៌នាពីមូលហេតុដែលធ្វើឲ្យសង្គ្រាមស៊ីវិលផ្ទុះឡើងពីឆ្នាំ ១៩៧០-១៩៧៥។

៤.(២០១៦) តើសង្គ្រាមស៊ីវិលពីឆ្នាំ ១៩៧០-១៩៧៥ មានផលវិបាកអ្វីខ្លះសម្រាប់កម្ពុជា?

៥.(២០១៧) តើសង្គ្រាមនៅកម្ពុជាក្នុងឆ្នាំ ១៩៧០-១៩៧៥ នឹងឆ្នាំ១៩៧៩-១៩៩៨ នឹងរបបប្រល័យពូជ សាសន៍ កម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)មានផលវិបាកអ្វីខ្លះសម្រាប់កម្ពុជា?

៦.(២០១៧) ចូរពណ៌នាពីកត្តាសំខាន់ៗដែលធ្វើឲ្យរបបសាធារណរដ្ឋខ្មែរ(១៩៧០-១៩៧៥)ដួលរលំ។

៧.(២០១៩) តើមូលហេតុអ្វីបានជារបបសាធារណរដ្ឋខ្មែរ(១៩៧០-១៩៧៥) ដួលរលំ?

៨.(២០១៩) ហេតុអ្វីបានជាកើតមានរដ្ឋប្រហារឆ្នាំ១៩៧០? តើរដ្ឋប្រហារនេះផ្តល់ផលវិបាកដូចម្តេចខ្លះ ?

៩.(២០២១) មូលហេតុអ្វីដែលនាំឲ្យមានរដ្ឋប្រហារទម្លាក់សម្តេចសីហនុ ?

១០.(២០២២)តើរដ្ឋប្រហារទម្លាក់សម្តេចនរោត្តម សីហនុ កើតឡើងនៅឆ្នាំណា និងបាននាំមកអ្វីខ្លះសម្រាប់កម្ពុជា ?

----------អត្ថាកំណែ----------

១. រដ្ឋប្រហារទម្លាក់ សម្តេច នរោត្តម សីហនុ កើតឡើងនៅឆ្នាំ ១៩៧០ (១៨មីនា១៩៧០)។

២.១០.រដ្ឋប្រហារពុំបាននាំប្រទេសកម្ពុជាទៅរកដំណោះស្រាយ នឹងភាពចម្រុងចម្រើននោះទេ មានតែនាំមកនូវ សង្គ្រាមស៊ីវិល ការបាត់បង់ខូចខាត នឹងវិនាសកម្មដូចជា៖

- ❖ ខាងសង្គម
  - ការបែកបាក់សាមគ្គីជាតិ

- បាតុកម្ម កូដកម្ម កុប្បកម្ម ដែលបង្កនូវការប្រឪកប្រឪលក្លាពអនាធិបតេយ្យទូទាំងប្រទេស
- ប្រជាជនរងទុក្ខវេទនា ព្រាត់ប្រាស់គ្រួសារ ផ្ទះសម្បែង រងគ្រោះទុរ្ភិក្ស
- ប្រជាជនរស់ដោយប្រឈមមុខ នឹងមនោគមវិជ្ជានៃសង្គ្រាមត្រជាក់ សឹកសង្គ្រាម ការទម្លាក់ គ្រាប់បែកពីសហរដ្ឋអាមេរិក
- ប្រជាជនមួយចំនួនរត់ចូលក្នុងព្រៃតាមការអំពាវនាវរបស់សម្តេច នរោត្តម សីហនុ ឯខ្លះទៀត រៀសខ្លួនមកកាន់ទីក្រុងភ្នំពេញ រស់នៅដោយកង្វះអាហារ បាត់បង់ការងារ

❖ ខាងសេដ្ឋកិច្ច

រដ្ឋប្រហារធ្វើឲ្យសេដ្ឋកិច្ចកម្ពុជាជាប់គាំងដោយ ៖

- ដីស្រែចម្ការទំនេរទុកចោល ទិន្នផលធ្លាក់ចុះ
- រោងចក្រសហគ្រាសត្រូវបិទទ្វា
- ទំនិញឡើងថ្លៃ អតិផរណា

❖ ខាងនយោបាយ

- កម្ពុជាបាត់បង់កេរ្តិ៍ឈ្មោះ កិត្តិយសលើឆាកអន្តរជាតិ
- អស្ថិរភាពខាងនយោបាយធ្វើឲ្យប្រជាជនបាត់បង់ជំនឿលើអ្នកដឹកនាំ
- កម្ពុជាបាត់បង់ឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី
- មានការផ្លាស់ប្តូររបបនយោបាយ
- ជាការបើកផ្លូវឲ្យខ្មែរក្រហមឡើងកាន់អំណាច ដែលនាំឲ្យកម្ពុជាទៅរកការសម្លាប់រង្គាលក្នុង របបប្រល័យពូជសាសន៍។

(មានចម្លើយត្រឹមត្រូវផ្សេងៗទៀត)

៣. មូលហេតុដែលធ្វើឲ្យសង្គ្រាមស៊ីវិលផ្ទុះឡើងពីឆ្នាំ ១៩៧០-១៩៧៥ ៖

- ដោយសារឥទ្ធិពលសង្គ្រាមត្រជាក់
- ការអនុវត្តនយោបាយអព្យាក្រឹតរបស់ សម្តេចនរោត្តម សីហនុ មិនចំទិសដៅ ឬលម្អៀង
- រដ្ឋប្រហារទម្លាក់ សម្តេចនរោត្តម សីហនុ (១៨មីនា១៩៧០)
- អំពើពុករលួយ បក្សពួកនិយម បាតុកម្ម កុប្បកម្មពេញផ្ទៃប្រទេស
- មន្ត្រីរបស់សម្តេច នរោត្តម សីហនុ ក្បត់នឹងព្រះអង្គ

- ការជ្រៀកជ្រែករបស់វៀតណាម ចិន សហរដ្ឋអាមេរិក ក្នុងនយោបាយខ្មែរ
- ការបង្កើត រណសិរ្សរួបរួមជាតិកម្ពុជា របស់សម្តេចនរោត្តម សីហនុ។ (ចំណុចផ្សេងៗទៀត)

៤.៥.សង្គ្រាមស៊ីវិលពីឆ្នាំ ១៩៧០-១៩៧៥,ឆ្នាំ១៩៧៩-១៩៩៨ នឹងរបបប្រល័យពូជសាសន៍កម្ពុជាប្រជា ធិបតេយ្យ (១៩៧៥-១៩៧៩) បាននាំមកនូវ ការខូតខាត នឹងវិនាសកម្មយ៉ាងធ្ងន់ធ្ងរ ដល់កម្ពុជាដូចជា៖

❖ វិនាសកម្មខាងសង្គម
- សម្លាប់ជីវិតមនុស្សអស់រាប់លាននាក់ និងធ្វើឲ្យមានរបួស ពិការជាច្រើន
- បន្សល់នៅស្ត្រីមេម៉ាយ ក្មេងកំព្រា ចាស់ជរាគ្មានទីពឹង
- ប្រជាជនរងទុក្ខវេទនា ព្រាត់ប្រាស់គ្រួសារ ផ្ទះសម្បែង ជួបគ្រោះទុរ្ភិក្ស
- បំផ្លាញផ្ទះសម្បែង វត្តអារាម សាលារៀន គ្រឹះស្ថានសាធារណៈ មន្ទីពេទ្យ
- បំបាត់សិទ្ធិសេរីភាព
- ជួបនៅអនាធិបតេយ្យ ចោរកម្ម ពុករលួយ អយុត្តិធម៌
- បំផ្លាញធនធានមនុស្ស...

❖ ការខូចខាតខាងសេដ្ឋកិច្ច
- ដីស្រែចម្ការទុកទំនេរចោល និងក្លាយជាចម្ការមីន រណ្តៅគ្រាប់បែក
- សំណង់ធារាសាស្ត្រ សំណង់បរិក្ខា ស្ពាន ផ្លូវថ្នល់ កំពង់ផែ ត្រូវខ្ទេចខ្ទាំ
- កសិដ្ឋាន រោងសិប្បកម្ម រោងចក្រសហគ្រាស ត្រូវបំផ្លាញ
- ចម្ការកៅស៊ូ ត្រូវខូចខាត វិស័យពាណិជ្ជកម្មត្រូវរាំងស្ទះ
- បាត់បង់ធនធាន និងអ្នកវិនិយោគមិនហ៊ានចូលមកជាក់ទុន
- ទំនិញឡើងថ្លៃ អតិផរណា...

❖ ខាងនយោបាយ ៖ អស្ថិរភាពខាងនយោបាយ បាននាំមកនូវ ៖
- ការបាត់បង់កិត្តិយស កេរ្តិ៍ឈ្មោះជាតិកម្ពុជាលើឆាកអន្តរជាតិ
- កម្ពុជាបាត់បង់ឯករាជ្យ អធិបតេយ្យភាព បូរណភាពទឹកដី
- ប្រជាជនអស់ទំនុកចិត្តលើអ្នកដឹកនាំ អស់សង្ឃឹមលើវាសនាជាតិខ្លួន

- នាំកម្ពុជាទៅរកការបែកបាក់ជាតិ ការសម្លាប់រង្គាលលើជាតិសាសន៍ឯង (របបកម្ពុជាជាតិប្រជាធិបតេយ្យ)
- កម្ពុជា ជាប្រទេសរស់នៅដោយឯកោ...

៦.៧.មូលហេតុបណ្តាលឲ្យរបបសាធារណរដ្ឋខ្មែរដួលរលំ ៖

- ប្រជាជននៅទីក្រុងភ្នំពេញ នឹងនៅតំបន់រំដោះនឿយណាយនឹងរបបសាធារណរដ្ឋខ្មែរ ដែលពោរពេញដោយភាពអាប់អួរ
- ប្រជាជននៅក្រុងភ្នំពេញ រស់លើដីដ៏តូចចង្អៀត ដោយរងនូវ ៖
  - កង្វះអាហារ កង្វះជម្រក បាត់បង់ការងារ
  - ទំនិញឡើងថ្លៃ អតិផរណា
  - អនាធិបតេយ្យភាព ចោរកម្ម អយុត្តិធម៌ ពុករលួយ បនល្បែងពាលា
  - ភាពច្របូកច្របល់ បាតុកម្ម កូដកម្ម កុប្បកម្ម ពេញទីក្រុង
- រដ្ឋាភិបាល លន់ នល់ គ្រប់គ្រងបានតែទីក្រុង នឹងទីប្រជុំជន ឯជនបទស្រែចម្ការគ្រប់គ្រងដោយ បក្សកុម្មុនីស្តកម្ពុជា (ខ្មែរក្រហម)
- សេដ្ឋកិច្ចរបបសាធារណរដ្ឋខ្មែរ មិនដំណើការ របបនេះរស់ដោយសារជំនួយពីសហរដ្ឋអាមេរិក
- ការដឹកជញ្ជូនស្បៀង សព្វាវុធ របស់សហរដ្ឋអាមេរិកដើម្បីជួយរដ្ឋាភិបាលលោក លន់ នល់ ត្រូវខ្មែរក្រហមកាត់ផ្តាច់ទាំងផ្លូវគោក នឹងផ្លូវទឹក
- ខ្មែរក្រហមធ្វើការហ៊ឹមព័ទ្ធទីក្រុងភ្នំពេញ នឹងរឹតបន្តឹងការនាំស្បៀងចូល
- ការចចារវាងតំណាងសាធារណរដ្ឋខ្មែរ នឹងតំណាងសម្តេចនរោត្តម សីហនុ ត្រូវបរាជ័យ
- ថ្ងៃទី១ ខែមេសា ឆ្នាំ១៩៧៥ លោក លន់ នល់ បានភៀសខ្លួនទៅសហរដ្ឋអាមេរិក
- ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញ។ (មានចម្លើយត្រឹមត្រូចផ្សេងៗទៀត)

៨. មូលហេតុ នឹងផលវិបាកនៃរដ្ឋប្រហារឆ្នាំ ១៩៧០ ៖

❖ ហេតុដែលនាំឲ្យមានរដ្ឋប្រហារឆ្នាំ ១៩៧០

មុនរដ្ឋប្រហារប្រទេសកម្ពុជា បានជួបវិបត្តិសង្គម សេដ្ឋកិច្ច នយោបាយ យ៉ាងធ្ងន់ធ្ងរដែលមិនអាចដោះស្រាយបាន ដូចជា៖

- បែគ្គិសង្គម
  - ការបែកបាក់សាមគ្គីជាតិ ទៅតាមមនោគមវិជ្ជា ដែលសាបព្រួសដោយអ្នកនយោបាយ (ខ្មែរក្រហម ខ្មែរខៀវ ខ្មែរស)
  - សង្គមជួបនូវអំពើពុករលួយ បក្ខពួកនិយម អនាធិបតេយ្យ អយុត្តិធម៌ ចោរកម្ម
  - ប្រជាជនរស់នៅតាមព្រំដែនកម្ពុជា-វៀតណាម រងនូវការទម្លាក់គ្រាប់បែក
  - ភាពចលាចល បាតុកម្ម កុប្បកម្ម ប្រឆាំងនឹងវត្តមានប្រជាជន និងកងទ័ពវៀតណាមកាន់តែច្រើនឡើងលើទឹកដីកម្ពុជា
- បែគ្គិសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

  សេដ្ឋកិច្ចជាតិធ្លាក់ចុះយ៉ាងខ្លាំងងើបលែងរួច ដោយសារ ៖
  - ការធ្វើគូបនីយកម្មបានធ្វើឲ្យធនគារឯកជន ក្រុមហ៊ុនឯកជនត្រូវបានបិទទ្វារ ប្រជាជន ឥតការងារធ្វើ
  - រដ្ឋបាត់បង់ប្រាក់ចំណូល ដោយសារតែទំនិញគេចពន្ធ អំពើពុករលួយ ការបដិសេធជំនួយពីសហរដ្ឋអាមេរិក
  - ការចំណាយ និងចំណូលខ្វះតុល្យភាព
  - ទំនិញឡើងថ្លៃ អតិផរណាក្រដាសប្រាក់
  - ការដឹកជញ្ជូនត្រូវរាំងស្ទះ
- បែគ្គិនយោបាយ

  ឥទ្ធិពលនៃសង្គ្រាមត្រជាក់បានបណ្តាលឲ្យ ៖
  - កម្ពុជាអនុវត្តន៍នយោបាយអព្យាក្រឹតមិនចំទិសដៅ និងលូកដៃចូលក្នុងសង្គ្រាមវៀតណាម
  - អ្នកនយោបាយខ្មែរបែកបាក់សាមគ្គីជាតិ
  - អ្នកនយោបាយខ្លះទៀតរៀបចំផែនការក្បត់សម្តេច នរោត្តម សីហនុ
  - មានការផ្លាស់ប្តូរជរដ្ឋាភិបាលញឹកញាប់
  - ខ្មែរក្រហម ពង្រឹងកម្លាំងនៅ ភូមិភាគឦសាន ឧត្តរ ពាយ័ព្យ ហើយវាយប្រហារលើសង្គមរាស្ត្រនិយម ព្រមទាំងគ្រប់គ្រងទឹកដីបានមួយចំនួន

- រដ្ឋាភិបាលមិនអាចទប់ស្កាត់ការបោះបោររបស់ប្រជាជនប្រឆាំងនឹងវត្តមាន ប្រជាជន និង កងទ័ពវៀតណាម កាន់តែច្រើនឡើងនៅលើដីកម្ពុជា

✓ មូលហេតុខាងលើនេះបណ្តាលឲ្យមានរដ្ឋប្រហារទម្លាក់សម្តេច នរោត្តម សីហនុ ពីប្រមុខរដ្ឋ នាថ្ងៃទី ១៨ ខែមីនា ឆ្នាំ១៩៧០ ។ (ចម្លើយសំណួរទី៩ ក៏ចឹងដែរ) (មានចម្លើយត្រូវផ្សេងៗទៀត)

❖ ផលវិបាកនៃរដ្ឋប្រហារឆ្នាំ១៩៧០ ៖ រដ្ឋប្រហារពុំបាននាំប្រទេសកម្ពុជាទៅរកដំណោះស្រាយ នឹងភាពចម្រុងចម្រើននោះទេ មានតែនាំមកនូវ សង្គ្រាមស៊ីវិល ការបាត់បង់ខូចខាតនឹងវិនាសកម្មដូចជា ៖

➢ ខាងសង្គម

- ការបែកបាក់សាមគ្គីជាតិ
- បាតុកម្ម កូដកម្ម កុប្បកម្មដែលបង្កនូវការច្របូកច្របល់ភាពអនាធិបតេយ្យទូទាំងប្រទេស
- ប្រជាជនរងទុក្ខវេទនា ព្រាត់ប្រាស់គ្រួសារ ផ្ទះសម្បែង រងគ្រោះទុរ្ភិក្ស
- ប្រជាជនរស់ដោយប្រឈមមុខ នឹងមនោគមវិជ្ជានៃសង្គ្រាមត្រជាក់ សឹកសង្គ្រាម ការទម្លាក់គ្រាប់បែកពីសហរដ្ឋអាមេរិក
- ប្រជាជនមួយចំនួនរត់ចូលក្នុងព្រៃតាមការអំពាវនាវរបស់សម្តេច នរោត្តម សីហនុ ឯខ្លះ ទៀតភៀសខ្លួនមកកាន់ទីក្រុងភ្នំពេញ រស់នៅដោយកង្វះអាហារ បាត់បង់ការងារ

➢ ខាងសេដ្ឋកិច្ច

រដ្ឋប្រហារធ្វើឲ្យសេដ្ឋកិច្ចកម្ពុជាជាប់គាំងដោយ ៖

- ដីស្រែចម្ការទំនេរទុកចោល ទិន្នផលធ្លាក់ចុះ
- រោងចក្រសហគ្រាសត្រូវបិទទ្វារ
- ទំនិញឡើងថ្លៃ អតិផរណា

➢ ខាងនយោបាយ

- កម្ពុជាបាត់បង់កេរ្តិ៍ឈ្មោះ កិត្តិយសលើឆាកអន្តរជាតិ
- អស្ថិរភាពខាងនយោបាយធ្វើឲ្យប្រជាជនបាត់បង់ជំនឿលើអ្នកដឹកនាំ

- កម្ពុជាបាត់បង់ឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី
- មានការផ្លាស់ប្តូររបបនយោបាយ
- ជាការបើកផ្លូវឲ្យខ្មែរក្រហមឡើងកាន់អំណាច ដែលនាំឲ្យកម្ពុជាទៅរកការសម្លាប់រង្គាលក្នុងរបបប្រល័យពូជសាសន៍។

(មានចម្លើយត្រឹមត្រូវផ្សេងៗទៀត)

📖 មេរៀនទី៤ កម្ពុជាប្រជាធិបតេយ្យ (១៩៧៥ - ១៩៧៩)

(ដកស្រង់ចេញពីការបង្រៀនក្នុងផេកក្រសួងអប់រំ)

✍ចងក្រងឡើងដោយ ម៉ែត ជីវិន✍

✦✦✦ ✦✦ ⊙ ✦✦✦✦✦

﴿ប្រធានសំណួរ﴾

១.(២០១៤) មូលហេតុអ្វីបានជាត្រូវកាត់ទោសមេដឹកនាំ កម្ពុជាប្រជាធិបតេយ្យ (ខ្មែរក្រហម)?

២.(២០១៤) ពណ៌នាអំពីវិនាសសកម្មនៅកម្ពុជាក្រោមរបបប្រល័យពូជសាសន៍កម្ពុជាប្រជាធិបតេយ្យនិងការស្ថាបនាកម្ពុជាឡើងវិញ។

៣.(២០១៦) តើនរណាគេជាមេខ្មែរក្រហម?សូមរាប់ឲ្យបានបីនាក់។

៤.(២០១៦) ហេតុអ្វីបានជាកម្ពុជាវេងនូវការបំផ្លិចបំផ្លាញក្នុងរបបខ្មែរក្រហម?

៥.(២០១៨) ចូរពណ៌នាពីកត្តាសំខាន់ៗដែលធ្វើឲ្យរបបកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩)ដួលរលំ។

៦.(២០១៨) មូលហេតុអ្វីបានជារបបប្រល័យពូជសាសន៍ កម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩) សម្លាប់មនុស្ស? តើមានផលវិបាកអ្វីខ្លះសម្រាប់កម្ពុជា?

៧.(២០១៩) ចូររៀបរាប់ឈ្មោះមេដឹកនាំខ្មែរក្រហមសំខាន់ៗឲ្យបានប្រាំនាក់។

៨.(២០១៩) ហេតុអ្វីបានជាតុលាការយកមេដឹកនាំកំពូលរបស់ខ្មែរក្រហម ដែលកាន់អំណាចនៅឆ្នាំ ១៩៧៥-១៩៧៩ ទៅកាត់ទោស?

៩.(២០២១) តើមូលហេតុអ្វីបានជារបបកម្ពុជាប្រជាធិបតេយ្យដួលរលំ ?

---------- អត្ថាធិប្បាយ ----------

១.៨.បានជាតុលាយកមេដឹកនាំកំពូលរបស់ខ្មែរក្រហម ដែលកាន់អំណាចនៅឆ្នាំ ១៩៧៥-១៩៧៩ ទៅកាត់ទោសព្រោះ៖

❖ មេដឹកនាំខ្មែរក្រហមទាំងនេះបានប្រព្រឹត្តអំពើឧក្រិដ្ឋកម្មក្នុងពេលកាន់អំណាចមាន:

- ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍
- ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ
- ឧក្រិដ្ឋកម្មសង្គ្រាម
- ឧក្រិដ្ឋកម្មប្រឆាំងនឹងអ្នកទទួលបានការការពារជាអន្តរជាតិ

- ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវឆ្នាំ១៩៥៤
- ការបំផ្លាញទ្រព្យសម្បត្តិវប្បធម៌របស់មនុស្សជាតិ

❖ តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមទាំងនេះដើម្បី:

- ផ្តល់យុត្តិធម៌ ផ្តល់ភាពស្ងប់ចិត្ត ការផ្សះផ្សាវិបត្តផ្លូវចិត្ត ដល់ជនរងគ្រោះដែលរស់រានមានជីវិត
- ជាមេរៀន ជាគំរូដល់មេដឹកនាំជំនាន់ក្រោយកុំឲ្យត្រាប់តាម
- ដើម្បីទប់ស្កាត់កុំឲ្យរបបនេះកើតមានជាថ្មី
- ធ្វើការបង្រួបបង្រួមជាតិ និង ផ្សះផ្សាជាតិ
- ផ្តល់យុត្តិធម៌ឲ្យជនរងគ្រោះដែលបាត់បង់ជីវិត
- ជាការដាក់ទណ្ឌកម្មដល់អ្នកដែលបានប្រព្រឹត្តខុសកុំឲ្យរួចខ្លួន

២.វិនាសកម្មនៅកម្ពុជា ក្រោមរបបប្រល័យពូជសាសន៍ កម្ពុជាប្រជាធិបតេយ្យ និងការស្តារបនាកម្ពុជាឡើងវិញ ៖

❖ វិនាសកម្មក្រោមរបបប្រល័យពូជសាសន៍ ៖

- សង្គម : ជម្លៀសប្រជាជន សម្លាប់រង្គាល បង្អត់អាហារ ធ្វើការជាទម្ងន់ បំបិទសិទ្ធិសេរីភាព...
- វប្បធម៌ : បំបាត់សាលារៀន វត្តអារាម ជំនឿ សាសនា ទំនៀមទម្លាប់ ប្រពៃណី
- ហេដ្ឋរចនាសម្ព័ន្ធ : សាលារៀន មន្ទីរពេទ្យ ផ្លូវថ្នល់ ស្ពាន សំណង់ សាធារណៈរងការខូចខាត
- សេដ្ឋកិច្ច : បំបាត់ទីផ្សារ រូបិយវត្ថុ កម្មសិទ្ធិឯកជន ពាណិជ្ជកម្មក្នុង និងក្រៅប្រទេស
- នយោបាយ : អនុវត្តនយោបាយផ្តាច់ការ បំភិតបំភ័យ សម្រិតសម្រាំង សម្លាប់ និងផ្តាច់ទំនាក់ទំងជាមួយប្រទេសមួយចំនួនលើពិភពលោក។

❖ ការស្តារបនាកម្ពុជាឡើងវិញ ៖

- បង្កើតក្រុមសាមគ្គីបង្កបង្កើនផល ដើម្បីជួយស្ត្រីមេម៉ាយ ចាស់ជរា ក្មេងកំព្រា...
- បង្កើតរចនាសម្ព័ន្ធគ្រប់គ្រង
- ស្តារសេដ្ឋកិច្ច កសិកម្ម ឧស្សាហកម្ម ពាណិជកម្ម

- អបរំ វប្បធម៌ បង្កើតសាលារៀនគ្រប់កម្រិតសិក្សា បង្កើតវត្តអារាម ជំនឿ សាសនា ប្រពៃណី ទំនៀមទម្លាប់
- ខាងនយោបាយ ស្តារមុខមាត់សេដ្ឋកិច្ចជាតិកម្ពុជាលើឆាកអន្តរជាតិ បង្រួបបង្រួមជាតិ ដែល ឈានទៅដល់ការបញ្ចប់សង្គ្រាម (២៣ តុលា ១៩៩១)

៣.៧.មេដឹកនាំខ្មែរក្រហមសំខាន់ៗមាន ៖

- សាឡុត ស (ប៉ុល ពត)
- នួន ជា
- ខៀវ សំផន
- អៀង សារី
- សុន សេន
- អៀង ធារិទ្ធ
- វន រ៉ែត
- សោ ភឹម
- ឈិត ជឿន (តាម៉ុក)...។

៤.កម្ពុជារងការបំផ្លិចបំផ្លាញក្នុងរបបខ្មែរក្រហមព្រោះ ៖

- ប្រកាន់យករបបផ្តាច់ការ ខ្មៅងងឹត
- ទទួលរងឥទ្ធិពលសង្គ្រាមត្រជាក់
- មេដឹកនាំមានចរឹតជាតិនិយមជ្រុល
- មនោគមវិជ្ជាជ្រុល
- ការប្រល័យពូជសាសន៍
- ជម្លៀសប្រជាជនចេញពីទីក្រុង និងទីប្រជុំជននានា
- បង្ខំប្រជាជនខ្មែរឲ្យធ្វើការជាទម្ងន់
- បង្អត់អាហារ ធ្វើទារុណកម្ម
- បំបិទសិទ្ធិសេរីភាព បំបាត់ជំនឿ សាសនា ប្រពៃណី ទំនៀមទម្លាប់ ការអប់រំ
- បង្កើតសហករណ៍កម្រិតខ្ពស់ទូទាំងប្រទេស លុបបំបាត់កម្មសិទ្ធិឯកជន
- ធ្វើវិសុទ្ធកម្ម ។ (មានទិដ្ឋភាពផ្សេងៗទៀត)

៥.៩.កត្តាដែលធ្វើឲ្យរបបកម្ពុជាប្រជាធិបតេយ្យដួលរលំមាន ៖

❖ ការស្អប់ខ្ពើមរបប ប៉ុល ពត របស់ប្រជាជនកម្ពុជា ព្រោះរបបនេះមាន ៖

- ធ្វើទារុណកម្ម នឹងការសម្លាប់ប្រជាជន
- បង្ខំឲ្យមនុស្សធ្វើការដោទម្ងន់ ទ្រុឌទ្រោមសុខភាព និងបាក់កម្លាំង
- កង្វះអាហារ កង្វះសម្លៀកបំពាក់ គ្មានថ្នាំសម្រាប់ព្យាបាល រងចាំតែសេចក្តីស្លាប់
- បំបិទសិទ្ធិសេរីភាព ជំនឿសាសនា ប្រពៃណី ទំនៀមទម្លាប់

❖ ការសម្រិតសម្រាំងយកមនុស្សបដិវត្តន៍បរិសុទ្ធ ៖

ការអនុវត្តនយោបាយសម្រិតសម្រាំងយកមនុស្សបដិវត្តន៍បរិសុទ្ធក្នុងចំណោមសមាជិកសំខាន់ៗនៃ បក្សកុម្មុយនីស្តកម្ពុជាបានបណ្តាលឲ្យ ៖

- មានការចាប់ ការសួរចម្លើយ ការធ្វើទារុណកម្ម សម្លាប់កម្មាភិបាលគ្នាឯង
- សមាជិកបក្សកុម្មុយនីស្តកម្ពុជា និងថ្នាក់ដឹកនាំបែកបាក់ផ្ទៃក្នុង

❖ ការធ្វើសង្គ្រាមជាមួយវៀតណាម ៖

ចាប់ពីឆ្នាំ ១៩៧៥ កម្ពុជាប្រជាធិបតេយ្យ ចាប់ផ្តើមបង្កជម្លោះតាមព្រំដែន ដោយពុំប្រមាណកម្លាំង របស់ខ្លួន (កងទ័ពខ្មែរក្រហមមានចំនួនតិច អាវុធពុំទំនើប យុទ្ធសាស្ត្រខ្សោយ ឯកងទ័ពវៀតណាម មានចំនួនច្រើន អាវុធទំនើប យុទ្ធសាស្ត្រខ្លាំង)

❖ ការបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ៖

- នៅថ្ងៃទី ២ ខែធ្នូ ឆ្នាំ១៩៧៨ រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបានបង្កើតឡើងក្នុងបំណង រំដោះប្រទេសពីរបបកម្ពុជាប្រជាធិបតេយ្យដែលជារបបប្រល័យពូជសាសន៍
- ដោយមានការគាំទ្រពីកងទ័ពវៀតណាម រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបានបើកការវាយ ប្រហារលើកងទ័ពខ្មែរក្រហមនាថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៧៨ នឹងទទួលបានជោគជ័យជម្នះនៅ ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ។

៦.មូលហេតុនៃការសម្លាប់មនុស្ស ក្នុងរបបប្រល័យពូជសាសន៍ កម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នឹងផលវិបាកដល់កម្ពុជា៖

❖ មូលហេតុ ៖

- ការអនុវត្តគោលនយោបាយ ៨ប្រការរបស់ខ្មែរក្រហម
- ប្រកាន់បដិវត្តន៍កុម្មុយនីស្ត ដែលតម្រូវឲ្យមានការកម្ទេច

- ការអនុវត្តនយោបាយ « មហាលោតផ្លោះ មហាអស្ចារ្យ » ដើម្បីសម្រេចគោលដៅឲ្យបានឆាប់ រហ័ស (ផែនការ៤ឆ្នាំ)
- គំនិតស្នេហាជាតិនិយមជ្រុល ងងឹតងងុល ដោយតម្រូវឲ្យជឿជាក់តែលើអង្គការមួយ បើពុំនោះទេ ត្រូវតែសម្លាប់ចោល
- ការអប់រំបំពាក់កំហឹងវណ្ណៈដល់កម្មាភិបាលខ្មែរក្រហម តាំងពីមុនឆ្នាំ១៩៧៥
- នយោបាយរឹមជ្ឈការសិទ្ធិអំណាច កាប់សម្លាប់មនុស្សដល់កម្មាភិបាលថ្នាក់ទាបដែលភាគច្រើន ជាមនុស្សមានការសិក្សាតិចតួច ឬល្ងង់ខ្លៅ និងក្លាយជាអ្នកដឹកនាំតាមមូលដ្ឋានដោយខ្វះការត្រួត ពិនិត្យពីថ្នាក់លើ
- គោលនយោបាយបោសសម្អាត សម្រិតសម្រាំង យកមនុស្សបដិវត្តន៍បរិសុទ្ធ
- គំនុំគំគួនផ្សេងៗ ការសងសឹក...
- ការធ្វើសង្គ្រាមប្រឆាំងវៀតណាម...

❖ ផលវិបាក ៖

របបកម្ពុជាប្រជាធិបតេយ្យបង្កផលវិបាកដល់ប្រទេសជាតិមានដូចជា៖

- បាត់បង់កិត្តិយសជាតិ នឹងកិត្យានុភាពលើឆាកអន្តរជាតិ
- ជាប់និរន្តរភាពក្នុងការអភិវឌ្ឍជាតិ
- សេដ្ឋកិច្ចជាតិរលត់រលាយ
- ប្រព័ន្ធអប់រំត្រូវបានបំផ្លាញទាំងស្រុង បាត់បង់ធនធានមនុស្ស
- បន្សល់ទុកស្ត្រីមេម៉ាយ ក្មេងកំព្រា ជនបាក់កម្លាំង
- ប្រជាជនរាប់សែននាក់ រត់ចាកចោលប្រទេស
- បង្កជាវិបត្តិផ្លូវចិត្ត
- ហេដ្ឋារចនាសម្ព័ន្ធត្រូវបំផ្លាញ
- វប្បធម៌ សាសនា និងជំនឿត្រូវបំផ្លាញចោល
- សិទ្ធិ សេរីភាព កម្មសិទ្ធិឯកជន តម្រូវការជាមូលដ្ឋានត្រូវបានដកហូត...

(មតិផ្សេងៗទៀត)

📖 មេរៀនទី៥ សាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា (១៩៧៩-១៩៩៣)

(ដកស្រង់ចេញពីការបង្រៀនក្នុងផេកក្រសួងអប់រំ)

✍ចងក្រងឡើងដោយ ម៉ែត ជីវិន✍

✦✦✦ ✦✦ ⊙ ✦✦✦✦✦

﴿ប្រធានសំណួរ﴾

១.(២០១៤) ពណ៌នាពីនយោបាយបង្រួបបង្រួមជាតិ ដែលបាននាំមកនូវសន្តិភាពនៅកម្ពុជា។

២.(២០១៦) ពណ៌នាពីការកសាងជាតិឡើងវិញក្រោយរបបខ្មែរក្រហមពីឆ្នាំ១៩៧៩-១៩៩០។

៣.(២០១៧) ចូរពណ៌នាពីចលនាតស៊ូ ដើម្បីរំដោះប្រទេសកម្ពុជាពីរបបប្រល័យពូជសាសន៍ " កម្ពុជាប្រជាធិបតេយ្យ " (១៩៧៥-១៩៧៩)។

៤.(២០១៩) ចូរពណ៌នាពីរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា។

៥.(២០១៩) ចូរអ្នកពណ៌នាពីការខិតខំចរចារកសន្តិភាពនិងការបង្រួបបង្រួមជាតិនៅកម្ពុជា។

៦.(២០២១) ចូរពណ៌នាពីនយោបាយបង្រួបបង្រួមជាតិនាំមកនូវសន្តិភាពជូនកម្ពុជា ។

៧.(២០២២) តើថ្ងៃរំដោះ៧មករា ១៩៧៩ បានផ្តល់អត្ថន័យជាប្រវត្តិសាស្ត្រយ៉ាងដូចម្តេចខ្លះចំពោះកម្ពុជា ?

----------អត្ថាកំណែ----------

១.៥.៦. ការខិតខំចរចារកសន្តិភាព និងការបង្រួបបង្រួមជាតិនៅកម្ពុជា ៖

- ខែវិច្ឆិកា ១៩៨៤ ប្រទេសបារាំងបានរៀបចំគម្រោងជំនួបរវាងសម្តេច នរោត្តម សីហនុ និងតំណាងសាធារណរដ្ឋប្រជាមានិតកម្ពុជា
- ឆ្នាំ ១៩៨៥ សភាពការណ៍នយោបាយនៅអាស៊ី អនុគ្រោះដល់ការចរចារកសន្តិភាពនៅកម្ពុជា
- ខែកក្កដា ឆ្នាំ១៩៨៧ ទស្សនកិច្ចជាផ្លូវការរបស់មន្ត្រីការប្រទេសឥណ្ឌូនេស៊ី នៅវៀតណាម ពិភាក្សាលើរូបមន្តនៃការជួបគ្នារវាងគូវិវាទខ្មែរទាំងអស់ជាពីរដំណាក់កាលគឺ
  - ការជួបគ្នារវាងបណ្តាភាគីខ្មែរបដិបក្ខទាំងពីរ
  - ការជួបគ្នារវាងបណ្តាភាគីខ្មែរ នឹងប្រទេសពាក់ព័ន្ធដើម្បីដោះស្រាយនយោបាយនៅកម្ពុជា

- ឆ្នាំ១៩៨៧ ជំនួបកំពូលរវាង អាមេរិក និងសហភាពសូវៀត ធ្វើឲ្យសភាពការណ៍នៅកម្ពុជាបានធូរស្រាល
- ខែសីហា នឹងខែតុលា ឆ្នាំ១៩៨៧ រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាជាក់សំណើសន្តិភាព និងបង្រួបបង្រួមជាតិទៅភាគីសម្តេច នរោត្តម សីហនុ
- ថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៨៧ ជួបលើកទី១រវាងសម្តេចនរោត្តម សីហនុ និងលោក ហ៊ុន សែន
- ជំនួបលើកទី២ រវាងសម្តេចនរោត្តម សីហនុ និងលោក ហ៊ុន សែន ថ្ងៃទី២១-២២ ខែមករា ១៩៨៨ នៅប្រទេសបារាំង ជំនួបលើកទី៣-៤-៥ សម្តេចនរោត្តម សីហនុ បានលុបចោល
- វេទិកាសម្តេច នរោត្តម សីហនុ និងឯកឧត្តម ហ៊ុន សែន ប្រព្រឹត្តទៅនៅទីក្រុងប៉ារីស ហ្សាកាតា នឹងប៉ាតាយ៉ា ដើម្បីដោះស្រាយនយោបាយកម្ពុជា
- ថ្ងៃទី ២៦ កញ្ញា ១៩៨៩ កងទ័ពវៀតណាមដកចេញពីកម្ពុជា
- ថ្ងៃទី៣០ កក្កដា ដល់៣០ សីហា ១៩៨៩ នៅទីក្រុងប៉ារីស សហប្រជាន (ឥណ្ឌូនេស៊ី+បារាំង) បានបង្កើតក្រុមប្រឹក្សាជាតិជាន់ខ្ពស់ (SNC) នៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩០ ដែលមាន សមាជិក១២រូប(៦រូបមកពីភាគីរដ្ឋកម្ពុជា នឹង៦រូបមកពីសម្ព័ន្ធត្រីភាគី) ក្រុមប្រឹក្សាជាតិជាន់ ខ្ពស់ប្រជុំនៅទីក្រុងបាងកក នៅប្រទេសបារាំង ក្រុងញ៉ូវយ៉ក ហ្សាកាតា យ៉ាតាយ៉ា និងប៉េកាំង ដើម្បីដោះស្រាយ បញ្ចប់សង្គ្រាមនៅកម្ពុជា
- ថ្ងៃទី២៣-២៤ ខែមិថុនា ឆ្នាំ១៩៩១ ភាគីទាំង៤បានស្រុះស្រួលគ្នាដោះស្រាយបញ្ហាជាតិ
- ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ សន្និសីទក្រុងប៉ារីស បានព្រមព្រៀងចុះហត្ថលេខាលើ សន្ធិសញ្ញាសន្តិភាព ហើយវិបត្តិនយោបាយនៅកម្ពុជាត្រូវបានបញ្ចប់
- ថ្ងៃទី២៣-២៨ ខែឧសភា ឆ្នាំ១៩៩៣ ការបោះឆ្នោតដោយសេរី និងយុត្តិធម៌បានរៀបចំឡើងដោយ អ៊ុនតាក់
    - នយោបាយ ឈ្នះ-ឈ្នះរបស់សម្តេច ហ៊ុន សែន
- ឆ្នាំ១៩៩៨ សមាហរណកម្ម កងកម្លាំងខ្មែរក្រហម ឲ្យចូលមករួមរស់ជាមួយរដ្ឋាភិបាលដែលនាំសន្តិភាពពេញលេញមកឲ្យកម្ពុជា ។

(ចម្លើយត្រឹមត្រូវផ្សេងៗទៀត)

២.ការកសាងជាតិឡើងវិញ ក្រោយរបបខ្មែរក្រហមពីឆ្នាំ១៩៧០-១៩៩០ ៖

❖ វិស័យនយោបាយ

- រំដោះប្រជាជនរួចផុតពីរបបប្រល័យពូជសាសន៍ ប៉ុល ពត ទាំងស្រុង
- ទប់ស្កាត់ការវិលត្រឡប់នៃរបបប្រល័យពូជសាសន៍ ប៉ុល ពត
- ទប់ស្កាត់អំពើអសកម្មក្នុងសង្គម ការជួញដូរមនុស្ស អាវុធ គ្រឿងញៀន
- លើកកម្ពស់លទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស
- ធ្វើកំណែទម្រង់រដ្ឋធម្មនុញ្ញ (វិសោធនកម្មរដ្ឋធម្មនុញ្ញ)
- អនុវត្តនយោបាយបង្រួបបង្រួមជាតិ

❖ វិស័យសេដ្ឋកិច្ច ៖ រដ្ឋាភិបាលបានស្ថាបនាសេដ្ឋកិច្ចដោយ ៖

- បង្កើតក្រុមសាមគ្គីបង្កបង្កើនផល ដើម្បីជួយដល់ស្ត្រីមេម៉ាយ ក្មេងកំព្រា ចាស់ជរា..
- ឆ្នាំ១៩៨០ បោះពុម្ពក្រដាសប្រាក់ឲ្យចាយវាយទូទាំងប្រទេស
- ឆ្នាំ១៩៨៣-១៩៨៦ ប្តូរពីក្រុមសាមគ្គីបង្កបង្កើនផល ទៅជាម្ចាស់ការទាំងស្រុងដោយធ្វើបែងចែកដីធ្លី នឹងឈានទៅរកកម្មសិទ្ធិឯកជន
- អនុវត្តមុខព្រួញទាំង៤នៃសេដ្ឋកិច្ច
- កសាងហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច (ផ្លូវថ្នល់ ស្ពាន កំពង់ផែ...)
- ពង្រឹងកិច្ចសហប្រត្តិការសេដ្ឋកិច្ចជាមួយប្រទេសតំបន់ និងពិភពលោក
- ពង្រឹងសន្តិភាព សុវត្ថិភាពនិងសណ្តាប់ធ្នាប់សង្គមដើម្បីទាក់ទាញវិនិយោគទុនពីបរទេស
- បង្កើតសេដ្ឋកិច្ចទីផ្សារសេរី នឹងជំរុញការអភិវឌ្ឍធនធានមនុស្ស

❖ ការស្ថាបនាសង្គម

- វិស័យអប់រំ ៖ ប្រព័ន្ធអប់រំត្រូវបានស្តារឡើងវិញ ដោយបើកទ្វារសាលារៀនគ្រប់កម្រិតសិក្សា ដល់ឧត្តមសិក្សាទទួលសិស្សឲ្យចូលរៀនតាំងពីទីក្រុងដល់ជនបទ ធ្វើការជ្រើសរើស និងបណ្តុះបណ្តាលគ្រូបង្រៀន ជំរុញនឹងបំផុសចលនាអក្ខរកម្ម បំពេញវិជ្ជា អនុវត្តនយោបាយ « អ្នកចេះច្រើនបង្រៀនអ្នកចេះតិច អ្នកចេះតិចបង្រៀនអ្នកមិនចេះ» បញ្ជូនសិស្សនិស្សិត ទៅសិក្សានៅបរទេស នឹងអញ្ជើញគ្រូបរទេសមកបង្ហាត់បង្រៀនខ្មែរនៅក្នុងប្រទេស...
- វិស័យវប្បធម៌ ៖ បើកសេរីភាពដល់ជំនឿ សាសនា ប្រពៃណី ទំនៀមទម្លាប់ បើកទ្វារសាលា វិចិត្រសិល្បៈ និងប្រមូលផ្តុំសិល្បករ

- វិស័យសង្គមកិច្ច ៖ បង្កើតមជ្ឈមណ្ឌលកុមារកំព្រា បង្កើតសាលាបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់ជនពិការ នឹងស្ត្រីមេម៉ាយ បង្កើតច្បាប់ការពារកម្មសិទ្ធឯកជន (១៩៨៧)
- វិស័យសុខាភិបាល ៖ បើកទ្វាមន្ទីពេទ្យទទួលពិនិត្យ នឹងព្យាបាលជំងឺ បើកទ្វាសាលាបណ្តុះ បណ្តាលពេទ្យ មានមហាវិទ្យាល័យវិជ្ជាសាស្ត្រ ឱសថសាស្ត្រ ទន្តសាស្ត្រ។

៣.ចលនាតស៊ូដើម្បីរំដោះប្រទេសកម្ពុជាពីរបបប្រល័យពូជសាសន៍ « កម្ពុជាប្រជាធិបតេយ្យ» ឆ្នាំ១៩៧៥-១៩៧៩៖

- ខែមករា ឆ្នាំ១៩៧៦ លោក ហ៊ូ នឹម ចេញមុខប្រឆាំងនឹង ប៉ុល ពត
- ខែមីនា ឆ្នាំ១៩៧៦ ប្រជាជននៅចម្ការហ្លួង នឹងខេត្តសៀមរាប ទាមទារឲ្យតម្លើងកម្រិតជីវភាព នឹងឲ្យគ្រួសាររស់នៅជួបជុំគ្នា
- ឆ្នាំ១៩៧៧ ប្រជាជននៅសៀមរាប បាត់ដំបង កំពង់ធំ កំពង់ឆ្នាំង មណ្ឌលគីរី ចម្ការហ្លួង បះបោរប្រឆាំង ប៉ុល ពត
- ថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៧ លោក ហ៊ុន សែន បានភៀសខ្លួនទៅប្រទេសវៀតណាមដើម្បីស្វែងរកការគាំទ្រ នឹងបង្កើតកម្លាំងប្រឆាំងខ្មែរក្រហម
- ថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៨ មហាសន្និបាត បានសម្រេចបង្កើត « រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា» ដែលដឹកនាំដោយលោក ហេង សំរិន
- ដោយមានជំនួយកងទ័ពវៀតណាម នឹងការចូលរួមពីប្រជាជនកម្ពុជា រណសិរ្សសាមគ្គីសង្គ្រោះ ជាតិកម្ពុជា បានវាយលើកម្លាំងកងទ័ពខ្មែរក្រហមតែរយៈពេលបីសប្តាហ៍រំដោះប្រជាជនបានស្ទើទាំងស្រុងទូទាំងប្រទេស
- ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ប្រជាជនកម្ពុជាត្រូវបានរំដោះឲ្យរួចចាកផុតពីរបបប្រល័យពូជសាសន៍ ប៉ុល ពត។

៤.ពណ៌នាពីរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ៖

របបសាធារណរដ្ឋប្រជាមានិតកម្ពុជា (ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៨) មានកិច្ចការចាំបាច់ពីរគឺ ការកសាងសន្តិភាព និងការស្តារបនាជាតិឡើងវិញ

❖ អង្គការគ្រប់គ្រងសំខាន់ៗនៃរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា

របបសាធារណរដ្ឋប្រជាមានិតកម្ពុជាគ្រប់គ្រងដោយគណបក្សតែមួយគឺគណបក្សប្រជាជនបដិវត្តន៍កម្ពុជា និងអង្គការគ្រប់គ្រងសំខាន់ៗ៤គឺ ៖

- គណបក្សប្រជាជនបក្សដិវត្តន៍កម្ពុជា
- ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍ ឬក្រុមប្រឹក្សារដ្ឋមន្ត្រី
- ក្រុមប្រឹក្សារដ្ឋ
- រដ្ឋសភាជាតិ

❖ រដ្ឋអំណាចខ្មែរ

- ដំណាក់កាលដំបូង ៖ ក្រសួងសំខាន់ៗគ្របគ្រងដោយមនុស្សពីរក្រុមគឺ អ្នកតស៊ូចាស់ៗ នៅ ភូមិភាគបូព៌ា (សមមិត្ត ហេង សំរិន ,ជាស៊ីម ,ហ៊ុន សែន) នឹងអ្នករៀននៅវៀតណាមក្រោយ សន្និសីទហ្សឺណែវ ឆ្នាំ១៩៥៤ (សមមិត្ត ប៉ែន សុវណ្ណ , ចាន់ ស៊ី)
- ដំណាក់កាលបន្ទាប់ ៖ ពេលសន្តិសុខប្រទេសមានលំនឹង រដ្ឋាភិបាល ជ្រើសរើសអ្នកមានសមត្ថភាពឲ្យបម្រើក្នុងក្បាលម៉ាស៊ីនដឹកនាំរដ្ឋ។

❖ អ្នកជំនាញការ នឹងកងទ័ពវៀតណាម

- អ្នកជំនាញការវៀតណាមអមរដ្ឋខ្មែរតាំងពីថ្នាក់ក្រសួងដល់ថ្នាក់មូលដ្ឋានដើម្បីជួយពង្រឹងរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា
- កងទ័ពវៀតណាមនៅ៣សពេញផ្ទៃប្រទេសដើម្បីជួយទប់ស្កាត់ការវិលត្រឡប់មកវិញនៃរបប ប្រល័យពូជសាសន៍

❖ កិច្ចការពារជាតិ

ដើម្បីទប់ស្កាត់ការវិលត្រឡប់មកវិញរបបខ្មែរក្រហម រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាបានចាត់វិធានការដូចតទៅ៖

- បង្កើតកងសេនាជនភូមិ បង្កើតក្រុមស្ម័យការពារ ក្រុមយាមកាម ធ្វើការជ្រើសរើសកងទ័ព បង្កើតកាតព្វកិច្ចយោធា ធ្វើការហ្វឹកហាត់ក្បួនយោធាដល់សិស្សនិស្សិត មុនចូលរៀន
- លើកទ័ពវាយលុកលើខ្មែរក្រហមនារដូវប្រាំង នឹងគ្រប់គ្រងតំបន់តាមព្រំដែន
- បង្កើតកិច្ចការពារ នៅតាមព្រំដែនកម្ពុជា-ថៃ ដោយអនុវត្តផែនការ«ក៥»
- ស្វែងរកការបញ្ចប់សង្គ្រាម ។

❖ ការកសាងជាតិរដ្ឋាភិបាលបានរៀបចំកសាងជាតិ

- ការស្ថាបនាសេដ្ឋកិច្ច ៖ បញ្ហាបន្ទាន់គឺស្បៀង
  - ✓ អំពាវនាវជំនួយពីសហគមន៍អន្តរជាតិ

- ✓ បង្កើនក្រុមសាមគ្គីបង្កបង្កើនផល
- ✓ ឆ្នាំ១៩៨០ បោះពុម្ពក្រដាសប្រាក់ឲ្យចាយវាយទូទាំងប្រទេស
- ✓ ឆ្នាំ១៩៨៣-១៩៨៦ ប្តូរពីក្រុមសាមគ្គីបង្កបង្កើនផលទៅជាម្ចាស់ការទាំងស្រុង ដោយធ្វើការបែងចែកដីធ្លី នឹងឈានទៅរកកម្មសិទ្ធិឯកជន
- ✓ អនុវត្តមុខព្រួញទាំង៤នៃសេដ្ឋកិច្ច

- ការស្តាបនាសង្គម
  - ➢ វិស័យអប់រំ ៖ ប្រព័ន្ធអប់រំត្រូវបានស្តារឡើងវិញដោយ ៖
    - ▪ បើកទ្វារសាលាទទួលសិស្ស និស្សិត ឲ្យចូលរៀន
    - ▪ ធ្វើការជ្រើសរើស នឹងបណ្តុះបណ្តាលគ្រូ
    - ▪ ជំរុញចលនាអក្ខរកម្ម នឹងបំពេញវិជ្ជា
    - ▪ អនុវត្តនយោបាយ « អ្នកចេះប្រើនបង្រៀនអ្នកចេះតិច អ្នកចេះតិចបង្រៀនអ្នក មិនចេះសោះ»
    - ▪ បញ្ជូននិស្សិតទៅសិក្សានៅបរទេស
  - ➢ វិស័យវប្បធម៌
    - ▪ បើកសេរីភាពដល់ ជំនឿ សាសនា ប្រពៃណីទំនៀមម្លាប់
    - ▪ បើកទ្វារសាលាវិចិត្រសិល្បៈនឹងប្រមូលផ្តុំសិល្បករ
  - ➢ វិស័យសង្គមកិច្ច ៖ បង្កើតមជ្ឈមណ្ឌលកុមារកំព្រា បង្កើតសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់ជនពិការ នឹងស្ត្រីមេម៉ាយ បង្កើតច្បាប់ការពារកម្មសិទ្ធិឯកជន
  - ➢ វិស័យសុខាភិបាល ៖ បើកទ្វារមន្ទីពេទ្យទទួលពិនិត្យ នឹងព្យាបាលជំងឺ បើកទ្វារសាលាបណ្តុះបណ្តាលពេទ្យមានហាមាវិទ្យាល័យវេជ្ជសាស្ត្រ ឱសថសាស្ត្រ ទន្តសាស្ត្រ (មានចម្លើយត្រឹមត្រូវផ្សេងទៀត)

៧. ថ្ងៃរំដោះ ៧ មករា ១៩៧៩ បានផ្តល់អត្ថន័យជាប្រវត្តិសាស្ត្រចំពោះ កម្ពុជាដូចជា :

- ជាថ្ងៃដែលប្រជាជនកម្ពុជារួចផុតពីការសម្លាប់រង្គាលនៃរបប ប្រល័យពូជសាសន៍កម្ពុជាប្រជាធិបតេយ្យ
- ជាថ្ងៃដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ ជាថ្ងៃចាប់បដិសន្ធិ របបសាធារណរដ្ឋប្រជាមានិតកម្ពុជា

- ជាថ្ងៃដែលប្រជាជនកម្ពុជាទទួលបាននូវ សិទ្ធិសេរីភាព សិទ្ធិនៃការសម្រេចជោគវាសនាខ្លួន
- ជាការរស់រានឡើងវិញនូវវប្បធម៌ជាតិ(ជំនឿ សាសនា ប្រពៃណី ទំនៀមទម្លាប់ សិល្បៈ...)
- ជាថ្ងៃស្តារនិងកសាងប្រទេសឡើងវិញលើគ្រប់វិស័យ ស្របតាមឆន្ទៈនិងគោលបំណងប្រជាជន
- ថ្ងៃដែលកម្ពុជាឈានទៅរក ឯករាជ្យ សន្តិភាព សេរីភាព និងសុភមង្គល
- ជាថ្ងៃស្តារមុខមាត់ប្រទេសកម្ពុជាឡើងវិញ លើឆាកអន្តរជាតិ
- ជាថ្ងៃដែលបណ្តាលឲ្យមានវត្តមានកងទ័ពវៀតណាមជាថ្មីម្តង ទៀតលើទឹកដីកម្ពុជា ។

(ចម្លើយត្រឹមត្រូវផ្សេងៗទៀត)

ដែនដីខ្មែរ

ខ្មែរគ្រប់កូមិរម្យណីយយសដ្ឋាន
ខ្មែរគ្រប់ប្រាណស្វាគមន៍សាមគ្គី។
ខ្មែរគ្រប់កាយសុខចិត្តប្តូរជីវិ
ឱ!ព្រះភូមិរិទ្ធិវង្សគង្គា។
ខ្មែរបានសុខទាំងអស់គ្រប់អាត្មា
មហាក្សត្រយើងគ្រប់គ្រងផែនដី។

🕮 មេរៀនទី៦ ព្រះរាជាណាចក្រកម្ពុជាទី២ (១៩៩៣ - បច្ចុប្បន្ន)

(ដកស្រង់ចេញពីការបង្រៀនក្នុងផេកក្រសួងអប់រំ)

✍ចងក្រងឡើងដោយ ម៉ែត ជីវិន✍

✦✦✦ ✦✦ ⊙ ✦✦✦✦✦

﴿ប្រធានសំណួរ﴾

១.(២០១៤) តើសម្តេច នរោត្តម សីហនុ និងសម្តេច ហ៊ុន សែន មានតួនាទីអ្វីខ្លះក្នុងការបញ្ចប់សង្គ្រាម នៅកម្ពុជា?

២.(២០១៤) តើការដាក់ប្រាសាទព្រះវិហារចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោកមានអត្ថន័យដូចម្តេច សម្រាប់កម្ពុជា?

៣.(២០១៥) ចូរពណ៌នាពីគោលនយោបាយឈ្នះ-ឈ្នះរបស់សម្តេច ហ៊ុន សែន ក្នុងការបញ្ចប់សង្គ្រាម នៅកម្ពុជា?

៤.(២០១៥) ចូរវិភាគពីព្រះរាជាណាចក្រកម្ពុជាទី២ និងការកសាងកម្ពុជាឡើងវិញ។

៥.(២០១៧) មូលហេតុអ្វីបានជាគេចាត់ទុកថា សម្តេច នរោត្តម សីហនុ និងសម្តេច ហ៊ុន សែន ជាបិតា សន្តិភាពនៅកម្ពុជា?

៦.(២០១៧) ចូរពណ៌នាពីសមិទ្ធផលរបស់រដ្ឋាភិបាលពីឆ្នាំ ១៩៩៣ ដល់បច្ចុប្បន្ន។

៧.(២០១៨) តើអ្នកនយោបាយខ្មែរណាដែលបានបញ្ចប់សង្គ្រាមក្នុងស្រុកនៅឆ្នាំ១៩៩៨?

៨.(២០១៨) តើសន្តិភាពដែលសម្រេចបានចាប់តាំងពីឆ្នាំ១៩៩៨បាននាំមកអ្វីខ្លះសម្រាប់កម្ពុជា?

៩.(២០១៨) ចូរពណ៌នាពីដំណើរការកសាងកម្ពុជាឡើងវិញចាប់តាំងពីឆ្នាំ ១៩៩៨ មកទល់បច្ចុប្បន្ន ។

១០.(២០១៩)ចូរអ្នកពណ៌នាពីការអភិវឌ្ឍសេដ្ឋកិច្ច សង្គមនៅកម្ពុជាពីឆ្នាំ១៩៩៣ មកទល់សព្វថ្ងៃ?

១១.(២០២១)ចូរពណ៌នាពីសមិទ្ធផលសំខាន់ៗរបស់រាជរដ្ឋាភិបាលកម្ពុជា ។

១២.(២០២១)ចូរអ្នកវិភាគអំពីតួនាទីនៃសន្តិភាពក្នុងអភិវឌ្ឍប្រទេសកម្ពុជា ។

១៣.(២០២២)តើមូលហេតុអ្វីបានជាគេចាត់ទុកថាសម្តេចនរោត្តម សីហនុ និងសម្តេចហ៊ុន សែន ជាបិតាសន្តិភាពនៅកម្ពុជា ?

១៤.(២០២២)តើអ្វីទៅជាគោលនយោបាយឈ្នះ ឈ្នះ ?

អត្ថាធិប្បាយ

១.តួនាទីរបស់សម្តេចនរោត្តម សីហនុ និងសម្តេច ហ៊ុន សែន ក្នុងការបញ្ចប់សង្គ្រាមនៅកម្ពុជាមានៈ

❖ សម្តេច នរោត្តម សីហនុ

- ជាតំណាងសម្ព័ន្ធត្រីភាគី(ខ្មែរក្រហម ហ៊ុនសុិនប៊ិច រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ)
- ជាអ្នកផ្តើមគំនិត ឲ្យមានការចរចាបញ្ចប់សង្គ្រាមនៅកម្ពុជា
- ជាប្រធានក្រុមប្រឹក្សាជាន់ខ្ពស់ (SNC)
- ជាម្ចាស់ហត្ថលេខីនៃកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីសថ្ងៃទី ២៣ ខែតុលា ឆ្នាំ១៩៩១
- ជាបិតាបង្រួបបង្រួមជាតិ ជាអ្នកផ្សះផ្សាជាតិ ក្នុងវិាទនៃការដេរណ្តើមឧត្តមភាពគ្នារវាងគណបក្សហ៊ុនសុិនប៊ិច និងគណបក្សប្រជាជនកម្ពុជាក្រោយការបោះឆ្នោត(១៩៩៣) ដោយ បង្កើតឲ្យមានរដ្ឋាភិបាលចម្រុះ ដែលនាំមកនូវសន្តិភាពជូនប្រទេសជាតិ។

❖ សម្តេច ហ៊ុន សែន

- ជាតំណាងរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា
- ជាអ្នកផ្តើមគំនិតឲ្យមានការចរចាបញ្ចប់សង្គ្រាមនៅកម្ពុជា
- ជាម្ចាស់ហត្ថលេខីនៃកិច្ចព្រមព្រៀងសន្តិភាពនៅក្រុងប៉ារីសថ្ងៃទី២៣ ខែតុលាឆ្នាំ១៩៩១
- ជាអ្នកធានាអះអាងសណ្តាប់ធ្នាប់ សន្តិសុខ ក្នុងការបោះឆ្នោតឆ្នាំ១៩៩៣
- ជាអ្នកបង្រួបបង្រួមជាតិ ផ្សះផ្សាជាតិដោយធ្វើសមាហរណកម្មកងកម្លាំងខ្មែរក្រហមឲ្យចូល មករួមរស់ជាមួយរាជរដ្ឋាភិបាល តាមរយៈការអនុវត្តនយោបាយឈ្នះ-ឈ្នះ ដែលនាំសន្តិភាព ពេញលេញជូនជាតិមាតុភូមិនាឆ្នាំ១៩៩៨ (២៩,១២,១៩៩៨)។

២.ការដាក់ប្រាសាទព្រះវិហារចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោកមានអត្ថន័យសម្រាប់កម្ពុជាៈ

- ជាមោទកភាពជាតិខ្មែរ
- រក្សាបូរណភាពទឹកដី
- បង្ហាញពីអត្តសញ្ញាណខ្មែរលើឆាកអន្តរជាតិ
- បង្ហាញពីភាពប៉ិនប្រសប់ ការច្នៃប្រឌិត ទេពកោសល្យដ៏ល្អឯករបស់បុព្វបុរសខ្មែរ ដែលផ្សារភ្ជាប់ ទៅនឹងអាទិទេព
- បង្ហាញពីភាពសំបូរបែបនៃរចនាបថ ស្ថាបត្យកម្មរបស់បុព្វបុរសខ្មែរ
- បង្ហាញសារជាថ្មីថាសម្បត្តិវប្បធម៌ទាំងនេះពិតជាមរតកប្រវត្តិសាស្ត្ររបស់ជូនតាខ្មែរ

- បង្ហាញពីវិសាលភាពទឹកដីខ្មែរ និងអំណាចព្រះរាជាក្នុងសម័យអង្គរ
- ទទួលបាននូវកិច្ចការពារពីសំណាក់សមាគមអន្តរជាតិ
- ទទួលបានមូលនិធិ បច្ចេកទេសក្នុងការ ជួសជុល អភិរក្ស ថែរក្សាសម្បត្តិវប្បធម៌មនុស្សជាតិ
- កំណើនភ្ញៀវទេសចរ ដែលបង្កើនការងារនិងប្រាក់ចំណូលដល់ប្រជាជន
- កំណើនសេដ្ឋកិច្ច តាមរយៈកំណើនភ្ញៀវទេសចរ
- បណ្តុះមនសិការស្នេហាជាតិ ស្រឡាញ់ ការពារ ថែរក្សាសម្បត្តិវប្បធម៌របស់មនុស្សជាតិ ។ (ទិដ្ឋភាពផ្សេងៗទៀត)

៣.គោលនយោបាយឈ្នះ-ឈ្នះរបស់សម្តេច ហ៊ុន សែន ក្នុងការបញ្ចប់សង្គ្រាមនៅកម្ពុជា៖

❖ វិស័យនយោបាយ

- ឆ្នាំ ១៩៩៨ សមាហរណកម្មកងទ័ពខ្មែរក្រហម ជាមួយកងទ័ពរាជរដ្ឋាភិបាលធ្វើឲ្យកងទ័ពមានការឯកភាពដើម្បីស្តារនិងកសាងប្រទេសជាតិ
- ក្រោយពីកងកម្លាំងខ្មែរក្រហមដួលរលំ នៅតាមព្រំដែនមានសុវត្ថិភាព និងមានការអភិវឌ្ឍ
- កម្ទេចអង្គការចាត់តាំងខ្មែរក្រហម
- មាតុភូមិនិវត្តន៍របស់ជនភៀសខ្លួនតាមព្រំដែន បែងចែកដីធ្លី កាន់កាប់ជាកម្មសិទ្ធិដល់បងប្អូនភៀសខ្លួន (អតីតខ្មែរក្រហម)
- បងប្អូនខ្មែរក្រហមទទួលបានតួនាទី និងបុណ្យសក្តិដែលធ្លាប់មានពីមុន

❖ វិស័យសង្គម

- ឆ្នាំ ១៩៩៨ មកដល់បច្ចុប្បន្ន ប្រទេសកម្ពុជាមានសុវត្ថិភាព និងសន្តិភាពពេញលេញ
- ធ្វើឲ្យមានឯកភាពជាតិ និងការបង្រួបបង្រួមជាតិ
- ធ្វើឲ្យមានសមិទ្ធផលច្រើន

❖ វិស័យសេដ្ឋកិច្ច ៖ កំណើនទិន្នផលកសិកម្ម ឧស្សាហកម្ម កំណើនអ្នកវិនិយោគ កំណើនភ្ញៀវទេសចរ មានទំនាក់ទំនងទីផ្សារក្នុងតំបន់ និងក្រៅតំបន់

❖ គមនាគមន៍ ៖ ការកសាងផ្លូវថ្នល់ ផ្លូវដែក ស្ពាន កំពង់ផែ អាកាសយានដ្ឋាន

❖ វិស័យអប់រំ ៖ កំណែទម្រង់ស៊ីជម្រៅលើវិស័យអប់រំ សាងសង់សាលារៀន បណ្តុះបណ្តាលធនធានមនុស្ស...

- សាសនា ៖ សុខដុមនីយកម្មខាងសាសនា
- សុខាភិបាល ៖ សាងសង់មន្ទីពេទ្យ មណ្ឌលសុខភាព

(ទិដ្ឋភាពផ្សេងទៀត)

៤.វិភាគពីព្រះរាជាណាចក្រកម្ពុជាទី២ និងការកសាងកម្ពុជាឡើងវិញ

- ព្រះរាជាណាចក្រកម្ពុជាទី២
  - កើតនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ដែលមានព្រះមហាក្សត្រសោយរាជ្យ
  - មានរដ្ឋធម្មនុញ្ញថ្មី សេរីពហុក្ស
  - មានរដ្ឋាភិបាលស្របច្បាប់មួយ
  - ព្រះរាជាណាចក្រកម្ពុជាទី២ កើតឡើងតាមរយៈការបោះឆ្នោតនៅថ្ងៃទី២៣-២៨ ខែឧសភា ឆ្នាំ១៩៩៣ រៀបចំដោយអង្គការសហប្រជាជាតិ ដែលនាំឲ្យមានការរៀបចំរដ្ឋាភិបាល ដោយសម្តេច នរោត្តម រណឫទ្ធិ និងសម្តេច ហ៊ុន សែន ជា នាយករដ្ឋមន្ត្រី
  - ព្រះរាជាណាចក្រកម្ពុជាទី២ គឺចាប់ពីឆ្នាំ១៩៩៣ រហូតដល់បច្ចុប្បន្ន
  - ព្រះរាជាណាចក្រកម្ពុជាទី២ បានរៀបចំការបោះឆ្នោតជាសកលដោយសេរីក្នុងការជ្រើសរើស តំណាងរាស្ត្រ
- ការស្តាបនាកម្ពុជាឡើងវិញ
  - វិស័យនយោបាយ ៖ ធ្វើកំណែទម្រង់រដ្ឋាភិបាលសាធារណៈ កងទ័ពនគរបាលជាតិ សមភាព យេនឌ័រ
  - វិស័យសេដ្ឋកិច្ច
    - ស្តារវិស័យកសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម
    - បង្កើតឲ្យមានប្រព័ន្ធសដ្ឋកិច្ចទីផ្សារ ផ្តល់កម្មសិទ្ធឯកជន
    - ធ្វើកំណែទម្រង់ហេដ្ឋារចនាសម្ព័ន្ធជាតិ
  - វិស័យអប់រំ វប្បធម៌ ៖ បង្កើតសាលារៀនគ្រប់កម្រិត វត្តអារាម សេរីភាព ខាងជំនឿសាសនា
  - វិស័យសង្គម ៖ ផ្តល់សេរីភាពដល់ប្រជាពលរដ្ឋ

(ទិដ្ឋភាពផ្សេងៗទៀត)

៥.១៣.បានជាគេចាត់ទុកថា សម្តេច នរោត្តម សីហនុ និង សម្តេច ហ៊ុន សែន ជាបិតាសន្តិភាពនៅកម្ពុជាពីព្រោះ ៖

❖ សម្តេច នរោត្តម សីហនុ

- ជាអ្នកផ្តើមគំនិតឲ្យមានការចរចារកសន្តិភាព
- ជាប្រធានក្រុមប្រឹក្សាជាន់ខ្ពស់ (SNC)
- ជាអ្នកចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីស (២៣ តុលា ១៩៩១)
- ជាអ្នកបង្រួបបង្រួមជាតិ ជាអ្នកផ្សះផ្សាជាតិ ដោយធ្វើការផ្សះផ្សារវិបត្តិក្រោយបោះឆ្នោតឆ្នាំ ១៩៩៣ ដែលកើតចេញពីការដេរណ្តើមឥទ្ធិពលគ្នារវាងគណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សប្រជាជនកម្ពុជា បង្កើតបានជារដ្ឋាភិបាលចម្រុះ
- ជាអ្នកផ្សះផ្សារវិបត្តិនយោបាយក្រោយការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រឆ្នាំ ១៩៩៨ ឆ្នាំ២០០៣...។

(មតិផ្សេងៗទៀត)

❖ សម្តេច ហ៊ុន សែន

- ជាអ្នកផ្តើមគំនិតឲ្យមានការចរចាបញ្ចប់រកសន្តិភាព
- ជាអ្នកចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពនៅក្រុងប៉ារីស (២៣ តុលា ១៩៩១)
- ជាអ្នកធានាអះអាងសណ្តាប់ធ្នាប់ សន្តិសុខ ក្នុងការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រថ្ងៃទី ២៣-២៨ ខែឧសភា ឆ្នាំ១៩៩៣
- ជាអ្នកផ្សះផ្សារវិបត្តិក្រោយការបោះឆ្នោតឆ្នាំ១៩៩៣ ឆ្នាំ១៩៩៨ ឆ្នាំ២០០៣ ឆ្នាំ២០០៨ និង ឆ្នាំ២០១៣
- ជាអ្នកបញ្ចប់សង្គ្រាមស៊ីវិលទាំងស្រុងនៅកម្ពុជា ដោយអនុវត្តនយោបាយឈ្នះ-ឈ្នះ (យុទ្ធសាស្ត្រឈ្នះ-ឈ្នះ)ដែលបានរំលាយអង្គការចាត់តាំងខ្មែរក្រហម ធ្វើឲ្យសមាហរណកម្ម កងទ័ពខ្មែរក្រហម ឲ្យមករួមរស់ជាមួយរដ្ឋាភិបាលនៅឆ្នាំ១៩៩៨ នាំមកនូវសន្តិភាពរីកចម្រើន និងវិបុលភាពនៅកម្ពុជា។

(មតិផ្សេងៗទៀត)

៦.១១.ពណ៌នាពីសមិទ្ធផលរបស់រាជរដ្ឋាភិបាលពីឆ្នាំ១៩៩៣ ដល់បច្ចុប្បន្ន ៖

❖ វិស័យនយោបាយ

- នយោបាយក្នុងប្រទេស
  - ការអនុវត្តនយោបាយ ឈ្នះ-ឈ្នះ បានរំលាយអង្គការចាត់តាំងខ្មែរក្រហម និងធ្វើសមាហរណកម្មកងកម្លាំងខ្មែរក្រហមឲ្យចូលមករួមរស់ជាមួយរាជរដ្ឋាភិបាលនៅឆ្នាំ ១៩៩៨ ដោយនាំមកនូវសន្តិភាពរបូនីយកម្មនៅកម្ពុជា
  - រៀបចំការបោះឆ្នោតដោយខ្លួនឯង ប្រកបដោយជោគជ័យទៅតាមលទ្ធិប្រជាធិបតេយ្យ
  - កំណែទម្រង់លើគ្រប់វិស័យ (រដ្ឋបាល តុលាការ កងកម្លាំងប្រដាប់អាវុធ អប់រំ...)
  - កម្ពុជាកាន់យកលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស
  - រាជរដ្ឋាភិបាល បានអនុវត្តនយោបាយ យុទ្ធសាស្ត្រត្រីកោណ និងយុទ្ធសាស្ត្រចតុកោណ
- នយោបាយក្រៅប្រទេស
  - ឆ្នាំ១៩៩៩ កម្ពុជាបានចូលជាសមាជិកអាស៊ាន (ASEAN)
  - ឆ្នាំ២០០៤ កម្ពុជាចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក
  - ឆ្នាំ២០០២ ឆ្នាំ២០១២ និងឆ្នាំ២០២២ កម្ពុជាធ្វើជាប្រធានអាស៊ាន
  - កម្ពុជាមានទំនាក់ទំនងល្អជាមួយប្រទេសក្នុងតំបន់ និងពិភពលោក
    (មតិផ្សេងៗទៀត)

❖ វិស័យសេដ្ឋកិច្ច

សេដ្ឋកិច្ចកម្ពុជាមានកំណើនជារៀងរាល់ឆ្នាំដែលធ្វើឲ្យប្រជាជនមានជីវភាពធូរធារ ៖

- កសិកម្ម ៖ មានកំណើនទិន្នផល ព្រោះសំបូរទីផ្សារ
- ឧស្សាហកម្ម ៖ កំណើនរោងចក្រឧស្សាហកម្ម សហគ្រាស បង្កើនការងារដល់ប្រជាជន
- ពាណិជ្ជកម្ម ៖ សំបូរវិនិយោគិន សំបូរទីផ្សារ
- ទេសចរណ៍ ៖ កំណើនភ្ញៀវទេសចរដែលបង្កើនការងារ និងប្រាក់ចំណូលដល់ប្រជាជន
- ហិរញ្ញវត្ថុ ៖ មានស្ថិរភាពអត្រាប្តូរប្រាក់
- គមនាគមន៍ ៖ សាងសង់ផ្លូវជាតិ ផ្លូវជែក ស្ពាន អាកាសយានដ្ឋាន កំពង់ផែ ដោយបំពាក់ ប្រព័ន្ធទឹក ភ្លើង ពីទីក្រុង ដល់ជនបទ
  (មានមតិផ្សេងទៀត)

❖ វិស័យសង្គម វប្បធម៌

- អប់រំសិក្សាធិការ ៖ បង្កើតសាលារៀនគ្រប់កម្រិត គ្រប់ទីកន្លែង នឹងមានកំណើនធនធានមនុស្ស
- វប្បធម៌ ៖ ធ្វើការគាស់កកាយវប្បធម៌ឲ្យរស់ឡើងវិញ និងដាក់បញ្ចូលសម្បត្តិវប្បធម៌កម្ពុជា ជាបេតិកភណ្ឌពិភពលោក
- សាសនា ៖ សុខដុមនីយកម្មក្នុងសាសនា
- សុខាភិបាល ៖ បង្កើតមន្ទីពេទ្យ មណ្ឌលសុខភាព ពីទីក្រុងដល់ជនបទ
- សិទ្ធិ ៖ ផ្តល់សិទ្ធិដល់ស្ត្រី (សមភាពយេនឌ័រ) ប្រជាជនមានការយល់ដឹងពីច្បាប់សណ្តាប់ធ្នាប់ល្អ ។

(មតិផ្សេងៗទៀត)

៧.អ្នកនយោបាយខ្មែរដែលបានបញ្ចប់សង្គ្រាមក្នុងស្រុកនៅឆ្នាំ ១៩៩៨ គឺ សម្តេច ហ៊ុន សែន ។

៨.សន្តិភាពដែលសម្រេចបានចាប់តាំងពីឆ្នាំ ១៩៩៨ បាននាំមកឲ្យកម្ពុជានូវការអភិវឌ្ឍជាតិលើគ្រប់វិស័យដូចជា ៖

❖ វិស័យនយោបាយ

➢ នយោបាយក្នុងប្រទេស

- កម្ពុជាបានសុខសន្តិភាព និងមានស្ថិរភាពនយោបាយ
- មានការបោះឆ្នោតជ្រើសរើសមេដឹកនាំតាមបែបប្រជាធិបតេយ្យ

➢ នយោបាយក្រៅប្រទេស

- ឆ្នាំ១៩៩៩ កម្ពុជាចូលជាសមាជិកអាស៊ាន (ASEAN)
- ឆ្នាំ២០០៤ កម្ពុជាចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក
- ឆ្នាំ២០០២ ឆ្នាំ២០១២ និងឆ្នាំ២០២២ កម្ពុជាធ្វើជាប្រធានអាស៊ាន
- កម្ពុជាមានទំនាក់ទំនងល្អជាមួយប្រទេសក្នុងតំបន់ និងពិភពលោក

(មានមតិផ្សេងៗទៀត)

❖ វិស័យសេដ្ឋកិច្ច

សេដ្ឋកិច្ចកម្ពុជាមានកំណើនជារៀងរាល់ឆ្នាំដែលធ្វើឲ្យប្រជាជនមានជីវភាពធូធារ ៖

- កសិកម្ម ៖ មានកំណើនទិន្នផល ព្រោះសំបូរទីផ្សារ

- ឧស្សាហកម្ម ៖ កំណើនរោងចក្រឧស្សាហកម្ម សហគ្រាស បង្កើនការងារដល់ប្រជាជន
- ពាណិជ្ជកម្ម ៖ សំបូរវិនិយោគិន សំបូរទីផ្សារ
- ទេសចរណ៍ ៖ កំណើនភ្ញៀវទេសចរ ដែលបង្កើនការងារ និងប្រាក់ចំណូលដល់ប្រជាជន
- ហិរញ្ញវត្ថុ ៖ មានស្ថិរភាពអត្រាប្តូរប្រាក់
- គមនាគមន៍ ៖ សាងសង់ផ្លូវជាតិ ផ្លូវដែក ស្ពាន អាកាសយានដ្ឋាន កំពង់ផែ ដោយបំពាក់ ប្រព័ន្ធទឹក ភ្លើង ពីទីក្រុង ដល់ជនបទ
(មានមតិផ្សេងទៀត)

❖ វិស័យសង្គម វប្បធម៌

- អប់រំសិក្សាធិការ ៖ បង្កើតសាលារៀនគ្រប់កម្រិត គ្រប់ទីកន្លែង និងមានកំណើនធនធានមនុស្ស
- វប្បធម៌ ៖ ធ្វើការគាស់កកាយវប្បធម៌ឲ្យរស់ឡើងវិញ និងដាក់បញ្ចូលសម្បត្តិវប្បធម៌កម្ពុជាជាបេតិកភណ្ឌពិភពលោក
- សាសនា៖ សុខដុមនីយកម្មក្នុងសាសនា
- សុខាភិបាល ៖ បង្កើតមន្ទីពេទ្យ មណ្ឌលសុខភាព ពីទីក្រុងដល់ជនបទ
- សិទ្ធិ ៖ ផ្តល់សិទ្ធិដល់ស្ត្រី (សមភាពយេនឌ័រ) ប្រជាជនមានការយល់ដឹងពីច្បាប់សណ្តាប់ធ្នាប់ល្អ
(មតិផ្សេងៗទៀត)

៩.ពណ៌នាពីដំណើរការកសាងកម្ពុជាឡើងវិញចាប់ពីឆ្នាំ១៩៩៨ មកទល់បច្ចុប្បន្ន ៖

❖ វិស័យនយោបាយ

- ឆ្នាំ១៩៩៨ មានការធ្វើសមាហរណកម្មកងទ័ពខ្មែរក្រហម និងកងទ័ពរាជរដ្ឋាភិបាលធ្វើឲ្យ មានកម្លាំងឯកភាពគ្នា ដើម្បីស្តារប្រទេសនិងកសាងប្រទេសកម្ពុជាឡើងវិញ
- ក្រោយពីកងទ័ពខ្មែរក្រហមដួលរលំ នៅតាមព្រំដែនមានសុវត្ថិភាព និងការអភិវឌ្ឍ
- ការកម្ទេចរចនាសម្ព័ន្ធអង្គការចាត់តាំងខ្មែរក្រហម
- ការបែងចែកដីធ្លីកាន់កាប់ជាកម្មសិទ្ធិដល់បងប្អូនអតីតខ្មែរក្រហម
- បងប្អូនខ្មែរក្រហមបានទទួលតួនាទី និងបុណ្យសក្តិដែលធ្លាប់មានពីមុន
(មានមតិផ្សេងៗទៀត)

- វិស័យសេដ្ឋកិច្ច
  - ធ្វើទំនាក់ទំនងពាណិជ្ជកម្មអន្តរជាតិជាមួយអាស៊ាន ប្រទេសក្រៅតំបន់ជាពិសេសជាមួយប្រទេសមហាអំណាចធំៗលើពិភពលោក
  - កសិកម្មមានការរីកចម្រើន ដោយរដ្ឋាភិបាលយកចិត្តទុកដាក់ក្នុងការបង្កើតប្រព័ន្ធធារាសាស្ត្រ និងបង្កាត់ពូជ...
  - អនុវត្តសេដ្ឋកិច្ចទីផ្សារសេរី កម្ពុជាក្លាយជាកន្លែងវិនិយោគទុនដ៏ទាក់ទាញ
  - វិស័យឧស្សាហកម្មមានការរីកចម្រើន បង្កើតរោងចក្រសហគ្រាសតូចធំជាច្រើន ពិសេសរោង ចក្រវាយនភ័ណ្ឌសម្រាប់បង្កើនការងារដល់ប្រជាពលរដ្ឋជៀសវៀងការធ្វើចំណាកស្រុក និង កាត់បន្ថយភាពក្រីក
  - វិស័យទេសចរណ៍ វប្បធម៌ មានប្រាសាទបុរាណជាច្រើន និងទេសចរណ៍ធម្មជាតិសម្រាប់ទាក់ទាញភ្ញៀវជាតិ និងអន្តរជាតិ

    (មានមតិផ្សេងៗទៀត)
- វិស័យសង្គម
  - ឆ្នាំ១៩៩៨ មកដល់បច្ចុប្បន្នមានសុវត្ថិភាព និងសន្តិភាពពេញលេញ
  - ធ្វើឲ្យមានសមិទ្ធផលជាច្រើនកើនឡើងដូចជា ៖
    - កសាងសាលារៀនពីមតេយ្យសិក្សារហូតដល់សាកលវិទ្យាល័យ
    - កសាងមន្ទីរពេទ្យ ផ្លូវថ្នល់ ស្ពាន ស្ពានអាកាស ប្រព័ន្ធធារាសាស្ត្រ ជាពិសេសសេដ្ឋកិច្ចមានការរីកចម្រើន និយាយរួមគឺមានការរីកចម្រើនលើគ្រប់វិស័យ
- វប្បធម៌
  - ការបង្កើតពហុកីឡាដ្ឋាន បណ្តុះបណ្តាលជំនាញ ធ្វើឲ្យកីឡាករមានសមត្ថភាពក្នុងការប្រកួត ប្រជែងលើឆាកអន្តរជាតិ
  - អភិរក្សសម្បត្តិវប្បធម៌ រូបិយ អរូបិយ ព្រមទាំងដាក់បញ្ចូលសម្បត្តិវប្បធម៌ជាបេតិកភណ្ឌពិភព លោក (រមណីយដ្ឋានអង្គរ ប្រាសាទព្រះវិហារ ប្រាសាទសំបូរព្រៃគុក រចាំព្រះរាជទ្រព្យ...)

    (មានមតិផ្សេងៗទៀត)
- ការអនុវត្តច្បាប់

- មានការទប់ស្កាត់ការជួញដូរមនុស្ស ការជួញដូរគ្រឿងញៀន និងអំពើកេរ្តកម្ម
- មានសេរីភាពផ្នែកសារព័ត៌មាន និងអនុញ្ញាតឲ្យមានសិទ្ធិសេរីភាពក្នុងការបង្កើតអង្គការសង្គមស៊ីវិល
- សមភាពយេនឌ័រ (ផ្តល់សិទ្ធិដល់ស្ត្រី) ។

(មានមតិផ្សេងៗទៀត)

១០.ការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកម្ពុជាឆ្នាំ១៩៩៣ មកទល់សព្វថ្ងៃមានដូចជា ៖

❖ នយោបាយឈ្នះ-ឈ្នះ

នយោបាយឈ្នះ-ឈ្នះ បានធ្វើឲ្យរាជរដ្ឋាភិបាលដាក់ចេញនូវ យុទ្ធសាស្ត្រត្រីកោណ និង យុទ្ធសាស្ត្រចតុកោណ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម តាមរយៈកំណែទម្រង់សាធារណៈ វិមជ្ឈការ កំណែទម្រង់ច្បាប់ ប្រព័ន្ធតុលាការ សមភាពយេនឌ័រ ហិរញ្ញវត្ថុសាធារណៈ លុបបំបាត់ អំពើពុករលួយ ការគ្រប់គ្រងធនធានធម្មជាតិ ប្រកបដោយចីរភាព

❖ វិស័យសេដ្ឋកិច្ច

- បង្កើនទំនាក់ទំនងពាណិជ្ជកម្មអន្តរជាតិជាមួយអាស៊ាន និងមហាអំណាចធំៗលើពិភពលោក
- កសិកម្មមានការរីកចម្រើន ដោយរដ្ឋាភិបាលយកចិត្តទុកដាក់ក្នុងការបង្កើតប្រព័ន្ធធារាសាស្ត្រ ការបង្កាត់ពូជ ការប្រើប្រាស់ដី
- អនុវត្តសេដ្ឋកិច្ចទីផ្សារសេរី កម្ពុជាក្លាយជាកន្លែងវិនិយោគទុនដ៏ទាក់ទាញ
- ជំរុញ និងលើកទឹកចិត្តការវិនិយោគពីឯកជន បង្កើនទុនពីបរទេស
- ជំរុញវិស័យឧស្សាហកម្មមានការរីកចម្រើន ផ្នែករោងចក្រសហគ្រាសតូចធំជាច្រើនពិសេស រោងចក្រវាយនភ័ណ្ឌសម្រាប់បង្កើនការងារដល់ប្រជាពលរដ្ឋជៀសវៀងការធ្វើចំណាកស្រុក និងកាត់បន្ថយភាពក្រីក
- ជំរុញឲ្យមានការយកចិត្តទុកដាក់លើ វិស័យទេសចរណ៍ វប្បធម៌ និងទេសចរណ៍ធម្មជាតិសម្រាប់ទាក់ទាញភ្ញៀវជាតិ និងអន្តរជាតិ
- ធ្វើឲ្យអត្រាប្តូរប្រាក់មានស្ថិរភាព
- ចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក (២០០៤)

- ❖ វិស័យសង្គម
  - ឆ្នាំ១៩៩៨ មកដល់បច្ចុប្បន្នរាជរដ្ឋាភិបាលបានរៀបចំសណ្តាប់ធ្នាប់សង្គម រក្សាសន្តិសុខសុវត្ថិភាព និងមានសន្តិភាពពេញលេញ
  - ធ្វើឲ្យមានសមិទ្ធផលជាច្រើនកើនឡើងដូចជា ៖
    - កសាងសាលារៀនពីមតេយ្យសិក្សារហូតដល់សាកលវិទ្យាល័យ
    - កសាងមន្ទីពេទ្យ ផ្លូវថ្នល់ ស្ពាន ស្ពានអាកាស ប្រព័ន្ធធារាសាស្ត្រ ជាពិសេសសេដ្ឋកិច្ចមានការរីកចម្រើន
    - ប្រជាជនមានជីវភាពកាន់តែប្រសើរ
- ❖ ការអនុវត្តច្បាប់
  - មានការទប់ស្កាត់ការជួញដូរមនុស្ស ការជួញដូគ្រឿងញៀន និងអំពើកេរ្តកម្ម
  - មានសេរីភាពផ្នែកសារព័ត៌មាន និងអនុញ្ញាតឲ្យមានសិទ្ធិសេរីភាពក្នុងការបង្កើតអង្គការ សង្គមស៊ីវិល
  - សមភាពយេនឌ័រ (ផ្តល់សិទ្ធិដល់ស្ត្រី)។

    (មានមតិផ្សេងៗទៀត)

១២.សន្តិភាពបានដើរតួនាទីយ៉ាងសំខាន់ ក្នុងការអភិវឌ្ឍប្រទេសកម្ពុជាលើគ្រប់វិស័យដូចតទៅ៖

- ❖ វិស័យនយោបាយ
  - មានការរួបរួមគ្នាដើម្បីអភិវឌ្ឍប្រទេស
  - មានទំនាក់ទំនងល្អជាមួយបរទេស ផ្នែកការទូត សេដ្ឋកិច្ច...
  - ធ្វើឱ្យមានសន្តិភាព (សន្តិការវិបនីយកម្ម) និងមានស្ថិរភាព នយោបាយ
  - ធ្វើឱ្យកម្ពុជារៀបចំការបោះឆ្នោតដោយខ្លួនឯង ក្នុងការជ្រើសរើសមេដឹកនាំតាមបែបប្រជាធិបតេយ្យ
  - សន្តិភាពបាននាំមកនូវឯករាជ្យ អធិបតេយ្យភាព និងបូរណភាពទឹកដីពិតប្រាកដ
  - កម្ពុជា អាចជាសមាជិកអង្គការ ស្ថាប័នអន្តរជាតិ(អាស៊ាន WTO...) និងបានក្លាយជាប្រធានអាស៊ានវិលជុំដោយពុំអាកខាន នៅឆ្នាំ២០០២, ២០១២, ២០២២។

    (ចម្លើយត្រឹមត្រូវផ្សេងទៀត)
- ❖ វិស័យសេដ្ឋកិច្ច

- ជំរុញវិស័យកសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម ទេសចរណ៍ឱ្យអភិវឌ្ឍ
- ងាយស្រួលក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធគ្រប់បែបយ៉ាង
- មានកំណើនការវិនិយោគពីឯកជន បង្កើនទុនពីបរទេស បង្កើន ការងារដល់ប្រជាពលរដ្ឋ ចៀសវាងការធ្វើចំណាកស្រុក និងកាត់ បន្ថយភាពក្រីក្រ
- មានទំនាក់ទំនងពាណិជ្ជកម្មអន្តរជាតិជាមួយអាស៊ាន និងមហា អំណាចធំៗលើពិភពលោក
- មានកំណើនភ្ញៀវទេសចរជាតិ និងអន្តរជាតិ ដែលបង្កើនការងារ និងប្រាក់ចំណូលជូនប្រជាជន
- កសាងហេដ្ឋារចនាសម្ព័ន្ធមានផ្លូវជាតិ ផ្លូវដែក ស្ពានស្ពានអាកាស អាកាសយានដ្ឋាន កំពង់ផែ ដោយបំពាក់ប្រព័ន្ធទឹក ភ្លើង ពីទីក្រុង ដល់ជនបទ ។

(ចម្លើយត្រឹមត្រូវផ្សេងទៀត)

❖ វិស័យសង្គម

- មានការទប់ស្កាត់សង្គ្រាម និងការខ្វែងគំនិតគ្នាក្នុងសង្គម
- លើកស្ទួយការគោរពសិទ្ធិមនុស្ស សេរីភាពគ្រប់បែបយ៉ាង ក្នុង សង្គមប្រជាធិបតេយ្យ
- ទប់ស្កាត់អំពើពុករលួយ
- ធ្វើឱ្យរដ្ឋមានលទ្ធភាពសម្រេចផែនការនានាតាមការកំណត់
- ជួយឱ្យមានសន្តិភាព និងសន្តិសុខសង្គម
- ជាមាគ៌ានាំសង្គមមានការអភិវឌ្ឍជាចីរភាព ។

(ចម្លើយត្រឹមត្រូវផ្សេងទៀត)

១៤.គោលនយោបាយឈ្នះ ឈ្នះ ជា ៖

ក. **និយមន័យ** គោលនយោបាយឈ្នះ ឈ្នះ ជាយុទ្ធសាស្ត្រ សម្រាប់បញ្ចប់សង្គ្រាមផ្ទៃក្នុង និងស្វែករកសន្តិភាពនៅកម្ពុជា។

ខ. **សមិទ្ធផលគោលនយោបាយឈ្នះ ឈ្នះ ៖**

❖ វិស័យនយោបាយ

- ឆ្នាំ១៩៩៨ សមាហរណកម្មកងទ័ពខ្មែរក្រហម ជាមួយកងទ័ពរាជរដ្ឋាភិបាល ធ្វើឱ្យកងទ័ពមាន ការឯកភាព ដើម្បីស្តារនិងកសាងប្រទេសជាតិ

- ក្រោយពីកងកម្លាំងខ្មែរក្រហមដួលរលំ នៅតាមព្រំ ដែនមានសុវត្ថិភាព និងមានការអភិវឌ្ឍ
- កម្ទេចអង្គការចាត់តាំងខ្មែរក្រហម
- មាតុភូមិនិវត្តន៍របស់ជនភៀសខ្លួនតាមព្រំដែន
- បែងចែកដីធ្លី កាន់កាប់ជាកម្មសិទ្ធិដល់បងប្អូន ភៀសខ្លួន (អតីតខ្មែរក្រហម)
- បងប្អូនខ្មែរក្រហមទទួលបានតួនាទី និងបុណ្យ សក្តិដែលធ្លាប់មានពីមុន។

❖ ផ្នែកសង្គម

- ឆ្នាំ១៩៩៨-បច្ចុប្បន្ន ប្រទេសកម្ពុជាមានសុវត្ថិភាព និងសន្តិភាពពេញលេញ
- ធ្វើឲ្យមានឯកភាពជាតិ និងការបង្រួបបង្រួមជាតិ
- ធ្វើឲ្យមានសមិទ្ធផលច្រើន
- វិស័យសេដ្ឋកិច្ច កំណើនទិន្នផលកសិកម្ម ឧស្សាហកម្ម កំណើនអ្នកវិនិយោគ កំណើនភ្ញៀវ ទេសចរ មានទំនាក់ទំនងទីផ្សារក្នុងតំបន់ និងក្រៅ តំបន់
- គមនាគមន៍ ការកសាងផ្លូវថ្នល់ ផ្លូវដែក ស្ពាន កំពង់ផែ អាកាសយានដ្ឋាន
- វិស័យអប់រំ កំណែទម្រង់ស៊ីជម្រៅលើវិស័យអប់រំ សាងសង់សាលារៀនបណ្តុះបណ្តាលធនធាន មនុស្ស...
- សាសនា សុខដុមនីយកម្មខាងសាសនា
- សុខាភិបាល សាងសង់មន្ទីរពេទ្យ មណ្ឌលសុខភាព

(ទិដ្ឋភាពផ្សេងៗទៀត)

ប្រវត្តិសាស្ត្រប្រទេសកម្ពុជា

(ដកស្រង់ចេញពីការបង្រៀនក្នុងផេកក្រសួងអប់រំ)

ចងក្រងឡើងដោយ ម៉ែត ជីវិន

✦✦✦ ✦✦ ⊙ ✦✦✦✦✦

ប្រធានសំណួរ

១.(២០១៤) តើប្រាសាទអង្គរវត្តបានសាងសង់នៅក្នុងរជ្ជកាលនៃព្រះមហាក្សត្រអង្គណា?

២.(២០១៤) តើព្រះបាទជ័យវរ្ម័នទី៧ បានធ្វើអ្វីខ្លះនៅក្នុងប្រវត្តិសាស្ត្រខ្មែរ?

៣.(២០១៤) ចូររៀបរាប់ពីព្រឹត្តិការណ៍សំខាន់ៗនៃប្រវត្តិសាស្ត្រកម្ពុជា នៅសតវត្សទី២០ ។

៤.(២០១៥) ចូរវិភាគពីតម្លៃសន្តិភាព ដែលកម្ពុជាទទួលបាន សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ។

៥.(២០១៥) ចូរបកស្រាយពីតួនាទីនៃ «វប្បធម៌សន្ធនា» នៅក្នុងសង្គមប្រជាធិបតេយ្យ ។

៦.(២០១៥) ចូរវិភាគពីតួនាទីព្រះពុទ្ធសាសនានៅក្នុងសង្គមកម្ពុជា។

៧.(២០១៦) អ្នកប្រាជ្ញខ្មែរឈ្មោះអ្វីដែលបានរៀបចំវចនានុក្រមខ្មែរ?

អត្ថាកំណែ

១. ប្រាសាទអង្គរវត្តត្រូវបានសាងសង់នៅក្នុងរជ្ជកាល ព្រះបាទសូរ្យវរ្ម័នទី២ ។

២.ស្នាព្រះហស្តព្រះបាទជ័យវរ្ម័នទី៧ មានដូចជា ៖

- រំដោះប្រទេសកម្ពុជាឲ្យរួចផុតពីការឈ្លានពានរបស់ពួកចាម (១១៧៧-១១៨១)
- កសាងក្រុងអង្គរធំ(អង្គរទី៤)
- សាងសង់មន្ទីរពេទ្យ និងធម្មសាលា
- សាងសង់ប្រាសាទជាច្រើនដូចជា ប្រាសាទបាយ័ន ប្រាសាទបន្ទាយឆ្មារ ប្រាសាទកីម៉ែ...
- សាងសង់ហេដ្ឋារចនាសម្ព័ន្ធ ផ្លូវ ស្ពាន...
- ពង្រីកអំណាច និងទឹកដីចក្រភពខ្មែរឲ្យធំទូលាយ
- លើកតម្កើងព្រះពុទ្ធសាសនាមហាយាន
- លើកស្ទួយអារ្យធម៌ខ្មែរឲ្យល្បីរន្ទឺនៅទ្វីបអាស៊ី វប្បធម៌ខ្មែរឈានដល់កំពូល
- ព្រះអង្គជាបិតាជាតិខ្មែរ

៣.ព្រឹត្តិការណ៍សំខាន់ៗនៃប្រវត្តិសាស្ត្រកម្ពុជា នៅក្នុងសតវត្សទី២០ មានដូចជា ៖

- សម័យអាណាព្យាបាល
  - ឆ្នាំ១៩០៤ សៀមប្រគល់ទឹកដីខ្មែរ ត្រាត ម្លូព្រៃ ទន្លេពៅ និងស្នឹងត្រែងឲ្យកម្ពុជាវិញ
  - ឆ្នាំ១៩០៧ សៀមប្រគល់ខេត្ត បាត់ដំបង សិរីសោភណ្ឌ សៀមរាបឲ្យកម្ពុជាវិញ
  - ឆ្នាំ១៩០៨ បារាំងបានគូសផែនទីឈ្មោះ «ដងរែក» ដែលទទួលស្គាល់ដោយតំណាងបារាំង សៀមនៅលើឆាកអន្តរជាតិ
  - ឆ្នាំ១៩៤៧ ប្រកាសឲ្យប្រើរដ្ឋធម្មនុញ្ញលើកដំបូងនៅកម្ពុជា ថ្ងៃទី៤ ខែមិថុនា ឆ្នាំ១៩៤៩ បារាំងប្រគល់ដែនដីកម្ពុជាក្រោមឲ្យទៅវៀតណាម
  - ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៤៩ បារាំងប្រគល់ឯករាជ្យបណ្តោះអាសន្នឲ្យកម្ពុជា
  - ឆ្នាំ១៩៥៣ ព្រះបាទនរោត្តម សីហនុ យាងធ្វើព្រះរាជបូជនីយកិច្ចទាមទារឯករាជ្យ
  - ថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ កម្ពុជាទទួលបានឯករាជ្យបរិបូណ៌ពីបារាំង
  - ឆ្នាំ១៩៥៤ ប្រតិបត្តិការបណ្តេញពួកវៀតមិញ ចេញពីកម្ពុជា
  - ឆ្នាំ១៩៥៤ សៀមលើទឹពទាំងកំរោលចូលកាន់កាប់ប្រាសាទព្រះវិហារ
- សម័យសង្គមរាស្ត្រនិយម(១៩៥៣-១៩៧០)
  - ឆ្នាំ១៩៥៥ សម្តេច នរោត្តម សីហនុ ដាក់រាជ្យ និងបង្កើតសង្គមរាស្ត្រនិយម
  - ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៥៥ កម្ពុជាចូលជាសមាជិកអង្គការសហប្រជាជាតិ
  - ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៦២ តុលាការអន្តរជាតិក្រុងឡាអេ ចេញសាលក្រមឲ្យកម្ពុជាឈ្នះ ក្តីក្នុងរឿងក្តីក្តាំ ប្រាសាទព្រះវិហារ
- របបសាធារណរដ្ឋខ្មែរ (១៩៧០-១៩៧៥)
  - ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០លោកលន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេចនរោត្តម សីហនុ
  - ឆ្នាំ១៩៦៩-១៩៧៣ សហរដ្ឋអាមេរិកទម្លាក់គ្រាប់បែកលើកម្ពុជា
  - ឆ្នាំ១៩៧០-១៩៧៥ សង្គ្រាមស៊ីវិលនៅកម្ពុជា
- របបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)
  - ថ្ងៃទី១៧ មេសា ១៩៧៥ ផ្តួលរំលំរបប លន់ នល់ (សាធារណរដ្ឋខ្មែរ)
    - ជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងទីប្រជុំជននានា
    - របបប្រល័យពូជសាសន៍
  - ថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៨ បង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា

- ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ថ្ងៃដ៏យជម្នះលើរបបកម្ពុជាប្រជាធិបតេយ្យ

❖ សាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា (១៩៧៩-១៩៩៣)

- ការស្តារ និងកសាងប្រទេសឡើងវិញ
- ឆ្នាំ១៩៨៩-១៩៩១ របបរដ្ឋកម្ពុជា
- ឆ្នាំ១៩៩១-១៩៩៣ រដ្ឋាភិបាលបណ្តោះអាសន្ន
- ថ្ងៃទី២៣ តុលា ១៩៩១ កិច្ចព្រមព្រៀងក្រុងប៉ារីស
- ថ្ងៃទី១៤ វិច្ឆិកា ១៩៩១ មាតុភូមិនិត្តន៍របស់សម្តេចនរោត្តម សីហនុ
- ថ្ងៃទី១៤ ធ្នូ ១៩៩២ តំបន់អង្គរដាក់បញ្ចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោក
- ឆ្នាំ១៩៩៨ បោះឆ្នោតជាលើកទី២ កម្ពុជាទទួលបានសុខសន្តិភាពទាំងស្រុង ក្រោមនយោបាយ ឈ្នះ-ឈ្នះ របស់សម្តេច ហ៊ុន សែន
- ថ្ងៃទី៣០ មេសា ១៩៩៩ កម្ពុជាចូលជាសមាជិកអាស៊ាន ។

(ព្រឹត្តិការណ៍ផ្សេងៗទៀត)

៤. តម្លៃនៃសន្តិភាព គឺកម្ពុជាបានសុខសន្តិភាពជៀសផុតពីសង្គ្រាម ដែលទទួលបាននូវការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមដូចជា៖

❖ វិស័យសេដ្ឋកិច្ច

- ជួយជំរុញការអភិវឌ្ឍវិស័យកសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម ទេសចរណ៍
- ងាយស្រួលក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធគ្រប់យ៉ាង
- គ្រឹះស្ថានជំនួញកើនឡើង (កំណើនអ្នកវិនិយោគទុក)

❖ ផ្នែកសង្គម

- មានការទប់ស្កាត់សង្គ្រាម ការទាស់ទែងខ្វែងគំនិតគ្នាក្នុងសង្គម
- លើកស្ទួយការគោរពសិទ្ធិមនុស្ស សេរីភាពក្នុងសង្គមប្រជាធិបតេយ្យ
- ការពារ និងទប់ស្កាត់អំពើពុករលួយ
- ធ្វើឲ្យរដ្ឋមានលទ្ធភាពសម្រេចផែនការនានាតាមការកំណត់
- ជួយឲ្យមានសន្តិសុខសង្គម និងប្រទេសមានសន្តិភាព

(អាចមានមតិពាក់ព័ន្ធការអភិវឌ្ឍន៍វិស័យអប់រំ វប្បធម៌ និងសាសនា)

៥.វប្បធម៌សន្ទនាផ្តល់ប្រយោជន៍ជាតិជាធំជាងប្រយោជន៍បុគ្គលដោយ ៖

- បញ្ចៀសសង្គ្រាមពាក្យសម្តី និងទំនាស់ផ្សេងៗក្នុងសង្គម
- ដោះស្រាយបញ្ហាផ្សេងៗដោយសន្តិវិធី
- ផ្តល់នូវភាពស្មោះត្រង់ និងជឿជាក់គ្នាទៅវិញទៅមក
- បង្កើតសាមគ្គីភាព និងសហប្រតិបត្តិការប្រសើរជាងមុន
- ជាវេទិកាដែកដេញដោល និងពិភាក្សាឈរលើគោលការណ៍ស្មើភាព
- ពុំមានការគម្រាមកំហែងគ្នាទៅវិញទៅមក
- ជាគំរូល្អក្នុងសង្គមជាតិ ប្រកបដោយភាពជឿជាក់ពីសំណាក់រាស្ត្រ
- គោរពគ្នាទៅវិញទៅមកក្នុងភាពថ្លៃថ្នូរ
- មានទំនួលខុសត្រូវលើផលប្រយោជន៍ជាតិក្នុងសង្គមប្រជាធិនតេយ្យ
- បញ្ចៀសរាល់អំពើហិង្សា និងសង្គ្រាម
  (មានមតិត្រឹមត្រូវផ្សេងៗទៀត)

៦.តួនាទីព្រះពុទ្ធសាសនានៅសង្គមកម្ពុជា

- ផ្តល់នូវអរំមនុស្សឲ្យប្រកាន់អំពើល្អ (ស្គាល់បុណ្យ បាប ប្រកាន់នូវសច្ចៈធម៌)
- ផ្តល់ចំណេះដឹង ស្គាល់បុណ្យបាប អំពើល្អ អំពើអាក្រក់ គុណ ទោស ប្រកាន់នូវសច្ចៈ
- ផ្តល់នូវកន្លែងស្នាក់អាស្រ័យ និងជម្រកសម្រាប់ការអប់រំផ្លូវចិត្ត
- ផ្តល់នូវចំណេះដឹង ការគោរពប្រណិបត្តិអំពើល្អ ឲ្យស្រឡាញ់ជាតិ មិនប្រកាន់ពូជសាសន៍ មិន ប្រព្រឹត្តខុសគន្លងព្រះពុទ្ធសាសនា
- សីលធម៌ មានអត្តចរិកថ្លៃថ្នូរ មានការគោរពសិទ្ធិមនុស្ស
- ចេះរស់ក្នុងសង្គមមានទំនាក់ទំនងល្អ ចេះអត់ឱនអធ្យាស្រ័យសាមគ្គីក្នុងសង្គម ប្រជាធិបតេយ្យ
- ជាកន្លែងផ្សព្វផ្សាយវប្បធម៌ជាតិ
- រស់នៅដោយសុខសន្តិភាព អហឹង្សា រស់ក្នុងសង្គមវប្បធម៌ចែករំលែក...។

៧.អ្នកប្រាជ្ញខ្មែរដែលបានរៀបចំវចនានុក្រមខ្មែរគឺ សម្តេចសង្ឃរាជ ជួន ណាត ។

ប្រវត្តិសាស្ត្រតំបន់ និងពិភពលោក

(ដកស្រង់ចេញពីការបង្រៀនក្នុងផេកក្រសួងអប់រំ)

ចងក្រងឡើងដោយ ម៉ែត ជីវិន

✦✦✦ ✦✦ ⊙ ✦✦✦✦✦

ប្រធានសំណួរ

១. (២០១៤) តើពិភពលោកកំពុងជួបប្រទះនឹងបញ្ហាធំៗអ្វីខ្លះ?

២.(២០១៤) ពណ៌នាអំពីសន្តិសុខស្បៀង ដែលពិភពលោកកំពុងជួបប្រទះ។

៣.(២០១៤) ពណ៌នាអំពីទិដ្ឋភាពវិជ្ជមាន និងអវិជ្ជមាននៃសកលភាវូបនីយកម្ម។

៤.(២០១៤) តើអាស៊ានជាអ្វី?ហើយមានសារៈសំខាន់អ្វីខ្លះសម្រាប់កម្ពុជា?

៥.(២០១៦) តើពិភពលោកយើងនាពេលបច្ចុប្បន្នកំពុងជួបប្រទះនឹងបញ្ហាធំៗអ្វីខ្លះ?

៦.(២០១៦) តើអាស៊ានជាអ្វី? តើកម្ពុជាបានទទួលផលប្រយោជន៍អ្វីខ្លះ ពីការចូលជាសមាជិកអាស៊ាន?

៧.(២០១៧) តើសង្គ្រាមត្រជាក់ក្នុងទសវត្សរ៍ឆ្នាំ១៩៥០-១៩៦០ នាំមកអ្វីខ្លះដល់ឥណ្ឌូចិន

៨.(២០១៧) តើសមាគមអាស៊ានមានសមាជិកប៉ុន្មាន?ប្រទេសណាខ្លះ?

៩.(២០១៨) សមាគមអឺរ៉ុបជាអ្វី?

១០.(២០១៨) ចូរពណ៌នាពីតួនាទីរបស់សមាគមអាស៊ាននៅអាស៊ីអាគ្នេយ៍ ។

១១.(២០២១) តើសមាគមអាស៊ានជាអ្វី មានប្រទេសណាខ្លះជាសមាជិក ?

១២.(២០២១) ចូរពណ៌នាពីបញ្ហាធំៗលើពិភពលោក ។

១៣.(២០២២) តើសមាគមអាស៊ានមានសមាជិកចំនួនប៉ុន្មាន ? ការចូលជាអាស៊ានផ្តល់ផលប្រយោជន៍អ្វីខ្លះ ដល់កម្ពុជា ?

១៤.(២០២២) ចូររៀបរាប់មូលហេតុ និងផលវិបាកនៃសាកលភាវូបនីយកម្ម ។

១៥.(២០២២) ចូររៀបរាប់ពីបញ្ហាសន្តិសុខស្បៀងលើពិភពលោក ។

១៦.(២០២២) តើសង្គ្រាមត្រជាក់ជាអ្វី ? មានផលវិបាកអ្វីខ្លះដល់ពិភពលោក ?

អត្ថាធិប្បាយ

១.៥.១២.ពិភពលោកយើងនាពេលបច្ចុប្បន្ននេះកំពុងជួបប្រទះនឹងបញ្ហាធំៗជាច្រើនដូចជា ៖

- បញ្ហាបរិស្ថាន ៖ បម្រែបម្រួលអាកាសធាតុ គ្រោះធម្មជាតិ(គ្រោះរាំងស្ងួត កំណើនកំដៅផែនដី ភ្លើងឆេះព្រៃ រញ្ជួយដី ព្យុះភ្លៀង ទឹកជំនន់) សម្រាម...

- បញ្ហាកំណើនប្រជាជន ៖ ឧបត្ថម្ភថាមពល សុវត្ថិភាពស្បៀង ភាពក្រីក្រ ជនអន្តោប្រវេសន៍
- បញ្ហាជនអន្តោប្រវេសន៍ ៖ ការជួញដូរមនុស្ស ជួញដូរផ្លូវភេទ គ្រឿងញៀន ពលកម្មលើកុមារ
- បញ្ហាសន្តិសុខស្បៀង ៖ កង្វះស្បៀងចោទជាបញ្ហានាំមកនូវភាពក្រីក្រ និងគ្រោះទុក្ស
- បញ្ហាភេរវកម្មអន្តរជាតិ ៖ ការធ្វើឃាតមេដឹកនាំ ការបំផ្ទុះគ្រាប់បែក...
- ឧក្រិដ្ឋកម្មឆ្លងដែន ៖ ការជួញដូរគ្រឿងញៀន ជួញដូរមនុស្ស ធ្វើចរាចរណ៍ ក្រដាសប្រាក់ក្លែង ក្លាយ ការជំរិតទារប្រាក់តាមប្រព័ន្ធអ៊ីនធឺណែត។

២.១៥. បញ្ហាសន្តិសុខស្បៀង ដែលពិភពលោកកំពុងជួបប្រទះមាន ៖

- បញ្ហាកង្វះគ្រឿងឧបភោគ បរិភោគ
- បញ្ហាប្រឈមនិងគ្រោះទុក្ស
- បញ្ហាដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ចពិភពលោក
- បញ្ហារបបគំហើញផ្នែកបច្ចេកវិទ្យា និងបច្ចេកទេសថ្មី
- បញ្ហាអត្រាកំណើនប្រជាជនលើពិភពលោក
- ការប្រើប្រាស់ថាមពលឧស្ម័នកាបូនិច
- ការប្រើប្រាស់ដី និងថ្នាំសម្លាប់សត្វល្អិតមិនបានសមស្រប បញ្ហាធម្មជាតិ (ទឹកជំនន់ ខ្យល់ព្យុះ គ្រោះរាំងស្ងួត ភ្នួយដី បន្ទុះភ្នំភ្លើង)
- បញ្ហាសង្គ្រាម (ជនភៀសខ្លួន)
- បញ្ហាកាប់បំផ្លាញព្រៃឈើ ការជីកយករ៉ែ

(បញ្ហាផ្សេងៗទៀត)

៣.ទិដ្ឋភាពវិជ្ជមាន និងអវិជ្ជមាននៃសកលភាវូបនីយកម្ម ៖

❖ ទិដ្ឋភាពវិជ្ជមាន

- ធ្វើឲ្យមានការរីកចម្រើនផ្នែកសេដ្ឋកិច្ច (កសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម ទេសចរណ៍) និងសង្គម (វប្បធម៌ សិល្បៈ)
- អភិវឌ្ឍន៍ផ្នែកបច្ចេកវិទ្យាទំនើប (បង្កើតគ្រឿងម៉ាស៊ីនស្វ័យប្រវត្តិ)
- ធ្វើឲ្យមានការរីកចម្រើនផ្នែកទូរគមនាគមន៍អន្តរជាតិ (ទូរសព្ទ ទូរទស្សន៍ អ៊ីនធឺណែត)
- បង្កើតសដ្ឋកិច្ចទីផ្សារសេរី មានការប្រកួតប្រជែង

- មានទំនាក់ទំនងល្អនៅក្នុងទំនាក់ទំនងការបរទេស
- បង្កើតកិច្ចសហប្រតិបត្តិការល្អ ដើម្បីដោះស្រាយរាល់បញ្ហាដែលបង្កការគំរាមកំហែងដល់ពិភពលោកឲ្យទាប់ពេលវេលា (បរិស្ថាន ជំងឺឆ្លង សន្តិសុខស្បៀង កំណើនប្រជាជន...)
- មានភាពងាយស្រួលក្នុងការ ធ្វើបម្លាស់ប្តូរលំនៅដ្ឋានរបស់ប្រជាជនលើពិភពលោក

❖ ទិដ្ឋភាពអវិជ្ជមាន

- ប្រទេសតូចតាចបាត់បង់អធិបតេយ្យភាពរបស់ខ្លួន នៅចំពោះមុខប្រទេសមហាអំណាច (អ៊ុយក្រែន អ៊ីរ៉ាក់ លីប៊ី...)
- មានការជ្រែកជ្រែកកិច្ចការផ្ទៃក្នុងពីសំណាក់ប្រទេសមហាអំណាច មកលើប្រទេសទន់ខ្សោយ ដែលធ្វើឲ្យមានការផ្លាស់ប្តូរក្នុងវិស័យនយោបាយ សេដ្ឋកិច្ច សង្គម
- បង្កឲ្យមានសង្គ្រាមរវាងរដ្ឋ និងរដ្ឋ (អ៊ីស្រាអែល និងប៉ាលេស្ទីន)
- ធ្វើឲ្យមានការរីកសាយយ៉ាងខ្លាំង នូវបច្ចេកវិទ្យាយោធាទំនើប ដែលបង្កការគំរាមកំហែងដល់ពិភពលោក
- កំណើនប្រជាជន ដែលចោទជាបញ្ហាដល់សេដ្ឋកិច្ច និងសង្គម
- ប្រព័ន្ធផ្សាយរណប ក៏អាចជាប្រភពនៃបញ្ហាដែលធ្វើឲ្យរដ្ឋាភិបាលរឹតតែបាត់បង់ប្រសិទ្ធភាព ក្នុងការគ្រប់គ្រងប្រព័ន្ធព័ត៌មាន។

៥.៦.អាស៊ាន គឺជាសហគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ ។

កម្ពុជាទទួលបាននូវសារប្រយោជន៍យ៉ាងច្រើនពីការចូលជាសមាជិកអាស៊ានដូចជា៖

❖ ខាងនយោបាយ

- កម្ពុជាលែងឯកោតទៅទៀត
- កម្ពុជាបានឈរស្មើមុខស្មើមាត់ជាមួយប្រទេសជាសមាជិកអាស៊ាន
- បានចូលរួមនូវរាល់ការសម្រេចចិត្តនានាក្នុងតំបន់

❖ ខាងផ្នែកសេដ្ឋកិច្ច

- កម្ពុជាក្លាយជាកន្លែងវិនិយោគដ៏ទាក់ទាញ
- ការធ្វើពាណិជ្ជកម្មងាយស្រួលជាងមុន
- ប្រជាជនអាចរកការងារធ្វើទាំងក្នុងប្រទេស និងក្នុងតំបន់
- កំណើនភ្ញៀវទេសចរដែលបង្កើតការងារ និងប្រាក់ចំណូលដល់ប្រជាជន

- សេដ្ឋកិច្ចកម្ពុជាមានកំណើនរៀងរាល់ឆ្នាំ

❖ ខាងផ្នែកសង្គម

- ទទួលបាននូវកិច្ចសហការជាមួយប្រទេសក្នុងតំបន់ក្នុងការរក្សាសន្តិភាព សន្តិសុខសង្គម
- ទប់ស្កាត់ការជួញដូរមនុស្ស គ្រឿងញៀន និងអំពើភេរវកម្ម
- ការជួយគ្នាទៅវិញទៅមកតាមរយៈការផ្ទេរបទពិសោធន៍ ចំណេះដឹង ផ្តល់អាហារូបករណ៍ ដល់មន្ត្រី យុវជនកម្ពុជាសម្រាប់ការរៀនសូត្រ និងទទួលបានឪកាសល្អៗជាច្រើន

❖ ខាងទំនាក់ទំនង

- ជំរុញឲ្យមានការកសាងហេដ្ឋារចនាសម្ព័ន្ធ ផ្លូវថ្នល់ ផ្លូវដែក អាកាសយានដ្ឋាន កំពង់ផែ ស្ពាន...
- ការលើកលែងទិដ្ឋាការ

(មតិផ្សេងៗទៀត)

៧.សង្គ្រាមត្រជាក់ក្នុងទស្សវត្សរ៍ឆ្នាំ១៩៥០-១៩៦០ បាននាំមកដល់ទ្វីបឥណ្ឌូចិនរួមមានដូចជា៖

❖ ផលវិជ្ជមាន

- ប្រទេសនៅក្នុងតំបន់ឥណ្ឌូចិនទទួលបានឯករាជ្យ
- មានស្វ័យភាពក្នុងការដឹកនាំប្រទេស
- ប្រទេសកម្ពុជាទទួលបានអព្យាក្រឹត
- ទទួលបានជំនួយក្នុងការអភិវឌ្ឍជាតិលើគ្រប់វិស័យ
- កម្ពុជាមានស្ថិរភាព និងចូលជាសមាជិកអង្គការសហប្រជាជាតិ

❖ ផលអវិជ្ជមាន

- ប្រទេសនៅក្នុងតំបន់ឥណ្ឌូចិនរងនូវការគាបសង្កត់ពីមហាអំណាច មនោគមវិជ្ជាសេរី និងកុម្មុយនីស្ត
- ប្រទេសវៀតណាមចែកជាពីរ (កុម្មុយនីស្ត និងសេរី)
- ប្រទេសឡាវចែកជាពីរ (កុម្មុយនីស្ត និងសេរី)
- សង្គ្រាមនៅវៀតណាមកើតឡើង

- កម្ពុជាអនុវត្តនយោបាយអព្យាក្រឹតមិនចំទិសដៅ និងមានទំនាក់ទំនងជាមួយប្រទេសជិតខាង

៨.សមាគមអាស៊ានមាន១០ប្រទេសដូចជា៖

- ព្រះរាជាណាចក្រថៃឡង់ដ៍
- សហព័ន្ធម៉ាឡេស៊ី
- សាធារណរដ្ឋឥណ្ឌូនេស៊ី
- សាធារណរដ្ឋសិង្ហបុរី
- សាធារណរដ្ឋហ្វីលីពីន
- ព្រុយនដារុយសាឡឹម
- សាធារណរដ្ឋសង្គមនិយមវៀតណាម
- សហព័ន្ធមីយ៉ាន់ម៉ា
- សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ
- ព្រះរាជាណាចក្រកម្ពុជា

៩.សហគមន៍អឺរ៉ុប គឺជាសមាគមសេដ្ឋកិច្ច និងនយោបាយដ៏ធំសម្បើមមួយ ដែលមានរដ្ឋអឺរ៉ុបចំនួន ២៧ប្រទេសជាសមាជិក ដោយឈរលើគោលការណ៍សេរីភាព ប្រជាធិបតេយ្យ សិទ្ធិមនុស្ស ។

១០.សហគមន៍អាស៊ានបានដើរតួបាទីយ៉ាងសំខាន់នៅអាស៊ីអាគ្នេយ៍ដូចតទៅ ៖

❖ ផ្នែកនយោបាយ

- រក្សាសន្តិសុខ សន្តិភាព ក្នុងតំបន់ និងពិភពលោក
- ចូលរួមដោះស្រាយវិវាទ ឬជម្លោះក្នុងតំបន់ និងពិភពលោក
- ធ្វើឲ្យមានឯកភាពក្នុងការដឹកនាំស្របតាមលទ្ធិប្រជាធិបតេយ្យ។

❖ ផ្នែកសេដ្ឋកិច្ច

- ជំរុញការអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ចក្នុងតំបន់ និងពិភពលោក
- ជំរុញកិច្ចសហប្រតិបត្តិការផ្នែកពាណិជ្ជកម្ម និងអភិវឌ្ឍន៍ទីផ្សារដើម្បីប្រកួតប្រជែងជាមួយ ប្រទេសជឿនលឿន
- បង្កើតកិច្ចសហប្រតិបត្តិការលើវិស័យទេសចរណ៍ ដើម្បីបង្កើនការងារនិងប្រាក់ចំណូលដល់ប្រជាជន។

- ផ្នែកសង្គម
  - ជំរុញកិច្ចសហប្រតិបត្តិការផ្នែកវប្បធម៌ ជំនឿ សាសនា ប្រពៃណី ទំនៀមទម្លាប់
  - ផ្លាស់ប្តូរបទពិសោធន៍ផ្នែកអប់រំសិក្សាធិការ ការណ្តុះបណ្តាលធនធានមនុស្ស បច្ចេកវិទ្យា និងវិទ្យាសាស្ត្រ
  - លើកកម្ពស់សិទ្ធិមនុស្ស និងសមភាពយេនឌ័រក្នុងតំបន់
  - ជំរុញកិច្ចសហប្រតិបត្តិការទប់ស្កាត់ការជួញដូរមនុស្ស ជួញដូរគ្រឿងញៀន និងអំពើកេរវៃកម្ម
  - បង្កើនទំនាក់ទំនងល្អរវាងប្រជាជាតិនានាក្នុងតំបន់ និងពិភពលោក ។

១១. សមាគមអាស៊ាន គឺជាសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ។

សមាគមអាស៊ានមាន១០ប្រទេសដូចជា ៖

- ព្រះរាជាណាចក្រកម្ពុជា
- ព្រះរាជាណាចក្រថៃឡង់ដ៍
- សហព័ន្ធម៉ាឡេស៊ី
- សាធារណរដ្ឋឥណ្ឌូនេស៊ី
- សាធារណរដ្ឋសិង្ហបុរី
- សាធារណរដ្ឋហ្វីលីពីន
- ព្រុយនដារុយសាឡឹម
- សាធារណរដ្ឋសង្គមនិយមវៀតណាម
- សហព័ន្ធមីយ៉ាន់ម៉ា
- សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ។

១៣.សមាគមអាស៊ានមាន១០ប្រទេសដូចជា ៖

- ព្រះរាជាណាចក្រកម្ពុជា
- ព្រះរាជាណាចក្រថៃឡង់ដ៍
- សហព័ន្ធម៉ាឡេស៊ី
- សាធារណរដ្ឋឥណ្ឌូនេស៊ី
- សាធារណរដ្ឋសិង្ហបុរី

- សាធារណរដ្ឋហ្វីលីពីន
- ព្រុយនដារុយសាឡឹម
- សាធារណរដ្ឋសង្គមនិយមវៀតណាម
- សហព័ន្ធមីយ៉ាន់ម៉ា
- សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ។

➢ កម្ពុជាទទួលបាននូវសារប្រយោជន៍យ៉ាងច្រើនពីការចូលជាសមាជិកអាស៊ានដូចជា៖

❖ ខាងនយោបាយ

- កម្ពុជាលែងឯកោតទៅទៀត
- កម្ពុជាបានឈរស្មើមុខស្មើមាត់ជាមួយប្រទេសជាសមាជិកអាស៊ាន
- បានចូលរួមនូវរាល់ការសម្រេចចិត្តនានាក្នុងតំបន់

❖ ខាងផ្នែកសេដ្ឋកិច្ច

- កម្ពុជាក្លាយជាកន្លែងវិនិយោគដ៏ទាក់ទាញ
- ការធ្វើពាណិជ្ជកម្មងាយស្រួលជាងមុន
- ប្រជាជនអាចរកការងារធ្វើទាំងក្នុងប្រទេស និងក្នុងតំបន់
- កំណើនភ្ញៀវទេសចរដែលបង្កើតការងារ និងប្រាក់ចំណូលដល់ប្រជាជន
- សេដ្ឋកិច្ចកម្ពុជាមានកំណើនរៀងរាល់ឆ្នាំ

❖ ខាងផ្នែកសង្គម

- ទទួលបាននូវកិច្ចសហការជាមួយប្រទេសក្នុងតំបន់ក្នុងការរក្សាសន្តិភាព សន្តិសុខសង្គម
- ទប់ស្កាត់ការជួញដូរមនុស្ស គ្រឿងញៀន និងអំពើកេរ្តិ៍កម្ម
- ការជួយគ្នាទៅវិញទៅមកតាមរយៈការផ្ទេរបទពិសោធន៍ ចំណេះដឹង ផ្តល់អាហារូបករណ៍ ដល់មន្ត្រី យុវជនកម្ពុជាសម្រាប់ការរៀនសូត្រ និងទទួលបានឱកាសល្អៗជាច្រើន

❖ ខាងទំនាក់ទំនង

- ជំរុញឲ្យមានការកសាងហេដ្ឋារចនាសម្ព័ន្ធ ផ្លូវថ្នល់ ផ្លូវដែក អាកាសយានដ្ឋាន កំពង់ផែ ស្ពាន...
- ការលើកលែងទិដ្ឋាការ (មតិផ្សេងៗទៀត)

១៤.រៀបរាប់មូលហេតុនិងផលវិបាកនៃសកលភាវូបនីយកម្ម ៖

❖ កត្តាដែលជាប្រភពជំរុញឲ្យមានសកលភាវូបនីយកម្មរួមមានដូចជា ៖

- កម្លាំងចលករនៃប្រព័ន្ធសេដ្ឋកិច្ចសកលលោកដែលជំរុញឱ្យកាន់តែ លេចឡើងនូវអស្ថិរភាពនិងផលវិបាកចំពោះបញ្ហាផ្ទៃក្នុងប្រទេស និងទំនាក់ទំនងរវាងប្រទេសលើពិភពលោក
- កំណើនយ៉ាងខ្លាំងនូវបម្លាស់ប្តូរទីកន្លែងរស់នៅរបស់ប្រជាពលរដ្ឋនៅ លើពិភពលោក
- ការរីកចម្រើនយ៉ាងខ្លាំងនូវប្រព័ន្ធទំនាក់ទំនងទូរគមនាគមន៍អន្តរជាតិ
- ការរីកសាយភាយយ៉ាងខ្លាំងនូវបច្ចេកវិទ្យាយោធាទំនើបដែលជានិច្ច កាលបានក្លាយជាឧបករណ៍នយោបាយពិភពលោក
- បញ្ហារួមជាច្រើនបានកើតឡើង ដែលទាមទារឲ្យមានការសម្រេច ចិត្តដោះស្រាយបញ្ហាទាំងនេះតាមរយៈ ថ្នាក់ដឹកនាំរដ្ឋាភិបាល អង្គ ការអន្តរជាតិ សហគមន៍អន្តរជាតិជាដើម។

❖ ផលវិបាកនៃសកលភាវូបនីយកម្ម ៖

- ប្រទេសតូចតាចត្រូវបាត់បង់អនាធិបតេយ្យរបស់ខ្លួននៅចំពោះមុខ ប្រទេសមហាអំណាច (អ៊ុយក្រែន អ៊ីរ៉ាក់ លីប៊ី ...)
- មានការជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងសំណាក់ប្រទេសមហាអំណាចមក លើប្រទេសទន់ខ្សោយ ដែលធ្វើឲ្យមានការផ្លាស់ប្តូរនៅក្នុងវិស័យនយោបាយ សេដ្ឋកិច្ច សង្គម
- បង្កឲ្យមានសង្គ្រាមរវាងរដ្ឋនិងរដ្ឋ (អ៊ីស្រាអែល និងប៉ាលេស្ទីន)
- ធ្វើឲ្យមានការរីកសាយភាយយ៉ាងខ្លាំងនូវបច្ចេកវិទ្យាយោធាទំនើប ដែលបង្កការគម្រាមកំហែងដល់ពិភពលោក
- កំណើនប្រជាជនឲ្យមានបញ្ហាចោទដល់សេដ្ឋកិច្ចនិងសង្គម
- ប្រព័ន្ធផ្តាយរណបក៏អាចជាប្រភពបញ្ហាដែលធ្វើឲ្យរដ្ឋាភិបាលរឹតត បាត់បង់ប្រសិទ្ធភាពក្នុងការគ្រប់គ្រងប្រព័ន្ធព័ត៌មានទៀត ។

(ចម្លើយត្រឹមត្រូវផ្សេងៗទៀត)

១៦.សង្គ្រាមត្រជាក់ជាប្រភេទសង្គ្រាមធ្វើការប្រណាំងប្រជែងខាង ផ្នែក គ្រឿងសព្វាវុធទំនើប មនោគមន៍វិជ្ជា នយយោបាយ បច្ចេក វិទ្យា រវាងប្តូកកុំម្មុយនីស (សហភាពសូវៀត) និង ប្តូកសេរី (សហរដ្ឋអាមេរិច) ដែលជាអ្នកបង្ក។

- វាផ្តល់ផលវិបាកដូចជា ៖
  - អង្គការសហប្រជាជាតិ ពុំអាចបំពេញតួនាទីរបស់ខ្លួន បានល្អប្រសើរ រក្សាសិទ្ធិគ្រប់យ៉ាង
  - ប្រជាជាតិដែលទើបតវួចផុតពីអាណានិគមត្រូវប្រឈម មុខនឹងមនោគមវិជ្ជាដែលបណ្តាលឱ្យបែកបាក់ជាតិ
  - ការរត់ប្រណាំងខាងសព្វាវុធបាននាំពិភពលោកទៅរក ភាពមហន្តរាយនៃអាវុធប្រល័យលោក និងការបង្កើតបក្ស សម្ព័ន្ធ យោធាប្រឈមមុខដាក់គ្នា
  - ប្រជាជាតិដែលទើបតែរួចផុតពីអាណានិគម និងប្រទេស ទន់ខ្សោយត្រូវប្រឈមមុខនឹង សង្គ្រាមស៊ីវិល ដែលនាំ មកនូវ វិនាសកម្ម និងការខូចខាតយ៉ាងធ្ងន់ធ្ងរ
  - ប្រទេសមួយចំនួនត្រូវបានបែងចែកជាពីរ ដូចជាប្រទេស វៀតណាម ប្រទេសកូរ៉េ ប្រទេសអាល្លឺម៉ង់ ជាដើម ។

« វិញ្ញាសាទី១ »

✍ ចងក្រងឡើងដោយ ម៉ែត ជីវិន ✍

(ដកស្រង់ចេញពីការបង្រៀនក្នុងផែកក្រសួងអប់រំ)

✦ ✦✦ ⊙ ✦✦✦

១. តើកម្ពុជាចូលជាសមាជិកអង្គការសហប្រជាជាតិនៅឆ្នាំណា ?

ក. តើការចូលជាសមាជិកអង្គការសហប្រជាជាតិមានអត្ថន័យដូចម្តេចខ្លះ ចំពោះកម្ពុជា ?

ខ. តើអង្គការសហប្រជាជាតិបានជួយដោះស្រាយបញ្ហាអ្វីខ្លះ ដល់កម្ពុជា ?

២. តើសម្តេច នរោត្តម សីហនុ បង្កើតអង្គការសង្គមរាស្ត្រនិយមនៅឆ្នាំណា ? ការបង្កើតអង្គការសង្គមរាស្ត្រនិយមរបស់សម្តេច នរោត្តម សីហនុ ពិតជាអាចបង្រួបបង្រួមជាតិបានដែរ ឬ ទេ ? ព្រោះអ្វី ?

៣. តើខ្មែរក្រហមឡើងកាន់អំណាចនៅកម្ពុជា នៅឆ្នាំណា ?

ក. ក្នុងការឡើងកាន់អំណាច ខ្មែរក្រហមបាននាំមកនូវអ្វីខ្លះ សម្រាប់កម្ពុជា ?

ខ. តើរបបកម្ពុជាប្រជាធិបតេយ្យបានបន្សល់នូវផែលវិបាកអ្វីខ្លះ សម្រាប់កម្ពុជា ?

អត្ថាធិប្បាយ

១. កម្ពុជាចូលជាសមាជិកអង្គការសហប្រជាជាតិនៅឆ្នាំ ១៩៥៥ (១៤ ធ្នូ ១៩៥៥) ។

ក. ការចូលជាសមាជិកអង្គការសហប្រជាជាតិមានអត្ថន័យជាប្រវត្តិសាស្ត្រ ចំពោះកម្ពុជា ដូចតទៅ ៖

- ប្រទេសកម្ពុជាលែងជាប្រទេសឯកកោតទៅទៀត
- កម្ពុជាបានឈរស្មើមុខស្មើមាត់ជាមួយប្រទេសនានាលើពិភពលោក
- កម្ពុជាបានចូលរួមសម្រេចកិច្ចការនានាលើពិភពលោកក្នុងមាគ៌ាសន្តិភាព
- កម្ពុជាទទួលបាននូវការគោរពឯករាជ្យ អធិបតេយ្យភាព បូរណភាពទឹកដីពីសំណាក់អន្តរជាតិ
- កម្ពុជាទទួលបាននូវមូលនិធិ ពីសំណាក់អន្តរជាតិក្នុងការអភិវឌ្ឍជាតិក្នុងមាគ៌ាសន្តិភាព
- កម្ពុជាទទួលបាននូវការការពារ ពីសំណាក់អន្តរជាតិ ។

(មតិផ្សេងទៀត)

ខ. អង្គការសហប្រជាជាតិបានជួយដោះស្រាយបញ្ហាជាច្រើនដល់កម្ពុជាដូចជា ៖

- តុលាការអន្តរជាតិក្រុងឡាអេ បានជួយដោះស្រាយវិវាទរឿងក្តីក្តាំប្រាសាទ ព្រះវិហារ ដែលថៃឈ្លានពាននៅឆ្នាំ ១៩៥៤ ដោយតុលាការចេញសាលក្រមឲ្យខ្មែរឈ្នះក្តីនៅថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ១៩៦២
- ឧត្តមស្នងការអង្គការសហប្រជាជាតិសម្រាប់ជនភៀសខ្លួន (UNHCR) បានជួយឧបត្ថម្ភគាំទ្រដល់ជនភៀសខ្លួន នៅតាមព្រំដែនកម្ពុជា - ថៃ
- អង្គការសហប្រជាជាតិបានជួយជ្រោមជ្រែងឲ្យមានការចរចាបញ្ចប់សង្គ្រាមស៊ីវិលនៅកម្ពុជា ដែលនាំទៅរកការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាព ក្រុងប៉ារីស ថ្ងៃទី ២៣ ខែតុលា ឆ្នាំ១៩៩១
- អាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិនៅកម្ពុជា (អ៊ុន តាក់ = UNTAC) បានជួយរៀបចំការបោះឆ្នោត (ថ្ងៃទី២៣-២៨ ខែឧសភា ឆ្នាំ១៩៩៣) ដើម្បីបង្កើតរដ្ឋាភិបាលថ្មី (ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣)
- តាមរយៈអង្គការនានាក្រោមឱវាទដូចជា អង្គការ UNDP , UNICEF , UNESCO , ILO , IMO , IMF , FAO , WHO , GATT..... អង្គការសហប្រជាជាតិបានជួយអភិវឌ្ឍន៍ប្រទេសកម្ពុជាក្នុងមាគ៌ាសន្តិភាព
- អង្គការយូណេស្កូ បានជួយរៀបចំដាក់សម្បត្តិវប្បធម៌កម្ពុជា ជាបេតិកភណ្ឌពិភពលោក
- អង្គការសហប្រជាជាតិបានជួយរៀបចំកាត់ទោសមេដឹកនាំខ្មែរក្រហម
- ជាថ្មីម្តងទៀតតុលាការអន្តរជាតិក្រុងឡាអេ បានបកស្រាយសាលក្រមឲ្យកម្ពុជាឈ្នះក្តីក្នុងរឿងក្តីជម្លោះទឹកដីតំបន់ប្រាសាទព្រះវិហារ (១១ វិច្ឆិកា ២០២២)

២. សម្តេចនរោត្តម សីហនុ បង្កើតអង្គការសង្គមរាស្ត្រនិយមនៅឆ្នាំ១៩៥៥ ។

➢ ការបង្កើតអង្គការសង្គមរាស្ត្រនិយមរបស់សម្តេចនរោត្តម សីហនុ ពុំអាចបង្រួបបង្រួមជាតិធ្វើឲ្យមានឯកភាពជាតិបានទេ (ឬបានតែរយៈពេលខ្លី) ព្រោះ

- គណបក្សដែលរំលាយខ្លួនចូលជាមួយសង្គមរាស្ត្រនិយម បានតែមួយរយៈប៉ុណ្ណោះ ក៏បានចាកចេញទៅបង្កើតបក្សថ្មី ឬពង្រឹងបក្សរបស់ខ្លួនឡើងវិញ
- ឥស្សរជននយោបាយរបស់សង្គមរាស្ត្រនិយមមួយចំនួន បានចាកចេញទៅបង្កើតបក្សថ្មីមកប្រឆាំងនឹងសង្គមរាស្ត្រនិយមវិញ
- មានបក្សប្រឆាំងក្នុងសភាដែលតែងតែប្រឆាំងនឹង គោលនយោបាយសង្គមរាស្ត្រនិយម

- អ្នកនយោបាយបែកបាក់សាមគ្គីគ្នា បង្កើតបានជាខ្មែរច្រើនក្រុម ដូចជា ក្រុមខ្មែរកុម្មុយនិស្ត (ខ្មែរក្រហម) ខ្មែរសេរី (ខ្មែរខៀវ) ក្រុមខ្មែររាជានិយម (ខ្មែរស) ដែលក្រុមទាំងនេះប្រឈមមុខដាក់គ្នាទាំងមនោគមវិជ្ជា និង ប្រដាប់អាវុធ
- ខ្មែរសេរីធ្វើការហាត់ទ័ពនៅព្រំដែនកម្ពុជា-ថៃ និង ធ្វើការផ្សព្វផ្សាយតាមវិទ្យុប្រឆាំងនឹងសង្គមរាស្ត្រនិយម
- ខ្មែរក្រហមបានពង្រឹងកម្លាំងនៅតាមភូមិភាគឦសាន ឧត្តរ ពាយ័ព្យ និងវាយប្រហារលើកម្លាំងសង្គមរាស្ត្រនិយម
- ក្រុមលោកលន់ នល់ បានធ្វើរដ្ឋប្រហារទម្លាក់សម្តេចនរោត្តម សីហនុ (១៨ មីនា ១៩៧០) របបសង្គមរាស្ត្រនិយម ក៏បានដួលរលំ ។

៣. ខ្មែរក្រហមឡើងកាន់អំណាចនៅកម្ពុជា នៅឆ្នាំ១៩៧៥ (១៧ មេសា ១៩៧៥) ។

ក. ក្នុងការឡើងកាន់អំណាច ខ្មែរក្រហមពុំបាននាំមកនូវភាពរីកចម្រើនរុងរឿងនោះទេ មានតែនាំមកនូវនិរាសសកម្មសម្រាប់កម្ពុជាដូចជា ៖

❖ **និរាសកម្មសង្គម :**

- ជម្លៀសប្រជាជនដោយបង្ខំចេញពីទីប្រជុំជន និងទីក្រុងភ្នំពេញ
- បង្ខំឲ្យប្រជាជនធ្វើការដោយមិនគ្មានពេលឈប់សម្រាក រហូតបាក់កម្លាំង
- ធ្វើការបង្អត់អាហារប្រជាជន គ្មានថ្នាំព្យាបាលជំងឺ រងចាំតែសេចក្តីស្លាប់
- បំបិទសិទ្ធិសេរីភាព ...

❖ **វប្បធម៌ :**

- ប្រព័ន្ធអប់រំ ត្រូវលុបបំបាត់ចោលទាំងស្រុង (បំបាត់សាលារៀន សម្លាប់គ្រូ)
- លុបបំបាត់វត្តអារាម ជំនឿ សាសនា ទំនៀមទម្លាប់ ប្រពៃណី កម្ទេចសំណង់ប្រាសាទ

❖ **ហេដ្ឋារចនាសម្ព័ន្ធ :** សាលារៀន មន្ទីរពេទ្យ ផ្លូវថ្នល់ ស្ពាន សំណង់សាធារណៈរងការខូចខាត

❖ **សេដ្ឋកិច្ច :**

- លុបបំបាត់ទីផ្សារ និងការចរាចរណ៍រូបិយវត្ថុ
- លុបបំបាត់កម្មសិទ្ធិឯកជន
- លុបបំបាត់សកម្មភាពពាណិជ្ជកម្មក្នុង និងក្រៅប្រទេស

❖ នយោបាយ :

- អនុវត្តនយោបាយកុម្មុយនិស្តផ្តាច់ការ បំពិតបំភ័យ កាប់សម្លាប់
- អនុវត្តនយោបាយសម្រិតសម្រាំងយកមនុស្សបដិវត្តន៍ល្អបរិសុទ្ធ ដែលនាំមកនូវការកាប់សម្លាប់
- ផ្តាច់ទំនាក់ទំនងជាមួយប្រទេសមួយចំនួនលើពិភពលោកដូចជា ប្រទេសថៃ វៀតណាម សហរដ្ឋអាមេរិក និង សហភាពសូវៀត

(មតិផ្សេងទៀត)

ខ. របបកម្ពុជាប្រជាធិបតេយ្យបានបន្សល់នូវផលវិបាកដល់ប្រទេសជាតិដូចជា ៖

❖ ខាងសង្គម :

- បន្សល់ទុកស្ត្រីមេម៉ាយ ក្មេងកំព្រា ចាស់ជរាគ្មានទីពឹង ជនបាក់កម្លាំង
- ប្រជាជនរាប់សែននាក់ រត់ចាកចោលប្រទេស (ភៀសខ្លួន) ដោយអស់សង្ឃឹមនឹងជោគវាសនាប្រទេសខ្លួន
- បង្កជាវិបត្តិផ្លូវចិត្ត
- បាត់បង់ធនធានមនុស្ស

❖ ខាងវប្បធម៌ :

- វប្បធម៌ ជំនឿ សាសនា ប្រពៃណី ទំនៀមទម្លាប់ សិល្បៈត្រូវបំផ្លាញចោល
- ប្រព័ន្ធអប់រំត្រូវបំផ្លាញទាំងស្រុង បាត់បង់ធនធានមនុស្ស

❖ ខាងសេដ្ឋកិច្ច :

- ជាប់និរន្តភាពក្នុងការអភិវឌ្ឍជាតិ
- សេដ្ឋកិច្ចជាតិធ្លាក់ដល់ចំណុចសូន្យ
- ហេដ្ឋារចនាសម្ព័ន្ធត្រូវខ្ទេចខ្ទាំ

❖ ខាងនយោយ :

- បាត់បង់កិត្តិយសជាតិ និងកិត្យានុភាពជាតិលើឆាកអន្តរជាតិ
- សិទ្ធិ សេរីភាព កម្មសិទ្ធិឯកជន តម្រូវការជាមូលដ្ឋានត្រូវបានដកហូត...
- ប្រជាជនបាត់បង់ជំនឿលើអ្នកដឹកនាំ

(មតិផ្សេងទៀត)

វិញ្ញាសាទី២

✍ ចងក្រងឡើងដោយ ម៉ែត ជីវិន ✍

(ដកស្រង់ចេញពីការបង្រៀនក្នុងផេកក្រសួងអប់រំ)

✦ ✦✦ ⊙ ✦✦✦

១. រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបង្កើតនៅឆ្នាំណា ?

ក. រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា បង្កើតឡើងក្នុងបំណងអ្វី ?

ខ. តើរណសិរ្សនេះបានបំពេញបេសកម្មដូចម្តេចខ្លះចំពោះជាតិ មាតុភូមិ ?

២. ចូរពណ៌នាពីវិស័យអប់រំ នៅកម្ពុជាមុន និងក្រោយឆ្នាំ១៩៧៩ ។

៣. តើរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា (រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា) ចាត់វិធានការដូចម្តេចខ្លះ ដើម្បីទប់ស្កាត់ការវិលត្រឡប់នៃរបបប្រល័យពូជសាសន៍ ?

---------- អត្រាកំណែ ----------

១. រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបង្កើតនៅឆ្នាំ ១៩៧៨ (ថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៨) ។

ក. រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា បង្កើតឡើងក្នុងបំណង ៖

- ផ្តួលរំលំរបបកម្ពុជាប្រជាធិបតេយ្យ ដែលជារបបប្រល័យពូជសាសន៍
- រៀបចំស្ថាប្រទេសកម្ពុជាឡើងវិញលើគ្រប់វិស័យ ដោយគោរពឆន្ទៈ និងគោលបំណងរបស់ប្រជាជន
- កសាងប្រទេសកម្ពុជាប្រកបដោយ ឯករាជ្យ សន្តិភាព សេរីភាព និងសុភមង្គល

នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៨ រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ត្រូវបង្កើតឡើងដែលមានសមមិត្ត ហេង សំរិន ជាប្រធាន ។

ខ. រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា បានបំពេញបេសកម្មចំពោះជាតិ មាតុភូមិដូចតទៅ ៖

❖ បេសកម្មចំពោះប្រជាជន

- រំដោះប្រជាជនពីការសម្លាប់រង្គាលនៃរបបប្រល័យពូជសាសន៍ ប៉ុល ពត
- លើកស្ទួយជីវភាពប្រជាជន តាមរយៈ ចែកស្បៀង សម្ភារៈប្រើប្រាស់ បង្កើតក្រុមសាមគ្គីបង្កបង្កើនផល ធ្វើការបែងចែកដីធ្លីដល់ប្រជាជន ផ្តល់សិទ្ធិលើកម្មសិទ្ធិអចសនៈវត្ថុ ដីធ្លី ផ្ទះសម្បែង ...
- ផ្តល់សិទ្ធិសេរីភាព ជំនឿ សាសនា ប្រពៃណី ទំនៀមទម្លាប់ ជូនប្រជាជន
- ផ្តល់នូវសេវាអប់រំ សុខាភិបាល

- ផ្តល់នូវការការពារសណ្តាប់ធ្នាប់ សន្តិសុខ សុវត្ថិភាព

❖ ចំពោះប្រទេសជាតិ

- រំដោះប្រទេសពីរបបកម្ពុជាប្រជាធិបតេយ្យ
- រៀបចំស្តារ និងកសាងជាតិឡើងវិញលើគ្រប់វិស័យស្របតាមឆន្ទៈប្រជាជន
- ធ្វើការទប់ស្កាត់ការវិលត្រឡប់មកវិញនៃរបបប្រល័យពូជសាសន៍
- ធ្វើការដឹកនាំប្រទេសប្រកបដោយឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល
- ធ្វើការអភិវឌ្ឍជាតិក្នុងមាគ៌ាសន្តិភាព
- ស្វែងរកការចរចាដើម្បីបញ្ចប់សង្គ្រាមនៅកម្ពុជា
- ស្តារមុខមាត់ប្រទេសកម្ពុជាលើឆាកអន្តរជាតិ

២. ពណ៌នាពីវិស័យអប់រំ នៅកម្ពុជាមុន និងក្រោយឆ្នាំ១៩៧៩

➢ ស្ថានភាពអប់រំនៅកម្ពុជា និងក្រោយឆ្នាំ១៩៧៩ ៖

❖ មុនឆ្នាំ១៩៧៩ ប្រព័ន្ធអប់រំត្រូវបានបំផ្លាញទាំងស្រុងដោយ:

- បិទទ្វារសាលារៀនគ្រប់ភូមិសិក្សា ដល់ឧត្តមសិក្សា ពីទីក្រុងដល់ជនបទ
- ខ្មែរក្រហមបានប្រែក្លាយសាលារៀនទៅជា ឃ្លាំង រោងបាយ ក្រោលសត្វ មន្ទីរសន្តិសុខ (គុក)
- កុមារ យុវជនក្នុងវ័យសិក្សាត្រូវបានបង្ខំឲ្យធ្វើការបង្កបង្កើនផលជាទម្ងន់ ក្រោមពាក្យស្លោក «កុំរៀនយកសញ្ញាបាត់ (សញ្ញាបត្រ) ត្រូវធ្វើការយកសញ្ញាឃើញ»
- កម្ទេចក្របខណ្ឌគ្រូបង្រៀន មន្ត្រីរដ្ឋការ
- គ្រូបង្រៀន និងបញ្ញាវន្ត អ្នកចេះដឹង ត្រូវបានសម្លាប់ចោល
- ប្រមូលយកនិស្សិតទៅសិក្សានៅបរទេស មកបង្ខំឲ្យធ្វើការបង្កបង្កើនផល ធ្វើទារុណកម្ម និងសម្លាប់ចោល
- អង្គការខ្មែរក្រហមបង្រៀនពីមនោគមវិជ្ជាបដិវត្តន៍ ដោយឲ្យកុមារ ស្រឡាញ់ជឿជាក់ ស្មោះត្រង់ ហ៊ានពលីដើម្បីអង្គការ យកការណ៍ពីឪពុកម្តាយ ពីជួរប្រជាជនជូនអង្គការ

❖ ក្រោយឆ្នាំ១៩៧៩ ប្រព័ន្ធអប់រំត្រូវបានស្តារឡើងវិញដោយ:

- បើកទ្វារសាលាគ្រប់កម្រិត ទទួលសិស្សឲ្យចូលរៀនតាំងពីទីក្រុងដល់ជនបទ

- ធ្វើការជួសជុល និងសាងសង់សាលារៀនបន្ថែម
- ធ្វើការជ្រើសរើស និងបណ្តុះបណ្តាលគ្រូបង្រៀន
- អំពាវនាវឲ្យឪពុកម្តាយ អាណាព្យាបាលយកកូន ក្មួយ ចៅ ទៅសាលារៀន
- ជំរុញ និងបំផុសចលនាអក្ខរកម្ម បំពេញវិជ្ជា
- អនុវត្តនយោបាយ « អ្នកចេះច្រើនបង្រៀនអ្នកចេះតិច អ្នកចេះតិចបង្រៀនអ្នកមិនចេះ »
- បង្កើតអន្តរាសិកដ្ឋានសម្រាប់សិស្ស និស្សិតស្នាក់នៅរៀនសូត្រ
- បញ្ជូនសិស្ស និស្សិតទៅសិក្សានៅបរទេស និងអញ្ជើញគ្រូបរទេសមកបង្ហាត់បង្រៀនកូនខ្មែរនៅក្នុងប្រទេស (មតិផ្សេងទៀត)

៣. រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា (រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា) បានចាត់វិធានការ ដើម្បីទប់ស្កាត់ការវិលត្រឡប់នៃរបបប្រល័យពូជសាសន៍ដូចតទៅ ៖

- បង្កើតកងសេនាជនភូមិ ដើម្បីរក្សាសន្តិសុខ សណ្តាប់ធ្នាប់តាមភូមិ ឃុំ
- បង្កើតក្រុមស្ម័យការពារ ក្រុមយាមកាម ដែលតម្រូវឲ្យសិស្ស និស្សិត មន្ត្រីរដ្ឋការចូលរួម
- បង្កើតកាតព្វកិច្ចយោធា ដែលតម្រូវឲ្យយុវជនចាប់ពីអាយុ១៨ឆ្នាំឡើងទៅចូលបម្រើកងទ័ព
- លើកទ័ពធ្វើការវាយលុកលើកងកម្លាំងសម្ព័ន្ធត្រីភាគី ជាពិសេសលើទ័ពខ្មែរក្រហមនារដូវប្រាំង និងដកទ័ពនារដូវវស្សា
- អនុវត្តផែនការ ក ៥ « កែនកម្លាំងកាប់ឆ្ការព្រៃការពារព្រំដែនកម្ពុជា » ដែលតម្រូវឲ្យប្រជាជនចូលរួមដើម្បី:
  - លើកទំនប់ ធ្វើផ្លូវ តាមបណ្តោយព្រំដែនកម្ពុជា-ថៃ ដើម្បីងាយស្រួលដឹកជញ្ជូនចល័តទ័ព សព្វាវុធ ស្បៀង
  - ធ្វើការកាប់ឆ្ការព្រៃក្បែរភូមិ មាត់ទឹក ជិតផ្លូវថ្នល់ ផ្លូវរថភ្លើង ដើម្បីកម្ទេចជម្រកលាក់ខ្លួនរបស់ខ្មែរក្រហម និង កម្លាំងសម្ព័ន្ធត្រីភាគី
  - ជីកលេណដ្ឋាន ដាំឫស្សី ដាក់ចម្រូង ដាក់មីន

ការអនុវត្តផែនការ ក ៥ នេះបានធ្វើឲ្យពលករខ្មែរស្លាប់ជាច្រើន ដោយសារជំងឺគ្រុនចាញ់ និងជាន់មីន ។

វិញ្ញាសាទី៣

✍ ចងក្រងឡើងដោយ ម៉ែត ជីវិន ✍

(ដកស្រង់ចេញពីការបង្រៀនក្នុងផេកក្រសួងអប់រំ)

✦ ✦✦ ⊙ ✦✦✦

១. តើប្រទេសកម្ពុជាចូលជាសមាជិកអាស៊ានៅឆ្នាំណា ?

២. តើហេតុ ផល (កត្តា)ណាខ្លះដែលបណ្តាលឲ្យរាជរដ្ឋាភិបាលកម្ពុជា សម្រេចចូលជាសមាជិកអាស៊ាន ?

៣. តើប្រទេសកម្ពុជាទទួលបានប្រយោជន៍(អត្ថន័យ)អ្វីខ្លះពីការចូលជាសមាជិកអាស៊ាន ?

៤. ចូរពណ៌នាពីតួនាទីកម្ពុជា នៅក្នុងសហគមន៍អាស៊ាន ?

អត្ថាធិប្បាយ

១. ប្រទេសកម្ពុជាចូលជាសមាជិកអាស៊ាននៅឆ្នាំ ១៩៩៩ (ថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៩) ។

២. កត្តាដែលបណ្តាលឲ្យរាជរដ្ឋាភិបាលកម្ពុជា សម្រេចចូលជាសមាជិកអាស៊ាន ៖

❖ កត្តាមិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់ប្រទេសជាសមាជិក

នេះជាកត្តាចម្បង ដែលទាក់ទាញកម្ពុជាចូលអាស៊ាន ព្រោះអាស៊ានមានគោលការណ៍មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរវាងគ្នា

❖ ស្មារតីសហគមន៍

ស្មារតីសហគមន៍ គឺជាការធ្វើការតាមកុងសង់ស៊ីស គឺប្រទេសជាសមាជិកមានសិទ្ធិស្មើគ្នាទាំងអស់ ប្រទេសមួយសម្លេងមួយ ។ ចំណុចនេះធ្វើឲ្យអាស៊ានមានសាមគ្គីភាព អាស៊ានស្វះស្វែងរកចំណុចរួម ដើម្បីសម្រេចអ្វីដែល អាស៊ានចង់បាន ។

❖ ការអនុវត្តសេដ្ឋកិច្ច-សង្គម ទាក់ទងសមាហរណកម្ម

កម្ពុជានឹងទទួលបានប្រយោជន៍យ៉ាងច្រើន ពីការជំរុញការអភិវឌ្ឍ និងការធ្វើសមាហរណកម្មអាស៊ាន តាមរយៈកាត់បន្ថយគម្លាតរវាងអាស៊ានចាស់ និងអាស៊ានថ្មី ដោយការពន្លឿនការអភិវឌ្ឍប្រទេសដែលជាសមាជិកថ្មី ។

❖ មធ្យោបាយទំនាក់ទំនងការទូតរបស់កម្ពុជា

ការចូលអាស៊ានធ្វើឲ្យកម្ពុជាមានដៃគូច្រើនទាំងក្នុងតំបន់ និងក្នុងពិភពលោក

ដែលជា ច្រកការទូតរបស់កម្ពុជា ជាការពង្រីកអានុភាព និងបង្កើនតួនាទីរបស់កម្ពុជា កាន់តែសកម្មភាពនៅក្នុងតំបន់ផង និងក្រៅតំបន់ផង ។

៣. ប្រទេសកម្ពុជាទទួលបានប្រយោជន៍យ៉ាងច្រើនពីការចូលជាសមាជិកអាស៊ានដូចជា ៖

❖ ខាងផ្នែកនយោបាយ

- កម្ពុជាលែងឯកកោតទៅទៀត
- កម្ពុជាបានឈរស្មើមុខស្មើមាត់ជាមួយប្រទេសជាសមាជិកអាស៊ាន
- បានចូលរួមនូវរាល់ការសម្រេចចិត្តនានាក្នុងតំបន់
- កម្ពុជាមានដៃគូច្រើនទាំងក្នុងតំបន់ និងក្នុងពិភពលោក
- កម្ពុជាបានពង្រីកអានុភាព និងបង្កើនតួនាទីរបស់ខ្លួនកាន់តែមានសកម្មភាពនៅក្នុងតំបន់ និង ក្រៅតំបន់

❖ ខាងផ្នែកទំនាក់ទំនង

- ជំរុញឲ្យមានការកសាងហេដ្ឋារចនាសម្ព័ន្ធ ផ្លូវថ្នល់ ផ្លូវដែក ស្ពាន អាកាសយានដ្ឋាន កំពង់ផែ
- ការលើកលែងទិដ្ឋាការ

❖ ខាងផ្នែកសេដ្ឋកិច្ច

- កម្ពុជាក្លាយជាកន្លែងវិនិយោគដ៏ទាក់ទាញ
- ការធ្វើពាណិជ្ជកម្មងាយស្រួលជាងមុន
- ប្រជាជនអាចរកការងារធ្វើទាំងក្នុងប្រទេស និងក្នុងតំបន់
- កំណើនភ្ញៀវទេសចរដែលបង្កើនការងារ និងប្រាក់ចំណូលដល់ប្រជាជន
- សេដ្ឋកិច្ចកម្ពុជាមានកំណើនរាល់ឆ្នាំ

❖ ខាងផ្នែកសង្គម

- ទទួលបាននូវកិច្ចសហការជាមួយប្រទេសក្នុងតំបន់ក្នុងការរក្សា សន្តិភាព សន្តិសុខសង្គម
- ទប់ស្កាត់ការជួញដូរមនុស្ស គ្រឿងញៀន និងអំពើកេរ្តិ៍ឈ្មោះ
- ការជួយគ្នាទៅវិញទៅមកតាមរយៈការផ្ទេរបទពិសោធន៍ ចំណេះដឹងផ្តល់អាហារូបណ៍ដល់សិស្ស និស្សិត យុវជនកម្ពុជាសិក្សារៀនសូត្រ

៤. ពណ៌នាពីតួនាទីកម្ពុជា នៅក្នុងសហគមន៍អាស៊ានមាន ៖

❖ ខាងនយោបាយ

- គោរពឯករាជ្យ អធិបតេយ្យភាព បូរណភាពទឹកដី របស់ប្រទេសជាសមាជិកអាស៊ាន
- គោរពសមភាព និងមិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងប្រទេសជាសមាជិកអាស៊ាន
- ចូលរួមលើកកម្ពស់ក្នុងការរក្សាសន្តិភាព សន្តិសុខ និងរបុលភាពនៅក្នុងតំបន់
- ចូលរួមដោះស្រាយវិវាទ ឬជម្លោះក្នុងតំបន់និងពិភពលោកដោយមធ្យោបាយសន្តិភាព
- លើកកម្ពស់ក្នុងការដឹកនាំប្រទេសតាមលទ្ធិប្រជាធិបតេយ្យ អភិបាលកិច្ចល្អនីតិរដ្ឋ
- រួមចំណែកក្នុងការសម្រេចកិច្ចការនានា ដោយឈរលើគោលការណ៍កុងសង់ស៊ីស
- កម្ពុជាធ្វើជាប្រធានអាស៊ានប្តូរវេនជាមួយប្រទេសជាសមាជិកអាស៊ាន
  - ឆ្នាំ ២០០២ កម្ពុជាធ្វើជាប្រធានអាស៊ាន ក្រោមមូលបទ « ការឆ្ពោះទៅកាន់សហគមន៍អាស៊ាន »
  - ឆ្នាំ ២០១២ កម្ពុជាធ្វើជាប្រធានអាស៊ាន ក្រោមមូលបទ « សហគមន៍មួយជោគវាសនាមួយ »
  - ឆ្នាំ ២០២២ កម្ពុជាធ្វើជាប្រធានអាស៊ាន ក្រោមមូលបទ « អាស៊ានរួមគ្នាធ្វើ - ដោះស្រាយបញ្ហាប្រឈមទាំងអស់គ្នា »

❖ ខាងសេដ្ឋកិច្ច

- លើកកម្ពស់កិច្ចសហប្រតិបត្តិការ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងតំបន់
- ចូលរួមអភិវឌ្ឍន៍វិស័យពាណិជ្ជកម្ម និងទីផ្សារសេរីដើម្បីប្រកួតប្រជែងជាមួយប្រទេសជឿនលឿន
- លើកកម្ពស់វិស័យផលិតកម្ម ដោយបំពាក់នូវបច្ចេកវិទ្យាទំនើប
- លើកកម្ពស់វិស័យទេសចរណ៍ ដើម្បីបង្កើនការងារ និងប្រាក់ចំណូលជូនប្រជាជន

❖ ខាងសង្គម វប្បធម៌

- អប់រំសិក្សាធិការ ជំរុញការបង្កើនធនធានមនុស្សតាមរយៈ
  - ការផ្ទេរចំណេះដឹង និងផ្លាស់ប្តូរបទពិសោធន៍ វិទ្យាសាស្ត្រ បច្ចេកទេស
  - ការផ្តល់អាហារូបករណ៍ ដល់សិស្ស និស្សិត បន្ត្រី បានសិក្សារៀនសូត្រ

- វប្បធម៌ ជំរុញកិច្ចសហប្រតិបត្តិការផ្នែកវប្បធម៌មាន ប្រពៃណី ទំនៀមទម្លាប់ ជំនឿ សាសនា សិល្បៈ ....រវាងប្រជាជាតិនានាក្នុងតំបន់
- សិទ្ធិ លើកកម្ពស់ការគោរពសិទ្ធិមនុស្ស សមភាពយេនឌ័រ
- លើកកម្ពស់កិច្ចសហប្រតិបត្តិការ ក្នុងការកាត់បន្ថយភាពក្រីក្រ និងធ្វើការអភិវឌ្ឍប្រកបដោយចីរភាព
- ចូលរួមកិច្ចសហប្រតិបត្តិការ ក្នុងការទប់ស្កាត់ ការជួញដូរមនុស្ស គ្រឿងញៀន និងអំពើភេរវកម្ម
- បង្កើនទំនាក់ទំនងល្អ ជាមួយប្រជាជាតិនានានៅក្នុងតំបន់ និងពិភពលោក ។

(មតិផ្សេងទៀត)

វិញ្ញាសាទី៤

✍ ចងក្រងឡើងដោយ ម៉ែត ជីវិន ✍

(ដកស្រង់ចេញពីការបង្រៀនក្នុងផេកក្រសួងអប់រំ)

✦ ✦✦ ⊙ ✦✦✦

១. ចូរពណ៌នាពីចលនាតស៊ូនៅអាស៊ីអាគ្នេយ៍ នាសតវត្សរ៍ទី២០ ។

២. ចូរបង្ហាញថាពីយុទ្ធសាស្ត្រ (កម្មវិធីនយោបាយ) ដួយម៉ឺយ ។

៣. តើដួយម៉ឺយបានជះឥទ្ធិពលយ៉ាងដូចម្តេចខ្លះដល់កម្ពុជា ?

៤. តើអ្វីខ្លះជាប្រភពនៃទំនាស់នៅតំបន់មជ្ឈិមបូព៌ា ?

៥. តើមូលហេតុណាខ្លះដែលបណ្តាលឲ្យប្រទេសអ៊ីស្រាអែលធ្វើសង្គ្រាមឈ្នះពិភពអារ៉ាប់ ?

អត្ថាធិប្បាយ

១. ពណ៌នាពីចលនាតស៊ូនៅអាស៊ីអាគ្នេយ៍ នាសតវត្សរ៍ទី២០ ៖

➢ ចលនាតស៊ូនៅអាស៊ីអាគ្នេយ៍ នាសតវត្សរ៍ទី២០មានពីរូបភាពគឺ ៖

- ចលនាតស៊ូរំដោះជាតិពីអាណានិគម
- ការតស៊ូប្រឆាំងនឹងពួកមូលធននិយមផ្តាច់ការសក្តិភូមិ

❖ ការតស៊ូដើម្បីឯករាជ្យជាតិ ៖

ក្រុមបញ្ញវន្តជាកម្លាំងឈានមុខនៃចលនាតស៊ូទាមទារឯករាជ្យ ដែលមានការចូលរួម ពី កសិករ កម្មករ ឈ្មួញ ពាណិជ្ជករជាតិតូចតាច សិប្បករ ប្រជាជនក្រីក្រ ជាកម្លាំងចលករ ។ ចលនាតស៊ូរំដោះជាតិរបស់ប្រជាជាតិនៅអាស៊ីអាគ្នេយ៍មានជាពីរសណ្ឋានគឺ ៖

- ការតស៊ូដោយអាវុធ (ហឹង្សា)
- ការតស៊ូដោយសន្តិវិធី (អហឹង្សា)
  - ការតស៊ូដោយហិង្សា ៖ គឺជាចលនាតស៊ូដោយប្រើអាវុធ ប្រយុទ្ធបង្ហូរឈាម ដើម្បីទាមទារឯករាជ្យ ដូចជា ចលនាតស៊ូរបស់ខ្មែរឥស្សរៈ នៅកម្ពុជា ចលនាតស៊ូរបស់ វៀតមិញ នៅវៀតណាមខាងជើង ចលនាតស៊ូរបស់ឡាវឥស្សរៈ...
  - ការតស៊ូដោយអហិង្សា ៖ គឺជាចលនាតស៊ូដោយសន្តិវិធី តាមរយៈមធ្យោបាយការទូត ដោយធ្វើការចរចា ពុំមានការប្រយុទ្ធបង្ហូរឈាម ដូចជា ព្រះរាជបូជនីយកិច្ច ទាមទារឯករាជ្យរបស់ព្រះបាទ នរោត្តម សីហនុ...

❖ ការតស៊ូប្រឆាំងនឹងពួកមូលធននិយមផ្តាច់ការសក្តិភូមិ

ការតស៊ូ ប្រឆាំងនឹងពួក មូលធននិយមផ្តាច់ការសក្តិភូមិ របស់ប្រជាជាតិនៅអាស៊ីអាគ្នេយ៍ ដែលមានពីរនិន្នាការគឺ ៖

- ក្រុមនិន្នាការប្រជាធិបតេយ្យសេរីនិយម
- ក្រុមនិន្នាការបដិវត្តន៍ប្រជាធិបតេយ្យកុម្មុនីស្តនិយម
  - ក្រុមនិន្នាការប្រជាធិបតេយ្យសេរីនិយម ៖
    - ⇨ ទិសដៅ ៖ ធ្វើកំណែទម្រង់ដោយកសាងនយោបាយ សេដ្ឋកិច្ច សង្គម ដើម្បីបម្រើឲ្យផលប្រយោជន៍ គហបតីជាតិ
    - ⇨ ការទាមទារ ៖ ក្រុមគហបតីប្រជាធិបតេយ្យសេរីនិយមបានទាមទារឲ្យ:
      - ✓ មានការយកចិត្តទុកដាក់ចំពោះវឌ្ឍនភាពឧស្សាហកម្មជាតិ បង្កើតប្រព័ន្ធសិក្សាធិការតាមបទពិសោធន៍នៃប្រទេសលោកខាងលិច
      - ✓ មានកំណែទម្រង់រចនាសម្ព័ន្ធរដ្ឋ និងសេដ្ឋកិច្ច បង្កើតឲ្យមានប្រព័ន្ធដឹកនាំទៅតាមច្បាប់ រដ្ឋធម្មនុញ្ញ ធ្វើទំនើបកម្មនៅក្នុងវិស័យយោធា និងវិស័យផ្សេងៗ
  - ក្រុមនិន្នាការបដិវត្តន៍ប្រជាធិបតេយ្យកុម្មុយនិស្តនិយម

    ឥទ្ធិពលនៃបក្សកុម្មុយនិស្តពិភពលោក បានធ្វើឲ្យលេចឡើងនូវបក្សកុម្មុយនីស្តក្នុងប្រទេសនានានៅអាស៊ីអាគ្នេយ៍ ។
    - ⇨ ទិសដៅ ៖ ប្រឆាំងពួកអាណានិគមដើម្បីឯករាជ្យ និងធ្វើបដិវត្តន៍ ប្រជាធិបតេយ្យផ្តួលរំលំ អំណាចសក្តិភូមិ មូលធននិយម
    - ⇨ ការទាមទារ ៖ កសាងអំណាចប្រជាជន និងមូលដ្ឋានកុម្មុយនីស្តនិយម (របបសង្គមនិយម) ។

២. កំណែទម្រង់ដួយម៉ឺយ បានដាក់ចេញនូវកម្មវិធីនយោបាយដូចតទៅ:

❖ ផ្នែកនយោបាយ

- រក្សាយន្តការនយោបាយបក្សកុម្មុយនីស្តជាអ្នកដឹកនាំ ដើម្បីរក្សាស្ថិរភាពនយោបាយក្នុងសង្គម
- កសាងទំនាក់ទំនងល្អលើ នយោបាយការបរទេសដោយមិនប្រកាន់ និន្នាការនយោបាយទាំងក្នុងតំបន់ និងលើពិភពលោក

- ជំរុញប្រទេសវៀតណាមឲ្យ រួចផុតពីការហ៊ឹមព័ទ្ធ និងការដាក់ទណ្ឌកម្មខាងសេដ្ឋកិច្ច
- ជំរុញការធ្វើសមាហរណកម្ម នយោបាយ និងសេដ្ឋកិច្ចលើពិភពលោក ។

❖ ផ្នែកសេដ្ឋកិច្ច

- កំណែទម្រង់រ៉ាឌីកាល់ទៅលើវិចនាសម្ព័ន្ធសេដ្ឋកិច្ចទាំងស្រុង
- ផ្តល់លទ្ធភាពដល់សហគ្រិន ធ្វើសកម្មភាពនៅប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី
- ឆ្នាំ១៩៨៧ បើកចំហរជើងមេឃ ដោយបានអនុម័តសម្រាប់វិនិយោគ ផ្តល់ជំនឿទុកចិត្ត ដើម្បីទាក់ទាញវិនិយោគទុនបរទេស
- ឆ្នាំ១៩៨៨ - ១៩៩០ ឧស្សាហកម្ម និងសហគ្រាសរដ្ឋបានរៀបចំកែប្រែ រចនាសម្ព័ន្ធដឹកនាំសម្របទៅនឹងប្រព័ន្ធទីផ្សារសេរី ដើម្បីប្រកួតប្រជែងនឹងសហគ្រាសឯកជន
- បង្កើនផលិតផលកសិកម្ម
- ឆ្នាំ១៩៩៦ មហាសន្និបាត បក្សកុម្មុយនីស្តវៀតណាមបានជំរុញការធ្វើទំនើបកម្មសេដ្ឋកិច្ច ដោយធ្វើឲ្យសេដ្ឋកិច្ចមានកំណើនពី១០-១២% ក្នុងមួយឆ្នាំ

❖ ផ្នែកសង្គម

- ធ្វើទំនើបកម្មសង្គម ដើម្បីឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែង
- ធ្វើកំណែទម្រង់វិស័យអប់រំសិក្សាធិការ សុខាភិបាល ការបណ្តុះបណ្តាលធនធានមនុស្ស
- លើកស្ទួយកម្រិតជីវភាពប្រជាជន ។

៣. ជួយម៉ឺយបានជះឥទ្ធិពលដល់កម្ពុជា ដូចជា ៖

- ផ្លាស់ឥរិយាបថនយោបាយការបរទេសចំពោះកម្ពុជា
- ដកជំនាញការវៀតណាមចេញពីកម្ពុជា
- ប្រកាស និងដកទ័ពចេញពីកម្ពុជាឆ្នាំ ១៩៨៩
- ជាឱកាសល្អដល់កម្ពុជាចរចាគ្នាបញ្ចប់សង្គ្រាម

៤. ប្រកពនៃទំនាស់នៅតំបន់មជ្ឈិមបូព៌ាបណ្តាលមកពី ៖

❖ កត្តាពូជសាសន៍ ៖ នៅក្រោយសង្គ្រាមលោកលើកទី១ អង់គ្លេសបង្កើតមជ្ឈមណ្ឌលជនជាតិជ្វីប ក្នុងទឹកដី រដ្ឋប៉ាលេស្ទីន ហើយនៅក្រោយសង្គ្រាមលោកលើកទី២ (១៩៤៧) អង្គការសហប្រជាជាតិទទួលស្គាល់រដ្ឋអ៊ីស្រាអែល (ជ្វីប) ដែលជាបុព្វហេតុនាំឲ្យមានទំនាស់ ។

- កត្តាសាសនា ៖ ពួកមជ្ឈិមបូព៌ាភាគច្រើនកាន់សាសនា អ៊ីស្លាម តែអ៊ីស្រាអែលដែលជាអ្នកបង្កើតសាសនា យេស៊ូគ្រិស្ត បែរជាកាន់សាសនា អ៊ីយ៉ាវ៉ែ ឯពួកអារ៉ាប់មិនចង់ឲ្យមានសាសនាផ្សេងក្នុងពិភពអារ៉ាប់នោះទេ ។
- កត្តាធនធានធម្មជាតិ (ប្រេងកាត) ៖ តំបន់មជ្ឈិមបូព៌ាសម្បូរទៅដោយរ៉ែ ប្រេងកាត ដែលបណ្តាលឲ្យប្រទេសនានា នៅអារ៉ាប់ និងប្រទេសមហាអំណាចដណ្តើមគ្នា (ទំនាស់ប្រយោជន៍) លើទ្រព្យដ៏មហាសាលនេះ ។

៥. មូលហេតុដែលបណ្តាលឲ្យប្រទេសអ៊ីស្រាអែលធ្វើសង្គ្រាមឈ្នះពិភពអារ៉ាប់ ៖

- កត្តាសាមគ្គី ៖ ជនជាតិអ៊ីស្រាអែល(ជ្វីប) ទាំងក្នុង និងក្រៅប្រទេស ទាំងប្រុស ទាំងស្រីសាមគ្គីគ្នាការពារប្រទេស (ឧ. សង្គ្រាម៦ថ្ងៃជាមួយអេហ្ស៊ីប)
- កត្តាខាងក្រៅ ៖ ជនជាតិអ៊ីស្រាអែល(ជ្វីប) ដែលរស់នៅក្រៅប្រទេសមាន មនសិការស្នេហាជាតិយ៉ាងមុតមាំ ភាគច្រើនជាអ្នកមាន (សេដ្ឋី) ពួកគេជួយគ្រប់មធ្យោមបាយដល់អ្នកនៅក្នុងប្រទេស ដូចជា ស្បៀង សព្វាវុធ ហិរញ្ញវត្ថុ ....
- មហាអំណាច ៖ នៅពីក្រោយខ្នងអ៊ីស្រាអែល មានសហរដ្ឋអាមេរិក អង់គ្លេស បារាំង (ឧ. សង្គ្រាមអ៊ីរ៉ាក់ និងកូវ៉ែត ពួកមហាអំណាចចាំជួយអ៊ីស្រាអែល ឯអ៊ីស្រាអែលក៏ជួយមហាអំណាចវិញ ។

ខ្ញុំគ្រាន់តែលឺ ខ្ញុំនឹងភ្លេច បើបានឃើញ ខ្ញុំនឹងចាំ បើបានធ្វើ ខ្ញុំនឹងយល់

.....ខុងជឺ.....

វិញ្ញាសាទី៥

✍ ចងក្រងឡើងដោយ ម៉ែត ជីវិន ✍

(ដកស្រង់ចេញពីការបង្រៀនក្នុងផេកក្រសួងអប់រំ)

✦ ✦✦ ⊙ ✦✦✦

១. តើសហរដ្ឋអាមេរិក ចក្រភពអង់គ្លេស សាធារណរដ្ឋបារាំងដើរតួនាទីយ៉ាងសំខាន់ដូចម្តេចខ្លះ នៅលើពិភពលោក ?

២. ចូរបង្ហាញពីហេតុ ផល នៃការអនុវត្តផែនការម៉ាសាល់របស់សហរដ្ឋអាមេរិក ។

៣. ចូរបង្ហាញពីលទ្ធផលនៃកំណែទម្រង់ពេរ៉េស្រ្តូយការនៅសហភាពសូវៀត (ចូរបង្ហាញការដួលរលំនៃសហភាពសូវៀត) ។

៤. តើបញ្ហាអ្វីខ្លះ ដែលបានគំរាមគំហែងដល់ការរស់នៅ និងសេចក្តីសុខក្សេមក្សាន្តរបស់មនុស្សជាតិ នៅលើសកលលោក ?

អត្ថាកំណែ

---

១. តួនាទីអាមេរិក ចក្រភពអង់គ្លេស សាធារណរដ្ឋបារាំងនៅលើពិភពលោកមាន ៖

- ជាប្រទេសនាំមុខគេខាងមនោគមវិជ្ជាសេរី (មូលធននិយម)
- ជាប្រទេសនាំមុខគេខាងលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស
- ជាអ្នកផ្តល់ជំនួយអភិវឌ្ឍន៍ដល់ប្រទេសនានាលើពិភពលោក ក្នុងមាគ៌ាសន្តិភាព
- ជាសមាជិកអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ដែលមានតួនាទីរក្សាសន្តិសុខ សន្តិភាព និងភាពរុងរឿងជូនពិភពលោក ។

២. បង្ហាញពីហេតុផល នៃការអនុវត្តផែនការ ម៉ាសាល់របស់សហរដ្ឋអាមេរិក ៖

❖ ផែនការម៉ាសាល់ (Marshall) ប្រកាសឡើងដោយលោកម៉ាសាល់ (Marshall រដ្ឋមន្ត្រីការបរទេស សហរដ្ឋអាមេរិក) នៅសាកលវិទ្យាល័យហាវើត (HAWARD) នាថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ១៩៤៧

❖ ហេតុ នៃការអនុវត្តផែនការម៉ាសាល់

- ហេតុផលមនុស្សធម៌: សហរដ្ឋអាមេរិកផ្តល់ជំនួយដើម្បី ៖
  - ជួយដល់ប្រជាជន និងរដ្ឋាភិបាលនៅ អឺរ៉ុបក្នុងការដោះបំណុល ដោះស្រាយជម្រកកង្វះចំណីអាហារ កង្វះថាមពល កង្វះសម្លៀកបំពាក់ បញ្ហាជនភៀសខ្លួន

- ជួយស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធ ដែលត្រូវបំផ្លាញដោយសង្គ្រាម
- ហេតុផលសេដ្ឋកិច្ច: អាមេរិកបានសម្លឹងឃើញប្រយោជន៍ខាងសេដ្ឋកិច្ច ៖
  - ទ្វីបអឺរ៉ុបនឹងក្លាយជាទីផ្សារសម្រាប់ទំនិញអាមេរិក
  - ទ្វីបអឺរ៉ុបនឹងក្លាយជាដៃគូពាណិជ្ជកម្មរបស់អាមេរិក
- ហេតុផលនយោបាយ: ជាហេតុផលចម្បង របស់សហរដ្ឋអាមេរិក ៖
  - ការទប់ស្កាត់ការរីកសាយនៃចលនាកុម្មុយនីស្តយ៉ាងឆាប់រហ័ស និងលើពិភពលោក
  - ការពង្រីកឥទ្ធិពលរបស់សហរដ្ឋអាមេរិកលើទ្វីបអឺរ៉ុប

❖ ផលនៃការអនុវត្តផែនការនេះបានធ្វើឲ្យ

- ខាងសង្គម ៖ ជួយប្រជាជននៅអឺរ៉ុបខាងលិចឲ្យរួចផុតពីកង្វះអាហារ និងតម្រូវការចាំបាច់ផ្សេងៗ
- ខាងសេដ្ឋកិច្ច
  - ជួយធ្វើទំនើបកម្មឧស្សាហកម្ម និងរបៀបធ្វើជំនួញតាម គំរូសហរដ្ឋអាមេរិក
  - ជួយសេដ្ឋកិច្ចអឺរ៉ុបខាងលិចឲ្យលូតលាស់ និងរួចចាកផុតពីវិបត្តិធ្ងន់ធ្ងរ
- ខាងនយោបាយ
  - អាចទប់ស្កាត់បាននូវការរីកសាយនៃឥទ្ធិពលកុម្មុយនីស្តអឺរ៉ុបខាងលិច
  - សហភាពសូវៀតមិនសប្បាយចិត្ត ព្រោះមានទិសដៅទប់ស្កាត់កុម្មុយនីស្ត
  - ទ្វីបអឺរ៉ុបចែកជាពីរគឺអឺរ៉ុបខាងលិច (ប្លុកខាងលិច) និងអឺរ៉ុបខាងកើត(ប្លុកខាងកើត)

ផែនការម៉ាសាល់បានបិទបញ្ចប់ត្រឹមឆ្នាំ១៩៥២ ។

❖ អាមេរិកបានប្រយោជន៍យ៉ាងច្រើន ពីការអនុវត្តផែនការម៉ាសាល់ដូចជា ៖

- ខាងសង្គម(មនុស្សធម៌) ៖ ការស្រោចស្រង់ប្រជាជនអឺរ៉ុបខាងលិច ពីកង្វះអាហារ កង្វះសម្លៀកបំពាក់ បាត់បង់ជម្រក ធ្វើឲ្យពិភពលោកមើលឃើញថារដ្ឋាភិបាល និងប្រជាជនសហរដ្ឋអាមេរិកប្រកបដោយ មនុស្សធម៌
- ខាងសេដ្ឋកិច្ច ៖ អឺរ៉ុបក្លាយជាទីផ្សារដ៏ធំ របស់សហរដ្ឋអាមេរិកនិង អឺរ៉ុបក្លាយជាដៃគូពាណិជ្ជកម្មដ៏ល្អ របស់សហរដ្ឋអាមេរិក
- ខាងនយោបាយ

- អាមេរិកទប់ស្កាត់ការរីកសាយ នៃឥទ្ធិពលកុម្មុយនីស្តនៅអឺរ៉ុបខាងលិចបាន
- សហរដ្ឋអាមេរិកមានឥទ្ធិពលទៅលើអឺរ៉ុបខាងលិច

៣. ការអនុវត្តកំណែទម្រង់ពេរ៉ែស្រ្តយកា បានធ្វើឲ្យសហភាពសូវៀត និងអឺរ៉ុបខាងកើត ផ្លាស់ប្តូរបបនយោបាយ សេដ្ឋកិច្ច សង្គម ស្ទើរតែស្រុងដូចតទៅ ៖

❖ ការផ្លាស់ប្តូរបបនយោបាយ

- ប្រទេសក្រោមរណបសូវៀតបានងាកដើរតាមលទ្ធិប្រជាធិបតេយ្យបែបអឺរ៉ុបខាងលិច ប្រទេសក្រោមរណបសូវៀតបានប្រកាសឯករាជ្យដូចជា អាល្លឺម៉ង់ខាងកើត ហុងគ្រី ឆេកូស្លូវ៉ាគី ប៊ុលហ្គារី ប៉ូឡូញ
- រដ្ឋចំនួនបីនៅមាត់សមុទ្របាល់ទិកបានផ្តាច់ចេញពីសហភាពសូវៀតដូចជា អេស្តូនី (Estonia) ឡែតតូនី (Lettonie=Latvia) លីទុយអានី (Lithuania)
- ប្រទេសអាល្លឺម៉ង់រួបរួមជាអាល្លឺម៉ង់តែមួយ (ថ្ងៃទី៣ ខែតុលា ឆ្នាំ១៩៩០)
- អង្គការសម្ព័ន្ធភាពវ៉ាសូវី (កតិកាសញ្ញាវ៉ាសូវី) អស់ប្រសិទ្ធភាព នៅថ្ងៃទី ១ខែកក្កដា ឆ្នាំ១៩៩១
- កងទ័ពក្រហមសូវៀត បានដកចេញពីអឺរ៉ុបខាងកើតពីឆ្នាំ ១៩៩១-១៩៩៤
- លោក មីខាអ៊ីល ហ្គោបាឆូវ បានបាត់បង់តួនាទី (ថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ១៩៩១)
- សហភាពសាធារណរដ្ឋសង្គមនិយមសូវៀតបាត់ឈ្មោះលើឆាកអន្តរជាតិ ដោយប្តូរទៅជាសហព័ន្ធរុស្ស៊ី
- បញ្ហាជនជាតិបានកើតឡើងដើម្បីទាមទារឯករាជ្យពិសេសរដ្ឋមួយចំនួននៅអាស៊ីកណ្តាល តំបន់បាល់កង់ (ជនជាតិស៊ែប និងក្រូអាត)

❖ ការផ្លាស់ប្តូរខាងសេដ្ឋកិច្ច

- អង្គការពាណិជ្ជកម្ម កូមេកុងត្រូវបញ្ចប់ (ថ្ងៃទី ២៨ខែមិថុនា ឆ្នាំ១៩៩១)
- របបសេដ្ឋកិច្ចទីផ្សារសេរីបានចូលមកជំនួសរបបសេដ្ឋកិច្ចផែនការ សេដ្ឋកិច្ចសមូសភាព
- សហភាពសូវៀត និងអឺរ៉ុបខាងកើតទទួលយកទុនវិនិយោគពីបស្ចិមប្រទេស

❖ ការផ្លាស់ប្តូរខាងសង្គម

- ប្រជាជនមានសេរីភាពជាងមុន បានរួមចំណែកក្នុងការកសាងជាតិ បានបញ្ចេញ មតិយោបល់
- សេរីភាពសារព័ត៌មាន មានលក្ខណៈល្អប្រសើរជាងមុន
- ប្រជាជនទទួលបាន នូវសិទ្ធិនៃកម្មសិទ្ធិ និងមានជីវភាពធូរធារជាងមុន ។

៤. បញ្ហាដែលបានគំរាមគំហែងដល់ការរស់នៅ និងសេចក្តីសុខក្សេមក្សាន្តរបស់មនុស្សជាតិ ទូទៅលើសកលលោកមាន ៖

- បញ្ហាបរិស្ថាន ៖ បម្រែបម្រួលអាកាសធាតុ គ្រោះធម្មជាតិ(គ្រោះរាំងស្ងួត កំណើនកំដៅផែនដី ភ្លើងឆេះព្រៃ រញ្ជួយដី ព្យុះភ្លៀង ទឹកជំនន់) សម្រាម...
- បញ្ហាកំណើនប្រជាជន ៖ ឧបត្ថម្ភថាមពល សុវត្ថិភាពស្បៀង ភាពក្រីក្រ ជនអន្តោប្រវេសន៍
- បញ្ហាជនអន្តោប្រវេសន៍ ៖ ការជួញដូរមនុស្ស ជួញដូរផ្លូវភេទ គ្រឿងញៀន ពលកម្មលើកុមារ
- បញ្ហាសន្តិសុខស្បៀង ៖ កង្វះស្បៀងចោទជាបញ្ហានាំមកនូវភាពក្រីក្រ និងគ្រោះទុក្ស
- បញ្ហាភេរវកម្មអន្តរជាតិ ៖ ការធ្វើឃាតមេដឹកនាំ ការបំផ្ទុះគ្រាប់បែក...
- ឧក្រិដ្ឋកម្មឆ្លងដែន ៖ ការជួញដូរគ្រឿងញៀន ជួញដូរមនុស្ស ធ្វើចរាចរណ៍ ក្រដាសប្រាក់ក្លែង ក្លាយ ការជំរិតទារប្រាក់តាមប្រព័ន្ធអ៊ីនធឺណែត។

សំណួរ និង ចម្លើយជ្រើសរើស

📖 ប្រទេសកម្ពុជាក្រោមអាណាព្យាបាលបារាំង

១. តើព្រះរាជាខ្មែរ អង្គណាដែលស្វែងរកកិច្ចការពារពីបារាំង ?

⇨ ព្រះរាជាខ្មែរ ដែលបានស្វែងរកកិច្ចការពារពីបារាំងគឺ ព្រះបាទ អង្គដួង ។

២. តើព្រះរាជាណាខ្លះ បានសោយរាជ្យក្នុងសម័យអាណានិគមនិយមបារាំង ?

⇨ ព្រះរាជា ដែលបានសោយរាជ្យក្នុងសម័យអាណានិគមនិយមបារាំងរួចមាន ៖

- ព្រះបាទនរោត្តម (១៨៦០ - ១៩០៤)
- ព្រះបាទស៊ីសុវត្ថិ (១៩០៤ - ១៩២៧)
- ព្រះបាទស៊ីសុវត្ថិ មុនីវង្ស (១៩២៧ - ១៩៤១)
- ព្រះបាទនរោត្តម សីហនុ (១៩៤១ - ១៩៥៥) ។

៣. តើពាក្យអាណាព្យាបាល និងអាណានិគម មានន័យដូចម្តេច ?

⇨ ពាក្យអាណាព្យាបាល គឺជាប្រព័ន្ធគ្រប់គ្រងមួយ ដែលមានប្រទេសជាម្ចាស់ស្រុកមានស្វ័យភាពក្នុងការគ្រប់គ្រង ប្រព័ន្ធរដ្ឋបាលរបស់ខ្លួន ។ ចំណែកឯប្រទេសអាណាព្យាបាលវិញ គឺមានតួនាទី ត្រឹមតែជាទីប្រឹក្សាប៉ុណ្ណោះ ។

⇨ ពាក្យអាណានិគម គឺជាប្រព័ន្ធគ្រប់គ្រងមួយ ដែលប្រទេសជាម្ចាស់ស្រុកពុំមានសិទ្ធិស្វ័យភាព ក្នុងការគ្រប់គ្រងលើប្រព័ន្ធរដ្ឋបាលរបស់ខ្លួនទេ ។ ប្រព័ន្ធរដ្ឋបាលនេះ ត្រូវបានគ្រប់គ្រងដោយប្រទេសដែលបានដាក់អាណានិគម ។

៤. តើសន្និសីទ ក្រុងហ្សឺណែវ បានចាប់ផ្តើម នៅថ្ងៃណា ខែណា ឆ្នាំណា ? តំណាងដោយប្រទេសប៉ុន្មាន ? ហើយបានអនុម័តលើកិច្ចព្រមព្រៀង សេចក្តីថ្លែងការណ៍ទាក់ទងនឹងកម្ពុជាដូចម្តេច ?

⇨ សន្និសីទ ក្រុងហ្សឺណែវ បានចាប់ផ្តើមនៅថ្ងៃទី ២៦ ខែមេសា ឆ្នាំ១៩៥៤ តំណាងដោយប្រទេសចំនួន ១៩ប្រទេស ។ បានអនុម័តលើកិច្ចព្រមព្រៀង សេចក្តីថ្លែងការណ៍ទាក់ទងនឹងកម្ពុជាដូចជា ៖

- កម្ពុជាជារដ្ឋអធិបតេយ្យតែមួយគត់ដែលពុំអាចបំបែកបាន
- សហគមន៍អន្តរជាតិ ទទួលស្គាល់ឯករាជ្យ អធិបតេយ្យភាព បូរណភាពទឹកដីនៃកម្ពុជា
- កម្ពុជាត្រូវអនុវត្តនយោបាយអព្យាក្រឹតតាមការស្នើសុំរបស់សូវៀត និងចិន
- ការបញ្ឈប់សកម្មភាពយោធានានាត្រឹមថ្ងៃទី ៧ សីហា ១៩៥៤

- ការដកទ័ពបរទេសចេញពីកម្ពុជាក្នុងកំឡុង ៩០ថ្ងៃ
- ការរំសាយកងកម្លាំងខ្មែរឥស្សរៈ ក្នុងកំឡុង៣០ថ្ងៃ និងការរួបរួមជាតិកម្ពុជា ។

៥. តើសន្ធិសញ្ញាអាណាព្យាបាលបារាំង-ខ្មែរ ថ្ងៃទី ១១ សីហា ១៨៦៣ មានអត្ថន័យដូចម្តេចខ្លះ?

តើសន្ធិសញ្ញានេះផ្តល់ផលវិបាកដូចម្តេចខ្លះចំពោះភាគីទាំងពីរ ?

⇨ សន្ធិសញ្ញាអាណាព្យាបាលបារាំង-ខ្មែរ ថ្ងៃទី១១ សីហា ១៨៦៣ មានអត្ថន័យ ៖

❖ ភាគីបារាំង : ព្រះចៅអធិរាជបារាំងបាន ៖

- ផ្តល់នូវកិច្ចការពារចំពោះព្រះរាជាកម្ពុជា
- រក្សាសណ្តាប់ធ្នាប់ និងភាពស្ងប់ស្ងាត់ក្នុងប្រទេស
- ការពារប្រទេសកម្ពុជាពីការវាយប្រហារពីប្រទេសខាងក្រៅ
- ជួយកម្ពុជាក្នុងការទារពន្ធដារ ពាណិជ្ជកម្ម និងស្ថាបនាគមនាគមន៍

❖ ភាគីកម្ពុជា : ព្រះរាជាខ្មែរបានផ្តល់សិទ្ធិដល់បារាំងដូចជា ៖

- ផ្តល់នូវកិច្ចការពារជនជាតិបារាំង និងអ្នកផ្សាយសាសនាកាតូលិក
- ផ្តល់ទីតាំង និងការបង្កើតសាលាក្តី
- អនុញ្ញាតឲ្យបារាំងកាប់ឈើធ្វើនាវា និងធ្វើពាណិជ្ជកម្ម
- អនុញ្ញាតិឲ្យបារាំងដាក់តំណាងខ្លួនអមព្រះរាជាខ្មែរ

⇨ សន្ធិសញ្ញាអាណាព្យាបាលបារាំងខ្មែរ បានផ្តល់នូវផលវិជ្ជមាន និងអវិជ្ជមានចំពោះកម្ពុជា៖

❖ ភាគីបារាំង :

➢ ផលវិជ្ជមាន

- បារាំងមានសិទ្ធិអំណាចក្នុងការគ្រប់គ្រងកម្ពុជា
- បារាំងមានសិទ្ធិធ្វើពាណិជ្ជកម្មនៅកម្ពុជា
- បារាំងមានសិទ្ធិកាប់ឈើធ្វើនាវា និងយកធនធានធម្មជាតិ
- បារាំងទទួលបាននូវការការពារជនជាតិបារាំង និងអ្នកផ្សាយសាសនាកាតូលិកពីអាជ្ញាធរខ្មែរ
- ទទួលបាននូវទីតាំងដែលព្រះរាជាខ្មែរផ្តល់ឲ្យ

➢ ផលអវិជ្ជមាន ៖ បារាំងរងនូវការបះបោរប្រឆាំងពីសំណាក់ប្រជាជនកម្ពុជា ។

❖ ភាគីកម្ពុជា :

- ផលវិជ្ជមាន
  - កម្ពុជាទទួលបាននូវការការពារទឹកដី ពូជសាសន៍ខ្មែរពីសំណាក់បារាំង
  - បារាំងជួយរៀបចំសង្គមខ្មែរឲ្យមានរបៀបរៀបរយធ្វើឱ្យប្រទេសមានសន្តិភាព ជួយកែទម្រង់សង្គមខ្មែរឲ្យល្អប្រសើរ
  - កម្ពុជាមានសិទ្ធិធ្វើពាណិជ្ជកម្ម នៅដែនកូសាំងស៊ីន
- ផលអវិជ្ជមាន
  - នាំឲ្យមានវត្តមានអាណាព្យាបាលបារាំងនៅកម្ពុជា
  - នាំកម្ពុជាទៅរកការបាត់បង់ឯករាជ្យ អធិបតេយ្យភាពជាតិ
  - នាំកម្ពុជាទៅរកការបាត់បង់ធនធានធម្មជាតិ និងវត្ថុកេតនភណ្ឌជាតិ
  - នាំប្រជាជនកម្ពុជាទៅរកទុក្ខវេទនា ដែលកើតចេញពីការគាបសង្កត់ ការប្រមូលពន្ធដារយ៉ាងធ្ងន់ធ្ងរសព្វសារពើ ។

៦. ហេតុអ្វីបានជាមានសន្ធិសញ្ញាបារាំង-សៀមថ្ងៃទី ១៥ កក្កដា ១៨៦៧ ? តើសន្ធិសញ្ញានេះមានអត្ថន័យដូចម្តេចខ្លះ ?

⇨ មូលហេតុដែលបណ្តាលឲ្យមានសន្ធិសញ្ញាបារាំង-សៀមថ្ងៃទី ១៥កក្កដា១៨៦៧ ៖

- បារាំងចង់គ្រប់គ្រងប្រទេសកម្ពុជាតែម្នាក់ឯងដោយពុំមានវត្តមានសៀម
- សៀមមិនចង់ចាកចេញពីកម្ពុជាដោយបាតដៃទទេគឺចង់បានថ្នូរអ្វីមួយពីបារាំង ខាងលើនេះបាននាំទៅរកការព្រមព្រៀងរវាងបារាំង-សៀម ។

⇨ សន្ធិសញ្ញាមានអត្ថន័យដូចតទៅ ៖

❖ ភាគីបារាំង

- បារាំងទទួលស្គាល់ថាទឹកដីខេត្ត មហានគរ(សៀមរាប) បាត់ដំបង សិរីសោភណ្ឌ ស្ថិតក្នុងរាជាណាចក្រសៀម
- បារាំងសន្យាមិនដណ្តើមយករាជាណាចក្រសៀមទៅបញ្ចូលជាកម្មសិទ្ធិរបស់ខ្លួនដូចកូសាំងស៊ីន

❖ ភាគីសៀម

- ទទួលស្គាល់ជាឱឡារឹកនូវអំណាចអាណាព្យាបាលបារាំងលើកម្ពុជា
- ទុកជាមោឃភាពនូវសន្ធិសញ្ញាសៀម-ខ្មែរខែធ្នូ ១៨៦៣

- លែងទទួលរាល់សួយសារអាករ វត្ថុអនុស្សាវរីយ៍ ឬ សញ្ញាផ្សេងៗទៀតនៃភាពចំណុះពីសំណាក់កម្ពុជា ។

៧. តើអនុសញ្ញាបារាំង-ខ្មែរ ថ្ងៃទី១៧ មិថុនា ១៨៨៤ មានទិសដៅដូចម្តេច ? អនុសញ្ញានេះមានអត្ថន័យដូចម្តេចខ្លះ ?

⇨ អនុសញ្ញាបារាំង-ខ្មែរថ្ងៃទី១៧ មិថុនា ១៨៨៤ ធ្វើឡើងដោយបង្ខិតបង្ខំក្រោមផ្លាក កំណែទម្រង់ក្នុងទិសដៅប្រែក្លាយប្រទេសកម្ពុជាពីក្រោមអាណាព្យាបាលទៅជាក្រោមអាណានិគម

⇨ អត្ថន័យនៃអនុសញ្ញាបារាំង-ខ្មែរថ្ងៃទី១៧ មិថុនា ១៨៨៤

- កែទម្រង់រដ្ឋបាល តុលាការ ហិរញ្ញវត្ថុ ពាណិជ្ជកម្ម
- ព្រះរាជានឹងបន្តគ្រប់គ្រងរដ្ឋ និងដឹកនាំរដ្ឋបាល
- រៀបចំថ្នាក់ដឹកនាំខេត្ត ដោយបារាំងផ្ទាល់ (រ៉េស៊ីដង់)
- លុបចោលរបបទាសភាពទាំងស្រុងនៅកម្ពុជា
- ភ្នំពេញគ្រប់គ្រង់ដោយគណៈកម្មការដែលមានសមាសភាព១៥រូប ។

៨. តើមានកត្តាអ្វីខ្លះដែលធ្វើឲ្យបារាំងបានដាក់អាណានិគមមកលើខ្មែរ?

⇨ កត្តាដែលបានធ្វើឲ្យបារាំងបានដាក់អាណានិគមមកលើខ្មែរគឺ ៖

- ដោយសារបារាំងបានចាប់ចិត្តនឹងទេសភាពដ៏ស្រស់ត្រកាលនៅអមច្រាំងទន្លេទាំងសងខាងដែលមានដំណាំរដូវ ដ៏ខៀវស្រងាត់ដូចជា សណ្តែក លូ ពោត និង បន្លែលាយឡំដើមឈើហូបផ្លែជាច្រើនប្រភេទ។
- បារាំងបានយល់ថា ប្រទេសកម្ពុជា គឺជាប្រទេសសម្បូរទន្លេ ដែលជាគមនាគមន៍ ដ៏សំខាន់ជំនួសផ្លូវគោកសម្រាប់ដឹកជញ្ជូនផលិតផលកសិកម្ម ទៅកាន់ទីផ្សារ អឺរ៉ុប។
- កម្ពុជា មានផ្ទៃដីកសិកម្មច្រើន ហើយមានប្រជាជនតិច ដែលអាចឲ្យពួកបារាំងបង្កើតជាដំណាំ កសិកម្មបានផលច្រើន ។
- កម្ពុជាជាប្រទេសសម្បូរទៅដោយព្រៃ និងភ្នំ ប្រកបទៅដោយឈើមានគុណភាព ខ្ពស់ ។
- នៅក្រោមដីសម្បូរទៅដោយរ៉ែ ជាច្រើនប្រភេទ ។

៩. ចូរពណ៌នាពីការបះបោររបស់ប្រជាជនកម្ពុជាក្នុងចន្លោះឆ្នាំ ១៨៨៤-១៨៨៧ ។

⇨ ពណ៌នាពីការបះបោររបស់ប្រជាជនកម្ពុជាក្នុងចន្លោះឆ្នាំ ១៨៨៤-១៨៨៧ ៖

- មូលហេតុនៃការបះបោរ : អនុសញ្ញាឆ្នាំ១៨៨៤ ធ្វើឲ្យព្រះរាជា និងមន្ត្រីខ្មែរបាត់បង់អំណាច

- បំណងនៃការបះបោរ:ទាមទារអំណាចថ្វាយព្រះរាជាខ្មែរ តែពុំមានបំណងទាមទារឯករាជ្យទេ
- ការចរចា :ដោយខ្លាចចលនាបះបោរក្លាយជាចលនាទាមទារឯករាជ្យបារាំងក៏ធ្វើការចរចា
- លទ្ធផល
  - បារាំងសន្យាថាមិនអនុវត្តខ្លឹមសារអនុសញ្ញាឆ្នាំ១៨៨៤
  - ព្រះមហាក្សត្រខ្មែរ និងមន្ត្រីរាជការខ្មែរទទួលបានតួនាទីក្នុងដួបាល
  - រ៉ែស៊ីដង់ជាន់ខ្ពស់បារាំងបន្តការងារជាទីប្រឹក្សាព្រះរាជាដដែរ ។

ថ្ងៃទី១ មករា ១៨៨៧ រដ្ឋបាលខ្មែរត្រូវបានស្តារឡើងវិញ ។

១០. តើមូលហេតុអ្វីខ្លះដែលបណ្តាលឲ្យបារាំងប្រគល់ឯករាជ្យជូនកម្ពុជាវិញ ?

⇨ មូលហេតុដែលបណ្តាលឲ្យបារាំងប្រគល់ឯករាជ្យជូនកម្ពុជាវិញ ៖

❖ បុព្វហេតុកម្ពុជា:

- លេចឡើងនូវចលនាជាតិនិយម ការបំផុសគំនិតជាតិនិយម ការរក្សាវប្បធម៌ សិទ្ធិសេរីភាព និងឯករាជ្យម្ចាស់ការ
- ចលនាខ្មែរឥស្សរៈធ្វើសកម្មភាពដោយអាវុធយ៉ាងខ្លាំងក្លាប្រឆាំងនឹងបារាំង
- ព្រះរាជបូជនីយកិច្ចទាមទារឯករាជ្យរបស់ព្រះបាទនរោត្តម សីហនុ
- ប្រជាជនកម្ពុជាងើបបះបោរគ្រប់ទិសទីក្នុងបំណង:
  - មិនចង់ស្ថិតក្រោមការគាបសង្កត់និងការបង្ខំឱ្យបងពន្ធយ៉ាងធ្ងន់ធ្ងរពីសំណាក់បារាំង
  - ចង់បានសិទ្ធិសេរីភាព ចង់កំណត់ជោគវាសនាជាតិដោយខ្លួនឯង
  - ចង់បានឯករាជ្យ អធិបតេយ្យភាព បូរណភាពទឹកដីជាតិ
  - ចង់រក្សាប្រពៃណី ទំនៀមទម្លាប់ ជំនឿសាសនា វប្បធម៌ជាតិខ្លួន

❖ បុព្វហេតុបារាំង

- បារាំងចុះទន់ខ្សោយនិងជួបវិបត្តិនយោបាយ សេដ្ឋកិច្ច ហិរញ្ញវត្ថុ សង្គម ក្រោយសង្គ្រាម លោកលើកទី២
- បារាំងបរាជ័យលើគ្រប់សមរភូមិនៃសង្គ្រាមទាមទារឯករាជ្យដូចជា សមរភូមិឌៀនបៀនភូ(វៀតណាម ថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៥៤) សមរភូមិនៅប្រទេសអាល់ហ្សេរី(១៩៥៤)

- បារាំងត្រូវគោរពធម្មនុញ្ញអង្គការសហប្រជាជាតិ។

❖ បុព្វហេតុខាងក្រៅ:

- ឥទ្ធិពលនៃសង្គ្រាមត្រជាក់
- លេចឡើងនូវចលនាតស៊ូទាមទារឯករាជ្យគ្រប់ទិសទីទូទាំងពិភពលោក (មតិផ្សេងទៀត)

១១. តើពួកអាណានិគមបារាំងបានជួយកសាងសេដ្ឋកិច្ចវៀតណាមយ៉ាងដូចម្តេចខ្លះ?

⇨ ពួកអាណានិគមបារាំងបានជួយកសាងសេដ្ឋកិច្ចវៀតណាមដូចជា ៖

- ឆ្នាំ១៨៨៨-១៩២៩ បារាំងបានវិនិយោគទុនលើវិស័យអាជីវកម្ម៉ែ និងដំណាំកៅស៊ូ
- បារាំងបានវិនិយោគលើវិស័យផ្សេងទៀតដូចជា ផ្លូវគមនាគមន៍ដែលរួមមាន ការ ដាក់បង្គោលភ្លើងអគ្គិសនីបំភ្លឺទីក្រុង សាងសង់ផ្លូវរថភ្លើងពីក្រុងព្រៃនគរ ទៅទីក្រុងហាណូយ សាងសង់ផ្លូវកៅស៊ូជាដើម
- បារាំងបានបង្កើតប្រព័ន្ធអប់រំដូចជា បង្កើតសាលាបឋមសិក្សា មធ្យមសិក្សា និង ឧត្តមសិក្សានៅទីក្រុងហាណូយ
- បារាំងបានបង្កើតរោងចក សហគ្រាសជាច្រើនដូចជា ម្ហូបអាហារ តម្បាញ ម៉ាស៊ីន កិនស្រូវ អគ្គិសនី រោងចក្រក្រដាស រោងម៉ាស៊ីនអារឈើ និងស្លាកែវជាដើម ។

១២. តើព្រះបាទអង្គឌួងបានធ្វើការទាក់ទងទៅបារាំងចំនួនប៉ុន្មានលើក ? ចូររៀបរាប់ ។

⇨ ព្រះបាទអង្គដួងបានធ្វើការទាក់ទងទៅបារាំងចំនួន២លើក ៖

- លើកទី១៖ ឆ្នាំ១៨៥៣ ព្រះបាទអង្គដួង ផ្ញើព្រះរាជសារចង់សម្ពន្ធភាពជាមួយព្រះ ចៅអធិរាជបារាំង។ ក្នុងព្រះរាជសាមានខ្លឹមសារថា "ពួកបេសកបព្វជិតបានប្រាប់ឲ្យ យើងដឹងថា អធិរាជបារាំងមានចិត្តសប្បុរសធម៌ចំពោះប្រជាជាតិ។ ព្រះអង្គជួយ ការពារប្រជាជាតិទាំងនោះ ដើម្បីធានាស្ថិរភាព និងសុខមាលភាពដោយមិនប៉ះ ពាល់ប្រយោជន៍ម្ចាស់ស្រុក និងថាធម៌រាជបារាំងល្អ ពុំមានការប៉ុនប៉ងដូចព្រះមហា ក្សត្រនានានៃទ្វីបអ៊ឺរ៉ុប ដែលគិតតែជិះជាន់ប្រទេសដទៃក្រៅពីប្រទេសខ្លួន។ យើង មានសេចក្តីរីករាយនឹងចងសម្ពន្ធភាពមួយរឹងមាំ ជាមួយព្រះចៅអធិរាជ ដែលនឹងធ្វើ ឲ្យប្រទេសរបស់យើងធំ និងសម្បូណ៌ ដើម្បីសេចក្តីរុងរឿងរបស់ប្រទេសយើង"។

- លើកទី២៖ ឆ្នាំ១៨៥៦ ព្រះអង្គដួងបានផ្ញើព្រះរាជសារម្តងទៀតដែលសេចក្តីជាអាទិ៍ថា "ចាប់ពីឆ្នាំ១៨៤៦ ស្តេចនៅកូសាំងស៊ីនបានប្រកាសថា បណ្តាខេត្តដែលគេ យកបានពីកម្ពុជានោះ មិនត្រូវស្តាប់បង្គាប់ខ្ញុំ និងមិនត្រូវបង់សួយអាករឲ្យមកខ្ញុំ ទេ។ លើសពីនេះ គេបានរារាំងមិនឲ្យធ្វើពាណិជ្ជកម្មនៅក្នុងប្រទេសខ្ញុំ និងនៅ តាមកំពង់ផែនានា។ នេះហើយជាស្ថានភាពជាក់ស្តែងនៃព្រះរាជាណាចក្រកម្ពុជា សូមព្រះអង្គទទួលស្គាល់ខេត្តទាំងនោះ រួមមាន៖ ខេត្តដូនណៃ (បាត់បងទៅជាង ២០០ឆ្នាំ) និងខេត្តទើបបាត់ទៅថ្មីៗដូចជា ព្រៃនគរ លង់ហោ ផ្សារដែក មេសរ ព្រះត្រពាំង អុងម៉ ក្រមួនស ទឹកខ្មៅ ពាម កោះត្រល់ និងកោះត្រឡាច។ ប្រសិនបើអណ្តាមប្រគល់ខេត្តណាមួយថ្វាយព្រះអង្គ សូមព្រះអង្គកុំទទួល ព្រោះ ជាខេត្តរបស់កម្ពុជាទេ។

📖 របបសង្គមរាស្ត្រនិយម

១៣. ចូរពណ៌នាពីការលេចឡើងនូវរបបសង្គមរាស្ត្រនិយម ។

⇨ ពណ៌នាពីការលេចឡើងនូវរបបសង្គមរាស្ត្រនិយម ៖

- ដ្ឋេធម្មនុញ្ញឆ្នាំ ១៩៤៧ បានក្រឹត្យបញ្ញត្តិអំណាចព្រះរាជាដោយរាល់ព្រះរាជតម្រិះខាងនយោបាយរបស់ព្រះអង្គត្រូវដាក់ឲ្យសភា អនុម័តជាមុនសិនទើបយកទៅបើបាន
- សភាតែងតែជំទាស់នឹងព្រះរាជាតម្រិះរបស់ព្រះរាជា
- ក្រោយបានឯករាជ្យ សង្គមខ្មែរបែកបាក់សាមគ្គីជាតិទាំងក្នុងស្រទាប់ប្រជាជន បញ្ញវន្ត អ្នកនយោបាយទៅតាមការសាបព្រោះនៃមនោគមវិជ្ជា
- ព្រះរាជាចង់បង្រួបបង្រួមជាតិ ផ្សះផ្សាជាតិ ធ្វើឲ្យមានឯកភាពជាតិក្រោមរាជបល្ល័ង្កតែមួយ ។

  កត្តាខាងលើធ្វើឲ្យព្រះបាទនរោត្តម សីហនុជាក់រាជ្យ (៣ មីនា ១៩៥៥) ហើយបង្កើតអង្គការសង្គមរាស្ត្រនិយម (២៣ មីនា ១៩៥៥) និងចូលរួមបោះឆ្នោត (១១ កញ្ញា ១៩៥៥) ទទួលបានជោគជ័យ ៨៣.៨៧% ។

  របបសង្គមរាស្ត្រនិយមចាប់ផ្តើមលេចឡើង ។

១៤. តើកត្តាអ្វីខ្លះដែលនាំឱ្យប្រជាជនមានការជឿជាក់លើគណបក្សសង្គមរាស្ត្រនិយម?

⇨ កត្តាដែលនាំឱ្យប្រជាជនមានការជឿជាក់លើគណបក្សសង្គមរាស្ត្រនិយមពីព្រោះ ៖

- សម្តេច នរោត្តម សីហនុដែលជាស្ថាបនិក និងជាប្រធានមានប្រជាប្រិយ ភាពខ្លាំង ព្រោះប្រជារាស្ត្រទទួលស្គាល់ព្រះអង្គជាបិតាឯករាជ្យជាតិ និង សន្តិភាព
- ភាពរឹងមាំនៃរចនាសម្ព័ន្ធដឹកនាំរបស់«សង្គមរាស្ត្រនិយម.ថ្នាក់មូលដ្ឋាន ៖ កត្តានេះធ្វើឱ្យមានការគាំទ្រពីមហាជនថ្នាក់មូលដ្ឋាន និងមន្ត្រីរាជការដែល ជាកម្លាំងចលករធ្វើឱ្យមានជ័យជម្នះក្នុងការបោះឆ្នោត
- មានឥស្សរជននយោបាយសំខាន់ៗជាច្រើនទៀត បានចូលរួមក្នុង,សង្គម រាស្ត្រនិយម. ដូចជាលោក ស៊ឹម វ៉ារ លោក សឺន សាន ព្រះអង្គម្ចាស់ នរិន្ទ ដេត លោក ញ៉ែម សំបូរ ជាដើម
- មានហិរញ្ញវត្ថុរឹងមាំ ដែលបានមកពីការបរិច្ចាគរបស់សមាជិក និងអ្នក មានទ្រព្យ សម្បត្តិភាគច្រើនក្នុងស្រុក ។

១៥. តើឥស្សរជនណាជាអ្នកបង្កើតអង្គការសង្គមរាស្ត្រនិយម?

ក. ហេតុអ្វីបានជាមានការបង្កើតអង្គការសង្គមរាស្ត្រនិយម?

ខ. តើការបង្កើតអង្គការសង្គមរាស្ត្រនិយម ពិតជាអាចបង្រួបបង្រួមជាតិ ធ្វើឱ្យមានឯកភាពជាតិ បានដែរ ឬទេ ? ព្រោះហេតុអ្វី ?

⇨ អង្គការសង្គមរាស្ត្រនិយមបង្កើតឡើងដោយ សម្តេច នរោត្តម សីហនុ ។

ក . មូលហេតុនៃការបង្កើតអង្គការសង្គមរាស្ត្រនិយម ៖

- រដ្ឋធម្មនុញ្ញឆ្នាំ ១៩៤៧ បានបញ្ជាតិក្រឹត្យអំណាចរបស់ព្រះមហាក្សត្រ ដូចជារាល់ព្រះរាជតម្រិះ ខាងនយោបាយរបស់ព្រះមហាក្សត្រអាចយកទៅអនុវត្តបានត្រូវដាក់ឱ្យ សភាអនុម័តយល់ព្រម ជាមុនសិន
- ឯសភាពុំដែលអនុម័តយល់ព្រមតាមព្រះរាជតម្រិះរបស់ព្រះមហាក្សត្រ
- សង្គមខ្មែរមានការបែកបាក់សាមគ្គីជាតិទាំងនៅក្នុងស្រទាប់ប្រជាជន បញ្ញវន្ត ពិសេស ក្នុងរង្វង់អ្នកនយោបាយ ទៅតាមនិន្នាការមនោគមវិជ្ជាក្នុងបន្ទុះសង្គ្រាមត្រជាក់
- ព្រះបាទ នរោត្តម សីហនុ ចង់ស្ថាបនាជាតិ បង្រួបបង្រួមជាតិ ធ្វើឱ្យមានឯកភាពជាតិ ស្ថិត ក្រោមរាជបល្ល័ង្កតែមួយ

បុព្វហេតុខាងលើនេះធ្វើឱ្យព្រះបាទនរោត្តម សីហនុ ដាក់រាជ្យ(៣ មីនា ១៩៥៥) ហើយបង្កើតអង្គការសង្គមរាស្ត្រនិយម (២៣ មីនា ១៩៥៥) ដោយចូលរួម

បោះឆ្នោត(១១កញ្ញា ១៩៥៥)ប្រកបដោយជោគជ័យ(សម្លេង៨៣.៨៧%) ។របប សង្គមរាស្ត្រក៏កើតឡើង។

ខ . ការបង្កើតអង្គការសង្គមរាស្ត្រនិយម របស់សម្តេចនរោត្តម សីហនុពុំអាចបង្រួបបង្រួមជាតិ ធ្វើឱ្យមានឯកភាពជាតិបានទេ(ឬបានតែរយៈពេលខ្លី) ព្រោះ

- គណបក្សដែលរំលាយខ្លួនចូលជាមួយសង្គមរាស្ត្រ បានតែមួយរយៈប៉ុណ្ណោះ ក៏បានចាកចេញទៅបង្កើតបក្សថ្មី ឬពង្រឹងបក្សរបស់ខ្លួនឡើងវិញ
- ឥស្សរជននយោបាយរបស់សង្គមរាស្ត្រនិយមមួយចំនួន បានចាកចេញទៅបង្កើតបក្សថ្មីមក ប្រឆាំងនឹងសង្គមរាស្ត្រនិយមវិញ
- មានបក្សប្រឆាំងក្នុងសភា ដែលតែងតែប្រឆាំងនឹងគោលនយោបាយសង្គមរាស្ត្រនិយម
- អ្នកនយោបាយបែកបាក់សាមគ្គីគ្នា បង្កើតបានជាខ្មែរច្រើនក្រុម ដូចជា ក្រុមខ្មែរកុម្មុយនីស្ត (ខ្មែរក្រហម) ខ្មែរសេរី (ខ្មែរខៀវ) ក្រុមខ្មែររាជានិយម(ខ្មែរស) ដែលក្រុមទាំងនេះប្រឈម មុខដាក់គ្នាទាំងមនោគមវិជ្ជា និងប្រដាប់អាវុធ
- ខ្មែរសេរីធ្វើការហាត់ទ័ពនៅព្រំដែនកម្ពុជា-ថៃ និងធ្វើការផ្សព្វផ្សាយតាមវិទ្យុប្រឆាំងនឹងសង្គមរាស្ត្រនិយម
- ខ្មែរក្រហមបានពង្រឹងកម្លាំងនៅតាមភូមិភាគឦសាន ឧត្តរ ពាយ័ព្យ និងវាយប្រហារលើកម្លាំង សង្គមរាស្ត្រនិយម
- ក្រុមរបស់លោកលន់ នល់ បានធ្វើរដ្ឋប្រហារទម្លាក់សម្តេចនរោត្តម សីហនុ (១៨មីនា១៩៧០) របបសង្គមរាស្ត្រនិយម ក៏ដួលរំលំ ។

១៦. តើព្រះបាទនរោត្តមសីហនុមានស្នាព្រះហស្តសំខាន់ៗអ្វីខ្លះនៅសម័យសង្គមរាស្ត្រនិយម?

⇨ ព្រះបាទនរោត្តម សីហនុ មានស្នាព្រះហស្តសំខាន់ៗ ដូចតទៅ ៖

- ទាមទារឯករាជ្យពីពួកអាណានិគមបារាំង ជូនជាតិ និងប្រជាជនខ្មែរ
- បង្កើត និងធ្វើឲ្យមានការរីកចម្រើន នៅសម័យសង្គមរាស្ត្រនិយម
- ទាមទារប្រាសាទព្រះវិហារពីថៃ ដែលបានចូលទៅកាន់ កាប់ដោយខុសច្បាប់នៅឆ្នាំ ១៩៥៤
- ប្រារព្ធសមាជជាតិ ធ្វើឲ្យមានការអភិវឌ្ឍជាតិលើគ្រប់វិស័យស្របតាមឆន្ទៈប្រជាជន

- ការអនុវត្តនយោបាយអព្យាក្រឹត បានធ្វើឲ្យប្រទេសជាតិមានសុខសន្តិភាពរយៈពេល ១៥ឆ្នាំ (១៩៥៥-១៩៧០) ស្របពេលដែលប្រទេសជិតខាងជួបនឹងសង្គ្រាម
- កម្ពុជាបានចូលជាសមាជិកអង្គការសហប្រជាជាតិ (១៤ ធ្នូ ១៩៥៥)
- បង្កើតសមិទ្ធផល នៃហេដ្ឋារចនា សម្ព័ន្ធសង្គម សម័យសង្គមរាស្ត្រនិយម ។

១៧. តើសមាជជាតិជាអ្វី ? បង្កើតឡើងនៅថ្ងៃ ខែ ឆ្នាំណា ? តើវាបាននាំមកនូវលទ្ធផលអ្វីខ្លះសម្រាប់ប្រទេសកម្ពុជា ?

⇨ សមាជជាតិ គឺជាស្ថាប័នរដ្ឋ ពោលជាវេទិការនៃលទ្ធិប្រជាធិបតេយ្យដែលតម្រូវឲ្យប្រជាពលរដ្ឋគ្រប់ ស្រទាប់វណ្ណៈ អ្នកនយោបាយគ្រប់និន្នាការ ចូលរួមពិភាក្សា បញ្ចេញមតិយោបល់ដើម្បីស្ថាបនាជាតិ ។ បង្កើតឡើងនៅថ្ងៃ ១៣ មិថុនា ១៩៥៥ និងបញ្ចប់នៅថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ១៩៦៩ ។ សមាជជាតិប្រារព្ធឡើងមួយឆ្នាំ ២ដង ។

❖ សមាជជាតិបាននាំមកនូវលទ្ធផលសម្រាប់ប្រទេសកម្ពុជាដូចជា ៖

- ការប្រឆាំងនឹងអំពើពុករលួយ
- ការអំណត់ភាសាខ្មែរជោគភាសាផ្លូវការ
- សភាតំណាងរាស្ត្រមានសិទ្ធិចូលរួមក្នុងការកែលម្អសកម្មភាពរដ្ឋបាល និងទាមទារឲ្យដាក់ទណ្ឌកម្មចំពោះមន្ត្រីអសកម្ម
- ស្ត្រីមានសិទ្ធិបោះឆ្នោត (៦ មករា ១៩៥៨) ។

🕮 របបសង្គមសាធារណរដ្ឋខ្មែរ

១៨. តើហេតុអ្វីបានជាកងទ័ពអាកាសរបស់សហរដ្ឋអាមេរិក បានទម្លាក់គ្រាប់បែ ៥២ (B-52) យ៉ាងខ្លាំងមកលើប្រទេសកម្ពុជា ? ចាប់ពី ពេលណា?

⇨ បានជាកងទ័ពអាកាសរបស់ សហរដ្ឋអាមេរិក បានទម្លាក់គ្រាប់បែ ៥២ (B-52) យ៉ាងខ្លាំងមកលើប្រទេសកម្ពុជា គឺដោយសារតែសហរដ្ឋអាមេរិក ខ្លាចប្រទេសវៀតណាម ខាងត្បូង ដែលអាច ឲ្យកងទ័ពអាមេរិក មិនអាចដកខ្លួន ពីវៀតណាមបាន។ ការទម្លាក់ នេះបានចាប់ផ្តើម ពីថ្ងៃទិ ០៦ ខែ កុម្ភៈដល់ ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ១៩៧៣ ។

១៩. តើការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកនាំមកនូវផែលប៉ះពាល់អ្វីខ្លះដល់កម្ពុជា ?

⇨ ការទម្លាក់គ្រាប់បែកនេះនាំមកនូវផែលប៉ះពាល់ដល់កម្ពុជាដូចជា ៖

❖ ផ្នែកសង្គម

- ប្រជាជនខ្មែររាប់ពាន់បានស្លាប់ ព្រមទាំងបន្សល់ទុកនូវជនពិការ ស្ត្រីម៉ែម៉ាយ កុមារកំព្រា អ្នកជំងឺរាប់រយនាក់
- ប្រជាជនរស់នៅដោយភាពភ័យខ្លាច ខ្វះខាតស្បៀងអាហារ និងភៀសខ្លួនពីជនបទចូលមកកាន់ទីក្រុងភ្នំពេញ
- សង្គមជួបនូវភាពអនាធិបតេយ្យ អំពើហឹង្សា ចោរកម្ម
- បំផ្លាញធនធានមនុស្ស និងហេដ្ឋារចនាសម្ពន្ធសង្គមដូចជា គ្រឹះស្ថានសិក្សា វត្តអារាម លំនៅដ្ឋាន

❖ សេដ្ឋកិច្ច

- ដីស្រែចម្ការជាច្រើនក្លាយជារណ្តៅគ្រាប់បែក ប្រជាជនមិនអាចធ្វើការអាស្រ័យផលបាន
- ប្រជាកសិករបាត់បង់មុខរបរ
- ផ្លូវថ្នល់ ស្ពាន រងនូវការបំផ្លាញ ធ្វើឲ្យប៉ះពាល់ដល់ចរន្តពាណិជ្ជកម្ម និងសេដ្ឋកិច្ចត្រូវរាំងស្ទះ
- កសិដ្ឋាន រោងចក្រ សហគ្រាសត្រូវបំផ្លិចបំផ្លាញ

❖ នយោបាយ

- កម្ពុជាបាត់បង់ឯករាជ្យភាព អធិបតេយ្យភាព បូរណភាពទឹកដី
- ប្រជាជនអស់ទំនុកចិត្តចំពោះរដ្ឋាភិបាល
- បែកបាក់សាមគ្គីជាតិ កើតមានតំបន់រដ្ឋបាល២ផ្សេងគ្នា

២០. តើមូលហេតុអ្វីបានជាផ្ទុះសង្គ្រាមស៊ីវិល ៥ឆ្នាំ(១៩៧០ - ១៩៧៥) នៅកម្ពុជា ?

⇨ មូលហេតុដែលធ្វើឲ្យផ្ទុះសង្គ្រាមស៊ីវិល ៥ឆ្នាំ(១៩៧០ - ១៩៧៥) នៅកម្ពុជា ៖

❖ ឥទ្ធិពលនៃសង្គ្រាមត្រជាក់បានធ្វើឲ្យ

- កម្ពុជាអនុវត្តនយោបាយអព្យាក្រឹត្យមិនចំទិសដៅ
- កម្ពុជាលូកដៃចូលទៅក្នុងសង្គ្រាមនៅវៀតណាម
- អំពើពុករលួយ បក្ខពួកនិយម អនាធិបតេយ្យ
- មន្ត្រីមួយចំនួនរៀបចំផែនការក្បត់សម្តេច នរោត្តម សីហនុ
- ផ្ដួលប្រហារទម្លាក់សម្តេចនរោត្តម សីហនុ ពីប្រមុខរដ្ឋ ១៩៧០

- ការលូកដៃចូលក្នុងនយោបាយខ្មែរបស់វៀតណាម ចិន សហរដ្ឋអាមេរិក
- ការបង្កើតរណសិរ្សរួបរួមជាតិកម្ពុជារបស់សម្តេច នរោត្តម សីហនុ ។

📖 របបកម្ពុជាប្រជាធិបតេយ្យ

២១. តើមុនថ្ងៃរំដោះ ១៧ មេសា ១៩៧៥ ក្រុមខ្មែរក្រហម បានធ្វើដូចម្តេចខ្លះ?

⇨ មុនថ្ងៃរំដោះ ១៧ មេសា ១៩៧៥ ក្រុមខ្មែរក្រហម បានធ្វើដូចតទៅ ៖

- ជាក់មីននៅគ្រប់ច្រកលួកតាមផ្លូវទឹកមកកាន់ទីក្រុងភ្នំពេញ ដើម្បីកាត់ផ្តាច់ ការដឹកជញ្ជូន អង្ករ និងគ្រាប់ រំសេវ ពីសំណាក់សហរដ្ឋអាមេរិក
- រឹតបន្តឹង ហើយឡោមព័ទ្ធទីក្រុងភ្នំពេញ ដែលក្នុងពេលនោះមានជនភៀសសឹកបានរស់នៅក្រុងភ្នំពេញបានកើនឡើងប្រមាណ ២លាននាក់ ។

២២. ក្រោយថ្ងៃ ១៧ មេសា ១៩៧៥ កងកម្លាំងប្រដាប់អាវុធរំដោះជាតិកម្ពុជាបានអនុវត្តតាមបទបញ្ជារបស់លេខបក្សកុម្មុយនីស្តប៉ុន្មានប្រការអ្វីខ្លះ ?

⇨ ក្រោយថ្ងៃ ១៧ មេសា ១៩៧៥ កងកម្លាំងប្រដាប់អាវុធរំដោះជាតិកម្ពុជាបានអនុវត្តតាមបទបញ្ជារបស់លេខបក្សកុម្មុយនីស្ត ៨ប្រការគឺ:

1. ជម្លៀសប្រជាជនចេញពីទីក្រុងទាំងអស់
2. លុបបំបាត់ផ្សារ
3. លុបបំបាត់រូបិយបណ្ណរបស់របប លន់ នល់
4. ផ្សឹកលោកសង្ឃកាន់ព្រះពុទ្ធសាសនាទាំងអស់ ហើយបញ្ជូនឱ្យទៅធ្វើការស្រែចម្ការ
5. ប្រហារជីវិតមេដឹកនាំរបបលន់ នល់
6. បង្កើតសហករណ៍កម្រិតខ្ពស់ទូទាំងប្រទេសដោយបង្កើតឱ្យមានរោងបាយរួម
7. បណ្តេញជនជាតិភាគតិចវៀតណាមឱ្យចេញទាំងអស់
8. បញ្ជូលទ័ពទៅតាមព្រំប្រទល់ ជាពិសេសព្រំប្រទល់វៀតណាម។

២៣. តើពាក្យថាអង្គការ មានវិសាលភាពយ៉ាងដូចម្តេច នៅសម័យកម្ពុជាប្រជាធិបតេយ្យ (ប៉ុល ពត) ? ហើយអង្គការបដិវត្តន៍ ត្រូវបានបង្កើតឡើងដោយនរណា?

⇨ នៅសម័យ កម្ពុជាប្រជាធិបតេយ្យ (ប៉ុល ពត) ពាក្យថា អង្គការមានវិសាលភាពគ្របដណ្តប់ទាំងបក្សកុម្មុយនីស្ត ទាំងអង្គការនីតិបញ្ញត្តិ នីតិប្រតិបត្តិ និងអំណាច តុលាការ ។ អង្គការបដិវត្តន៍ ត្រូវបានបង្កើតឡើងដោយសមាជិក បក្សកុម្មុយនីស្តកម្ពុជា ។

២៤. តើចម្រៀងជាតិនៅសម័យកម្ពុជាប្រជាធិបតេយ្យ មានឈ្មោះថាដូចម្តេច ? និពន្ធដោយ នរណា ?

⇨ ចម្រៀងជាតិនៅសម័យកម្ពុជាប្រជាធិបតេយ្យ មានឈ្មោះថា ១៧ មេសា មហាជោគ ជ័យ ដែលនិពន្ធដោយ ប៉ុល ពត ។

២៥. តើសមូហភាវូបនីយកម្មគឺជាអ្វី ? ហើយវាបានធ្វើឲ្យប៉ះពាល់មកលើគ្រួសារខ្មែរ ដូចម្តេចខ្លះ ?

⇨ សមូហភាវូបនីយកម្មគឺ ជាគោលនយោបាយដ៏សំខាន់បំផុតរបស់កម្ពុជាប្រជាធិបតេយ្យ ។ គោលនយោបាយនេះបានធ្វើឲ្យប៉ះពាល់មកលើគ្រួសារខ្មែរដូចជា៖

- ក្រុមគ្រួសារត្រូវបានបំបែកចេញពីគ្នា ហើយប្រជាជនត្រូវបានចាត់តាំងទៅតាមក្រុមនីមួយៗ
- ប្តីត្រូវបានបំបែកចេញពីប្រពន្ធ កូនក្មេងត្រូវបំបែកចេញពីឪពុកម្តាយ ហើយត្រូវបានចាត់ តាំងឲ្យទៅធ្វើការនៅដំរែផ្សេងៗគ្នា ។

២៦. តើរបបកម្ពុជាប្រជាធិបតេយ្យ (ខ្មែរក្រហម ឬបក្សកុម្មុយនីស្តកម្ពុជា)ដឹកនាំ និងគ្រប់គ្រងប្រទេសពីឆ្នាំណាដល់ឆ្នាំណា ? របបនេះអនុវត្តនយោបាយដូចម្តេចខ្លះ ?

⇨ របបកម្ពុជាប្រជាធិបតេយ្យ (ខ្មែរក្រហម ឬបក្សកុម្មុយនីស្តកម្ពុជា)ដឹកនាំ និងគ្រប់គ្រងប្រទេសពីឆ្នាំ១៩៧៥-១៩៧៩ ។ របបនេះបានអនុវត្តនយោបាយ ៖

❖ អនុវត្តគោលនយោបាយ ៨ប្រការរបស់ប៉ុល ពតគឺ

- ជម្លៀសប្រជាជនឱ្យចេញពីទីក្រុងភ្នំពេញទាំងអស់
- លុបបំបាត់ផ្សារ
- លុបបំបាត់ការប្រើប្រាស់ និងចរាចរណ៍រូបិយប័ណ្ណ
- ផ្សឹកព្រះសង្ឃក្នុងសំណាក់ព្រះពុទ្ធសាសនាទាំងអស់ឱ្យទៅធ្វើស្រែចំការតាមមូលដ្ឋានជនបទ
- ប្រហារជីវិតមេដឹកនាំរបប លន់ នល់
- បង្កើតសហករណ៍កម្រិតខ្ពស់ទូទាំងប្រទេស
- បណ្តេញជនជាតិភាគតិចវៀតណាមឱ្យចេញទាំងអស់
- បញ្ជូនទ័ពទៅតាមព្រំប្រទល់ ជាពិសេសព្រំប្រទល់វៀតណាម

- ❖ បង្កើតឱ្យមានសភាតំណាងកសិករ កម្មករ ពលករ កងទ័ព មានរដ្ឋធម្មនុញ្ញ តែភាពជាក់ស្តែង អំណាចនេះស្ថិតលើបក្សកុម្មុយនីស្តកម្ពុជា
- ❖ ធ្វើការបែងចែករដ្ឋបាលដែនដី ជាថ្នាក់មជ្ឈឹម ភូមិភាគ តំបន់ ស្រុក ឃុំ ឬសហករណ៍
- ❖ អនុវត្តនយោបាយមហាលោតផ្លោះមហាអស្ចារ្យ ដោយ
  - ❖ អនុវត្តផែនការ ៤ឆ្នាំ(១៩៧៧-១៩៨០)
  - ❖ ធ្វើសមូហភាវូបនីយកម្ម ដោយបង្កើតជាសហករណ៍ រស់នៅរួម ហូបរួម ធ្វើការរួម
  - ❖ ធ្វើការបែងចែកប្រជាជន ជាពីរប្រភេទគឺ ប្រជាជនមូលដ្ឋាន(ប្រជាជនចាស់) និងប្រជាជន ជម្លៀស(ប្រជាជនថ្មី)
- ❖ អនុវត្តនយោបាយសម្រិតសម្រាំងយកមនុស្សបដិវត្តន៍ល្អបរិសុទ្ធ
- ❖ ធ្វើសង្គ្រាមប្រឆាំងវៀតណាម
- ❖ កាត់ផ្តាច់ទំនាក់ទំនងការទូតនិងចាត់ទុកប្រទេសសូវៀត ថៃ សហរដ្ឋអាមេរិក.. ជាសត្រូវ ។

(មតិផ្សេងទៀត)

២៧. ហេតុអ្វីបានជាមានការសម្លាប់រង្គាល នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ?

⇨ បានជាមានការសម្លាប់រង្គាល នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពីព្រោះ ៖

- ❖ អនុវត្តគោលនយោបាយ ៨ប្រការរបស់ប៉ុល ពតគឺ
  - ជម្លៀសប្រជាជនឱ្យចេញពីទីក្រុងភ្នំពេញទាំងអស់
  - លុបបំបាត់ផ្សារ
  - លុបបំបាត់ការប្រើប្រាស់ និងចរាចរណ៍រូបិយប័ណ្ណ
  - ផ្សឹកព្រះសង្ឃក្នុងសំណាក់ព្រះពុទ្ធសាសនាទាំងអស់ឱ្យទៅធ្វើស្រែចំការតាមមូលដ្ឋានជនបទ
  - ប្រហារជីវិតមេដឹកនាំរបប លន់ នល់
  - បង្កើតសហករណ៍កម្រិតខ្ពស់ទូទាំងប្រទេស
  - បណ្តេញជនជាតិភាគតិចវៀតណាមឱ្យចេញទាំងអស់
  - បញ្ជូនទ័ពទៅតាមព្រំប្រទល់ ជាពិសេសព្រំប្រទល់វៀតណាម
- ❖ អនុវត្តផែនការ ៤ឆ្នាំ(១៩៧៧-១៩៨០) ដែលតម្រូវឱ្យ ៖

- ប្រជាជនធ្វើការលើស ១២ម៉ោងក្នុង១ថ្ងៃ គ្មានពេលឈប់សម្រាកទាំងក្មេង ចាស់ ប្រុស ស្រី រហូតបាក់កម្លាំង កើតជំងឺរងចាំតែសេចក្តីស្លាប់
- ការបង្អត់អាហារ ការធ្វើទារុណកម្ម ការកាប់សម្លាប់ប្រជាជនទាំងឡាយណាដែលរអ៊ូរទាំ តូញតែ្អរនឹងការងារ លួចប្លុបអាហារ លួចមកលេងផ្ទះ ធ្វើឱ្យបាត់គោ ក្របី បាក់នង្គ័ល .បាក់ ស្លាបព្រា បែកចាន ...ដែលត្រូវចោទថាក្បត់អង្គការ និងត្រូវកម្ទេច(សម្លាប់)

❖ ការអនុវត្តនយោបាយសម្រិតសម្រាំងយកមនុស្សបដិវត្តន៍ល្អបរិសុទ្ធបានធ្វើឱ្យ៖

- ខ្មែរក្រហមស្វែងរកអ្នកប្រឆាំង ជនបង្កប់ជាភ្នាក់ងារសម្ងាត់របស់បរទេសមកធ្វើទារុណកម្មនិង សម្លាប់
- ខ្មែរក្រហមសង្ស័យលើកម្មាភិបាលគ្នាឯងពីថ្នាក់ក្រោម ដល់ថ្នាក់លើ ហើយចាប់ធ្វើទារុណកម្មសម្លាប់ក្រោមពាក្យស្លោក"កម្ទេចខុស ជៀសជាងលែងខុស"
- ការធ្វើសង្គ្រាមប្រឆាំងវៀតណាមបណ្តាលឱ្យមានការសម្លាប់រង្គាលទៅលើខ្មែរគ្នាឯង និងជនជាតិ វៀតណាម
- ការអប់រំមនោគមវិជ្ជាបដិវត្តន៍ និងគំនិតជាតិនិយមជ្រុល បាននាំទៅរកការសម្លាប់រង្គាលលើអ្នក ប្រឆាំង និងជាតិសាសន៍ដទៃ(វៀតណាម ចិន ចាម ជនជាតិភាគតិច...)
- ការសងសឹកផ្សេងៗ គំនុំវណ្ណៈរវាងអ្នកមាននិងអ្នកក្រ អ្នកទីក្រុងនិងជនបទ
- ការដាក់ផែនការ និងការផ្តល់អំណាចដល់ថ្នាក់ក្រោមហួសហេតុដោយខ្វះការត្រួតពិនិត្យតាមដាន ធ្វើឱ្យអង្គការថ្នាក់ក្រោមប្រព្រឹត្តស្រេចតែចិត្ត ដោយធ្វើយ៉ាងណាឱ្យសម្រេចតាមទិសដៅអង្គការ ថ្នាក់លើដាក់ចុះ។

(មតិផ្សេងទៀត)

២៨. ចូរបង្ហាញពីស្ថានភាពរស់នៅ របស់ប្រជាជនកម្ពុជា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

⇨ ស្ថានភាពរស់នៅ របស់ប្រជាជនកម្ពុជា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

ប្រជាជនកម្ពុជារស់ក្នុងគុកឥតជញ្ជាំង ប្រៀបបាននឹងឋាននរកដោយរងនូវ ៖

- ការភ័យខ្លាច ភ័យតក់ស្លុត ការធ្វើទារុណកម្ម ការកាប់សម្លាប់

- ការបង្ខំឱ្យធ្វើការលើស ១២ម៉ោងក្នុង១ថ្ងៃ ៧ថ្ងៃក្នុង១សប្តាហ៍ គ្មានថ្ងៃឈប់សម្រាក ទាំងក្មេង ចាស់ ប្រុស ស្រី រហូតបាក់កម្លាំង
- ការបង្កត់អាហារ កង្វះសម្លៀកបំបាក់ កង្វះជម្រកគ្មានថ្នាំសម្រាប់ព្យាបាលជំងឺរងចាំតែសេចក្តីស្លាប់ បំបិទសិទ្ធិសេរីភាព ជំនឿសាសនា ប្រពៃណី ទំនៀមទំលាប់ដូចជា ៖
  - ពុំមានសិទ្ធិបញ្ចេញមតិ យោបល់ ពុំមានសិទ្ធិដើរហើរពីតំបន់មួយទៅតំបន់មួយ
  - ជំនឿសាសនា ត្រូវហាមឃាត់ជាច់ខាត ដោយអង្គការធ្វើការផ្សឹកព្រះសង្ឃ ប្រែក្លាយវត្តអារាម ទៅជាក្រោលសត្វ ឃ្លាំង រោងបាយ មន្ទីរសន្តិសុខ(គុក)...
  - ប្រពៃណីទំនៀមទំលាប់ត្រូវហាមឃាត់ ដូចជាអាពាហ៍ពិពាហ៍មានតែអង្គការជាអ្នករៀបចំឱ្យ
- ការបែងចែកប្រជាជន ជាពីរប្រភេទគឺ ប្រជាជនមូលដ្ឋាន(ប្រជាជនចាស់) និងប្រជាជនជម្លៀស (ប្រជាជនថ្មី)
- បែងចែកប្រជាជនទៅតាមកម្លាំង តាមវ័យដូចជា កងកុមារ កងយុវជន(កងចល័ត) ក្រុមវ័យ កណ្តាល(ក្រុមឪពុក ម្តាយ) វ័យចាស់ជរា
- រស់នៅជាសមូហភាព ជាសហករណ៍ ហូបរួម ធ្វើការរួម គ្មានកម្មសិទ្ធិឯកជន.គ្មានការរស់ជាបុគ្គល
- ឪពុកម្តាយគ្មានសិទ្ធិលើកូន ព្រោះកូនជាកូនរបស់អង្គការ
- កុមារទទួលបាននូវការអប់រំមនោគមវិជ្ជាបដិវត្តន៍ ដោយឱ្យកុមារស្រឡាញ់ ជឿជាក់ស្មោះត្រង់ ហ៊ានពលិដើម្បីអង្គការ យកការណ៍ពីឪពុកម្តាយ ពីជួរប្រជាជនជូនអង្គការ
- រស់ក្រោមពាក្យស្លោក"ទុកក៏មិនចំណេញ ដកចេញក៏មិនខាត"

ដូចនេះប្រជាជនកម្ពុជារស់ជាទាសករ ប្រៀបបានឧបករណ៍ផលិតដែលចេះនិយាយ ។

២៩. ចូររៀបរាប់ពីរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋ និងមជ្ឈឹមបក្សកុម្មុយនីស្តឆ្នាំ១៩៧៦ ?

⇨ រៀបរាប់ពីរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋ និងមជ្ឈឹមបក្សកុម្មុយនីស្តឆ្នាំ១៩៧៦

❖ រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋ

- ខៀវ សំផន ជាប្រធានគណៈប្រធានរដ្ឋ ឬប្រមុខរដ្ឋ
- នួន ជា ជាប្រធានសភាតំណាងប្រជាជនកម្ពុជា
- ប៉ុល ពត ជានាយករដ្ឋមន្ត្រី

- អៀង សារី ជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស
- វ៉ន វ៉ែត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច
- សុន សេន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

❖ រចនាសម្ព័ន្ធមជ្ឈឹមបក្សកុម្មុយនីស្ត

- ប៉ុល ពត ជាលេខបក្ស
- នួន ជា ជាអនុលេខាបក្ស
- សមាជិកបក្សមាន៖ សោភឹម អៀងសារី សុនសន ឈិតជឿន វ៉ន់វ៉ែត កពក ខៀវសំផន ញឹមរស់។

៣០. តើពួកខ្មែរក្រហមបែងចែកប្រទេសកម្ពុជាជាប៉ុន្មានភូមិភាគ ? ប៉ុន្មានតំបន់ ?

⇨ ពួកខ្មែរក្រហមបែងចែកប្រទេសកម្ពុជាជា៦ភូមិភាគ និង៣២តំបន់ គឺ៖

- ភូមិភាគបូព៌ា (២០៣) : សោ ភឹម មានខេត្តព្រៃវែង ស្វាយរៀង កំពង់ចាម ក្រចេះមួយផ្នែក កណ្តាលមួយផ្នែក មាន តំបន់ ២០, ២១, ២២, ២៣, ២៤ ។
- ភូមិភាគនិរតី (៤០៥) : ឈិត ជឿន(តាម៉ុក)មានខេត្តតាកែវ កំពត កំពង់ស្ពឺ២ស្រុក និងកណ្តាល៥ស្រុក មានតំបន់១៣, ២៥, ៣៣, ៣៥ ។
- ភូមិភាគឧត្តរ (៣០៣) : កុយធួន(ធុច), កងចាប, កែពក មានខេត្តកំពង់ធំ ខេត្តកំពង់ចាមខាងលិចទន្លេ និង ក្រចេះ១ ស្រុក មាន៣តំបន់ ៤១, ៤២, ៤៣។
- ភូមិភាគ៣យ៉ាង (៥០៦): ញឹម រស់ មានខេត្តបាត់ដំបង ពោធិ៍សាត់ និងមាន៧តំបន់ ១,២,៣,៤,៥,៦,៧។
- ភូមិភាគបស្ចិម (៤០១): ជូជេត មានខេត្តកោះកុង កំពង់ឆ្នាំង និងផ្នែកខ្លះនៃកំពង់ស្ពឺ មាន៥តំបន់គឺ ១១, ១៥, ៣១, ៣២, ៣៧ ។
- ភូមិភាគឥសាន (១០៨) : ណៃសារ៉ាន់(យ៉ា) មានខេត្តមណ្ឌលគីរី រតនគីរី និងផ្នែកខ្លះនៃខេត្តព្រះវិហារ និង ស្ទឹងត្រែង មាន៦តំបន់គឺ ១០១, ១០២, ១០៤, ១០៥, ១០៧, ៥០៥ ។

៣១. តើសាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហមមានឈ្មោះជាផ្លូវការដូចម្តេចខ្លះ ? តើមេដឹកនាំខ្មែរក្រហមណាខ្លះ ដែលត្រូវបានតុលាការចោទប្រកាន់និងកាត់ទោស ?

- ⇨ សាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហមមានឈ្មោះជាផ្លូវការថា « អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា» ។
- ⇨ មេដឹកនាំខ្មែរក្រហមដែលតុលាការចោទប្រកាន់ និង កាត់ទោសមាន ៖
  - សំណុំរឿង ០០១ គឺ កាំងហ្គេចអ៊ាវ ហៅ ឌុច ជាអតីតប្រធានគុកទួលស្លែង (ស-២១)
  - សំណុំរឿង ០០២ មាន:
    - ខៀវ សំផន អតីតប្រមុខរដ្ឋកម្ពុជាប្រជាធិបតេយ្យ
    - នួន ជា អតីតប្រធានសភា
    - អៀង សារី អតីតឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស
    - អៀង ធីរិទ្ធ អតីតរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច សុខាភិបាល ។

🕮 សាធារណរដ្ឋប្រជាមានិតកម្ពុជា និង ព្រះរាជាណាចក្រកម្ពុជាទី២

៣២. ចូររៀបរាប់ស្ថានភាពប្រជាជនកម្ពុជាក្រោយថ្ងៃទី ៧ មករា ១៩៧៩ ។

- ⇨ ស្ថានភាពប្រជាជនកម្ពុជាក្រោយថ្ងៃទី៧ មករា១៩៧៩ ៖
  - ប្រជាជនកម្ពុជាបានវិលត្រឡប់មកស្រុកកំណើតវិញ ដើម្បីជួបជុំគ្រួសារ ប៉ុន្តែ
    - ពុំមាននរណាម្នាក់ដែលពុំបានបាត់បង់សាច់ញាតិទេ
    - អ្នកខ្លះបានស្លាប់ផុតពូជ
  - ប្រជាជនខ្លះទៀតដោយអស់សង្ឃឹមនឹងរស់នៅស្រុកខ្មែរ ក៏បានភៀសខ្លួនទៅរស់នៅក្នុងជំរុំតាមព្រំដែនកម្ពុជា ថៃ ក្រោមការឧបត្ថម្ភរបស់អង្គការសហប្រជាជាតិ
  - ប្រជាជនប្រមាណ៨០%គិតតែពីដើររកបងប្អូន សាច់ញាតិ ពុំបានធ្វើស្រែចំការ បង្កបង្កើន ផល
  - អ្នកនៅរស់ភាគច្រើនជាស្ត្រីមេម៉ាយ ក្មេងកំព្រា ចាស់ជរា ជនបាក់កម្លាំង គ្មានទីពឹង គ្មាន ឧបករណ៍ធ្វើស្រែចម្ការ
  - ប្រជាជនរស់នៅដោយកង្វះសម្លៀកបំពាក់ កង្វះអាហារ រងគ្រោះទុក្ខ ព្រោះមុននឹងចាកចេញខ្មែរក្រហមបានដុតបំផ្លាញស្បៀងអាហារចោលស្ទើរអស់។
    (មតិផ្សេងទៀត)

៣៣. ហេតុអ្វីបានជាសភានៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៨៩ ?តើសភាអនុម័តយ៉ាងដូចម្តេចខ្លះ ?

- ⇨ បានជាសភានៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញនាឆ្នាំ ១៩៨៩ ព្រោះ៖
  - កែតម្រូវរដ្ឋធម្មនុញ្ញឱ្យស្របនឹងកាលៈទេសៈ ស្ថានការណ៍ជាក់ស្តែង
  - ដើម្បីសម្របសម្រួលខាងនយោបាយ និងបើកផ្លូវឱ្យរដ្ឋាភិបាលធ្វើការចរចាបញ្ចប់សង្គ្រាម ស៊ីវិលនៅកម្ពុជា

❖ សភាអនុម័តធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញដូចតទៅ ៖

- ប្តូរឈ្មោះប្រទេសពីសាធារណរដ្ឋប្រជាមានិតកម្ពុជា ទៅជារដ្ឋកម្ពុជា
- ប្តូរទង់ជាតិ ភ្លេងជាតិ
- លុបចោលនូវទោសប្រហារជីវិត (លុបចោលច្បាប់ប្រហារជីវិត)
- លើកតម្កើងព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ និងលុបចោលនូវការកំហិតអាយុអ្នកសាងផ្ទួស
- បង្កើតច្បាប់ការពារកម្មសិទ្ធិឯកជន និងទីផ្សារសេរី
- ផ្តល់សេរីភាពដល់សារព័ត៌មាន និងការបង្កើតអង្គការសង្គមស៊ីវិល
- លុបចោលនូវពាក្យ សង្គមនិយម កុម្មុយនីស្ត ក្នុងអត្ថបទច្បាប់
- រដ្ឋធម្មនុញ្ញបានចែងថា "កម្ពុជាអនុវត្តនយោបាយអព្យាក្រឹតមិនចូលបក្សសម្ព័ន្ធ វិសោធនកម្មរដ្ឋធម្មនុញ្ញនេះបានបើកផ្លូវឱ្យរដ្ឋាភិបាលធ្វើការចរចាបញ្ចប់សង្គ្រាម ស៊ីវិលនៅកម្ពុជា។

(មតិផ្សេងទៀត)

៣៤. បន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យបានដួលរលំ តើប្រទេសកម្ពុជាចែកចេញជាប៉ុន្មានភាគី? ចូររៀបរាប់ ។

⇨ បន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ កម្ពុជាមានការបែងចែកជា៤ភាគីគឺ ៖

- ភាគីទី១ រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាដឹកនាំដោយ ហេង សំរិន។ ភាគីទី ១ នេះជាក្រុមដែលបានរំដោះកម្ពុជាចេញពីរបបខ្មែរក្រហម មានទិសដៅ កសាងជាតិឡើងវិញ និងបានទប់ស្កាត់ការវិលត្រលប់មកវិញរបស់ខ្មែរក្រហម។
- ភាគីទី២ កម្ពុជាប្រជាធិបតេយ្យ ឬខ្មែរក្រហម ដែលដឹកនាំដោយប៉ុល ពត ដ្បិតថា ខ្មែរក្រហមដួលរលំទៅ ក៏ប៉ុន្តែពួកគេនៅតែបន្តគ្រប់គ្រង់ទឹកដីកម្ពុជាមួយភាគ ដំរុំ កៀស

ខ្លួនមួយចំនួននៅតាមព្រំដែនខ្មែរ-ថៃ ។

- ភាគីទី៣ រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរប្រជាធិបតេយ្យដឹកនាំដោយ សឺន សាន បង្កើតឡើងនៅថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៩។ រណសិរ្សនេះមានទិសដៅ សំខាន់បីគឺ រំដោះប្រទេសកម្ពុជាចេញពីអំណាចរបស់វៀតណាម ប្រឆាំងការរំលិ ត្រលប់របស់ខ្មែរក្រហម និងកសាងជាតិឡើងវិញ។ រណសិរ្សនេះកាន់កាប់ទឹកដី និងជំរុំជនភៀសខ្លួនមួយចំនួននៅតាមព្រំដែនខ្មែរ-ថៃ។
- ភាគីទី៤ ក្រុមរាជានិយមរបស់សម្តេច នរោត្តម សីហនុ(ហ៊ុនស៊ិនប៊ិច)។ ភាគីទី នេះ បង្កើតឡើងនៅខែមីនា ឆ្នាំ១៩៨១ ទិសដៅសំខាន់គឺប្រឆាំងនឹងវត្តមាន របស់វៀតណាមនៅលើទឹកដីប្រទេសកម្ពុជា។ ក្រុមនេះកាន់កាប់ទឹកដី និងជំរុំ ជនភៀសខ្លួនមួយចំនួននៅតាមព្រំដែនខ្មែរ-ថៃ ជំរុំដែលសំខាន់ជាងគេរបស់ក្រុម នេះគឺនៅអូរស្មាច់ ខេត្តឧត្តរមានជ័យ។

៣៥. ចូររាប់ឈ្មោះប្រទេស ដែលបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងក្រុងប៉ារីសថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ឱ្យបាន៥ ? តើកិច្ចព្រមព្រៀងនេះផ្តោតលើចំណុចសំខាន់ៗអ្វីខ្លះ ? តើកិច្ចព្រមព្រៀងនេះមានខ្លឹមសារសំខាន់ៗអ្វីខ្លះ ?

⇨ ប្រទេសដែលបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងក្រុងប៉ារីសថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ មាន ៖

- សហរដ្ឋអាមេរិក សហភាពសូវៀត ចក្រភពអង់គ្លេស សាធារណរដ្ឋបារាំង សាធារណរដ្ឋ
- ប្រជាមានិតចិន ប្រទេសថៃ វៀតណាម ឡាវ ម៉ាឡេស៊ី ឥណ្ឌូនេស៊ី ព្រុយនេ សឹង្ហបុរី ហ្វីលីពីន
- កាណាដា អូស្ត្រាលី ឥណ្ឌា ជប៉ុន យូហ្គោស្លាវី

❖ កិច្ចព្រមព្រៀងនេះផ្តោតលើចំណុចសំខាន់ៗ២គឺ ៖

- បញ្ហាអធិបតេយ្យភាព បូរណភាពទឹកដី និងឯករាជ្យភាពនៃកម្ពុជា
- បញ្ហាស្តារ និងកសាងប្រទេសកម្ពុជាឡើងវិញ

❖ កិច្ចព្រមព្រៀងនេះមានខ្លឹមសារសំខាន់ៗដូចជា៖

- ការឈប់បាញ់គ្នារវាងភាគីជម្លោះក្នុងសង្គ្រាមស៊ីវិលនៅកម្ពុជា

- ការកាត់រំសាយកងទ័ព
- ការដកកងទ័ពបរទេសចេញពីកម្ពុជា
- ការរៀបចំការបោះឆ្នោតតាមបែបប្រជាធិបតេយ្យ
- កំណត់អាណត្តិ និងអំណាចរបស់អ៊ុនតាក់(UNTAC)ដោយ :
  - ការរក្សាសន្តិសុខ សន្តិភាពដោយដកអាវុធពីភាគី ជម្លោះទាំង៤
  - ការរួមបញ្ចូលគ្នារវាងរដ្ឋអំណាច រដ្ឋកម្ពុជា និងសម្ព័ន្ធត្រីភាគី
  - ការរៀបចំការបោះឆ្នោតនៅកម្ពុជា
  - ការដឹកជញ្ជូនជនភៀសខ្លួនប្រមាណ ៣៥០០០០នាក់មកមាតុភូមិវិញ
- ការកំណត់រដ្ឋធម្មនុញ្ញថ្មីដោយ :
  - គោរពគោលការណ៍ប្រជាធិបតេយ្យសេរីពហុបក្ស
  - ឈរលើគោលការណ៍គោរពសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន
  - នីតិរដ្ឋ

    (មតិផ្សេងទៀត)

៣៦. ចូររៀបរាប់ពីការកកើតឡើងនៃរាជរដ្ឋាភិបាលថ្មី នៃព្រះរាជាណាចក្រកម្ពុជាទី២ ។

⇨ ការកកើតឡើងនៃរាជរដ្ឋាភិបាលថ្មី នៃព្រះរាជាណាចក្រកម្ពុជាទី២ ៖

- ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ កិច្ចព្រមព្រៀងក្រុងប៉ារីសបាននាំកម្ពុជាទៅរកការបោះឆ្នោត ដោយសេរីក្រោមការរៀបចំដោយអ៊ុនតាក់
- ថ្ងៃទី២៣-២៨ ខែឧសភា ឆ្នាំ១៩៩៣ ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្របានប្រព្រឹត្តទៅ ដោយមានគណបក្សចំនួន២០ចុះឈ្មោះ តែខ្មែរក្រហមធ្វើពហិការ ដែលជាលទ្ធផល មាន៨ គណបក្សជាប់ឆ្នោត
- តំណាងរាស្ត្រជាប់ឆ្នោតបានចូលប្រជុំ ដោយប្រែក្លាយខ្លួនជាសភាធម្មនុញ្ញហើយនាំគ្នាសរសេរ រដ្ឋធម្មនុញ្ញថ្មី
- ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ សភាបានអនុម័តរដ្ឋធម្មនុញ្ញ
- ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៣ ព្រះមហាក្សត្របានឡាយព្រះហស្តលេខាប្រកាសឱ្យប្រើរដ្ឋ ធម្មនុញ្ញថ្មី រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាក៏បានកើតឡើង ។

៣៧. ចូរពណ៌នាពីការអនុវត្តយុទ្ធសាស្ត្រត្រីកោណ របស់រាជរដ្ឋាភិបាលក្នុងអាណត្តិទី២ (១៩៩៨-២០០៣) ។

⇨ យុទ្ធសាស្ត្រត្រីកោណ របស់រាជរដ្ឋាភិបាលក្នុងអាណត្តិទី២(១៩៩៨-២០០៣) មាន៖ យុទ្ធសាស្ត្រត្រីកោណត្រូវបានរាជរដ្ឋាភិបាលអនុវត្តក្នុងអាណត្តិទី២ (១៩៩៨-២០០៣) ដែល មានទិសដៅជំរុញការអភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជា ៖

❖ មុំទី១ «សន្តិភាពូបនីយកម្ម»

- គឺការនាំសន្តិភាពពេញលេញមកឱ្យកម្ពុជា
- លទ្ធផល: រាជរដ្ឋាភិបាលសម្រេចបានជោគជ័យដោយធ្វើសមាហរណកម្មកងកម្លាំងខ្មែរ ក្រហមឱ្យចូលមករួមរស់ជាមួយសង្គមជាតិទាំងស្រុង នាថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៨ តាម រយៈការអនុវត្តនយោបាយឈ្នះ-ឈ្នះ

❖ មុំទី២ «សមាហរណកម្មប្រទេសកម្ពុជាចូលក្នុងតំបន់ និងពិភពលោក»

- គឺជាការរៀបចំប្រទេស និងការធ្វើធម្មនីយកម្ម ដើម្បីធ្វើសមាហរណកម្មកម្ពុជាចូលទៅ ក្នុងតំបន់និងពិភពលោក
- លទ្ធផល :
  - ឆ្នាំ១៩៩៨ អង្គការសហប្រជាជាតិបានប្រគល់អាសនៈមកឱ្យកម្ពុជាវិញ
  - ថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៩ កម្ពុជាបានចូលជាសមាជិកអាស៊ាន(Asean)
  - ខែតុលា២០០៤កម្ពុជាចូលជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក (WTO)

❖ មុំទី៣ «ការអភិវឌ្ឍសង្គម សេដ្ឋកិច្ច»

- គឺការជំរុញការអភិវឌ្ឍសង្គម សេដ្ឋកិច្ច តាមរយៈ កំណែទម្រង់សាធារណៈ រិមជ្ឈការ កំណែទម្រង់ច្បាប់និងប្រព័ន្ធតុលាការ កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ សមភាព យេនឌ័រ ការលុបបំបាត់អំពើពុករលួយ ការកាត់រំសាយកងទ័ព និងការគ្រប់គ្រង ធនធានធម្មជាតិ ប្រកបដោយចីភាព។
- លទ្ធផលយុទ្ធសាស្ត្រត្រីកោណ ៖
  - ឆ្នាំ២០០៣ បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់
  - ការវិនិយោគទុនកើនឡើង ដែលនាំឱ្យមានកំណើនសេដ្ឋកិច្ច

- ការគ្រប់គ្រងរូបិយវត្ថុមានស្ថិរភាព(លំនឹងនៃអត្រាប្តូរប្រាក់)
- ការគ្រប់គ្រងរដ្ឋបាលសាធារណៈ និងហិរញ្ញវត្ថុសាធារណៈប្រសើរជាងមុន

ជារួមការអនុវត្តយុទ្ធសាស្ត្រត្រីកោណបាននាំមកនូវសន្តិភាព និងការអភិវឌ្ឍប្រទេសជាតិ។

📖 អាស៊ាន និង ចំណេះដឹងទូទៅ

៣៨. តើអាស៊ានបង្កើតឡើងដំបូងដោយប្រទេសណាខ្លះ ? នៅទីណា ? នៅថ្ងៃខែណា ?

⇨ អាស៊ានបង្កើតឡើងដំបូងមានប្រទេស៥ នៅទីក្រុងបាងកក ដែលរួមមាន ប្រទេស ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ភីលីពីន សិង្ហបុរី និងថៃ កាលពីថ្ងៃទី ០៨ ខែសីហា ឆ្នាំ ១៩៦៧ ។

៣៩. តើប្រទេសណាខ្លះដែលបានចូលជាសមាជិកអាស៊ានជាបន្តបន្ទាប់មកទៀត ?

⇨ ប្រទេសដែលបានចូលជាសមាជិកអាស៊ាន ជាបន្តបន្ទាប់មកទៀតមាន ៖

- ប្រទេស ព្រុយនេ សមាជិកទី៦ ចូលថ្ងៃទី ០៨ ខែមករា ឆ្នាំ ១៩៨៤
- ប្រទេស វៀតណាម សមាជិកទី៧ ចូលថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ១៩៩៥
- ប្រទេស ឡាវ សមាជិកទី៨ ចូលថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ ១៩៩៧
- ប្រទេស មីយ៉ាន់ម៉ា (ភូមា) សមាជិកទី៩ ចូលថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ ១៩៩៧
- ប្រទេស កម្ពុជា សមាជិកទី១០ ចូលថ្ងៃទី ៣០ ខែមេសា ឆ្នាំ ១៩៩៩ ។

៤០. តើអាស៊ានមានគោលដៅដូចម្តេចខ្លះ ?

⇨ គោលដៅបង្កើតអាស៊ាន គឺធ្វើសហប្រតិបត្តិការក្នុងតំបន់ដោយ ឈរលើស្មារតីភាពលើវិស័យ ៖

- សេដ្ឋកិច្ច ៖ កសិកម្ម ឧស្សាហកម្ម គមនាគមន៍ ទេសចរណ៍ ពាណិជ្ជកម្ម
- វិទ្យាសាស្ត្រ ៖ បច្ចេកទេស វប្បធម៌ និងការងាររដ្ឋបាល
- តំហែរក្សាសន្តិភាព ៖ សន្តិសុខក្នុងតំបន់តាមរយៈការគោរពដ៏ខ្ជាប់ខ្ជួននូវយុត្តិធម៌ និង គោលការណ៍ច្បាប់ទាំងឡាយក្នុងទំនាក់ទំនងរវាងប្រទេសក្នុងតំបន់ និងប្រកាន់ខ្ជាប់ខ្ជួន នូវធម្មនុញ្ញសហប្រជាជាតិ ។
- តំហែរក្សាកិច្ចសហប្រតិបត្តិការជិតស្និទ្ធិនិងមានផលប្រយោជន៍ជាមួយអង្គការក្នុងតំបន់ដែលមានស្រាប់ ។

៤១. តើអាស៊ានមានបាវចនាដូចម្តេច ?

⇨ បាវចនាអាស៊ានគឺ: ចក្ខុវិស័យមួយ អត្តសញ្ញាណមួយ សហគមន៍មួយ ។

៤២. ចូរនិយាយពីអត្ថន័យនៃនិមិត្តសញ្ញាអាស៊ាននិងទង់អាស៊ាន ។

⇨ និមិត្តសញ្ញាអាស៊ាន និងទង់អាស៊ានតំណាងឲ្យសមាគមអាស៊ានមួយ ដែលមានស្ថិរភាព សន្តិភាព រួបរួមគ្នា និងប្រកបដោយថាមពល ។

ពណ៌របស់និមិត្តសញ្ញា និងទង់អាស៊ានមានពណ៌ ខៀវ ក្រហម ស និងពណ៌លឿង ដែល ពណ៌ទាំងអស់នេះតំណាងឲ្យពណ៌សំខាន់ៗនៃទង់ជាតិរបស់ប្រទេសសមាជិកទាំងអស់ ។ អត្ថន័យនៃពណ៌នីមួយៗគឺ៖

- ពណ៌ខៀវ ៖ តំណាងឲ្យសន្តិភាព និងស្ថិរភាព
- ពណ៌ក្រហម ៖ តំណាងឲ្យសេចក្តីក្លាហាន និងភាពស្វាហាប់ , ថាមពល
- ពណ៌ស ៖ តំណាងឲ្យភាពបរិសុទ្ធ ស្អាតស្អំ
- ពណ៌លឿង ៖ តំណាងឲ្យវិបុលភាព, ភាពសម្បូរសប្បាយ
- ដើមស្រូវទាំង១០៖ តំណាងឲ្យសុបិនរបស់បិតាបង្កើតអាស៊ានដែលមានបំណងប្រមូលផ្តុំ ប្រទេសទាំង១០នៅអាស៊ីអាគ្នេយ៍ ឲ្យក្លាយជាសហគមន៍មួយប្រកបដោយមិត្តភាព និង សាមគ្គីភាព
- រង្វង់៧ព័ទ្ធជុំវិញ ៖ តំណាងឲ្យភាពឯកភាពគ្នារបស់អាស៊ាន ។

៤៣. តើអាស៊ានមានន័យដូចម្តេច? ពាក្យនេះមកពីពាក្យថាដូចម្តេច ?

⇨ អាស៊ានមានន័យថា "សមាគមប្រជាជាតិអាស៊ីអគ្នេយ៍" ។ អាស៊ាន ជាពាក្យកាត់តាសាអង់គ្លេសដែលមកពីពាក្យពេញថា (ASEAN = Association of South East Asian Nation) ។

៤៤. តើអាស៊ានបូក ១មានន័យដូចម្តេច ?

⇨ អាស៊ានបូក១មានន័យថាប្រទេសសមាជិកអាស៊ានទាំង១០បូកជាមួយនឹងប្រទេសឥណ្ឌា។

៤៥. តើអាស៊ានបូក ២មានន័យដូចម្តេច ?

⇨ អាស៊ានបូក២ មានន័យថាប្រទេសអាស៊ានទាំង១០បូករួមបញ្ចូលជាមួយនឹងប្រទេសញូហ្សេឡិន និងប្រទេសអូស្ត្រាលី ។

៤៦. តើអាស៊ានបូក ៣ មានន័យដូចម្តេច?

⇨ អាស៊ានបូក ៣មានន័យថាប្រទេសអាស៊ានទាំង១០រួមជាមួយប្រទេសអាស៊ីបូព៌ាចំនួនបីគឺ ប្រទេសចិន ប្រទេសជប៉ុន ប្រទេសកូរ៉េខាងត្បូង ។

៤៧. តើអាស៊ាន ៦មានន័យដូចម្តេច ?

⇨ អាស៊ាន ៦ មានន័យថា ៖ ប្រទេសអាស៊ាន៥ ប្រទេសប្រុីយណៃដែលចូលជាសមាជិកអាស៊ានថ្ងៃ ៧ មករា ១៩៨៤ដូច្នេះកាលណាគេនិយាយ ឬសរសេរថា អាស៊ាន៦ គឺសំដៅទៅសមាជិកប្រទេសទាំង ៦នោះតែប៉ុណ្ណោះ ។

៤៨. តើប្រទេសកម្ពុជាបានធ្វើជាប្រធានអាស៊ានប៉ុន្មានដង ?

⇨ ប្រទេសកម្ពុជាបានធ្វើជាប្រធានអាស៊ាន ៣ដងគឺ ៖

- ឆ្នាំ ២០០២ កម្ពុជាធ្វើជាប្រធានអាស៊ាន ក្រោមមូលបទ « ការឆ្ពោះទៅកាន់សហគមន៍អាស៊ាន »
- ឆ្នាំ ២០១២ កម្ពុជាធ្វើជាប្រធានអាស៊ាន ក្រោមមូលបទ « សហគមន៍មួយជោគវាសនាមួយ »
- ឆ្នាំ ២០២២ កម្ពុជាធ្វើជាប្រធានអាស៊ាន ក្រោមមូលបទ « អាស៊ានរួមគ្នាធ្វើ - ដោះស្រាយបញ្ហាប្រឈមទាំងអស់គ្នា »

៤៩. តើការបង្កើតអាស៊ានមានគោលបំណងអ្វីខ្លះ ?

⇨ គោលបំណងនៃការបង្កើតអាស៊ានគឺ ៖

- ធ្វើឱ្យទីផ្សារ និងមូលដ្ឋានផលិតផលតែមួយ ធ្វើឱ្យតំបន់សេដ្ឋកិច្ចមានការប្រកួតប្រជែងខ្ពស់
- ធ្វើឱ្យតំបន់នៃការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយសមធម៌
- បង្កើតកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនយោបាយ សង្គម និងវប្បធម៌
- អទិភាពកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍសង្គម និងវប្បធម៌ក្នុងនិងបណ្តាប្រទេសនៃតំបន់អាស៊ីអាគ្នេយ៍
- ព្យាយាមការពារផលប្រយោជន៍គ្នាទៅវិញទៅមក និងបង្កើតសាមគ្គីភាពក្នុងតំបន់ក៏ដូចជាលើកកម្ពស់សន្តិ ភាព និងស្ថិរភាពក្នុងតំបន់
- លើកទឹកចិត្តដល់សន្តិភាព និងស្ថិរភាពនយោបាយបង្កើតឡើងដោយគោលការណ៍នៃអង្គការសហប្រជាជាតិ
- ជម្រុញកិច្ចសហប្រតិបត្តិការ និងទំនាក់ទំនងជិតស្និទ្ធរវាងប្រទេស និងអង្គការដទៃទៀត

- លើកកម្ពស់កិច្ចសហប្រតិបត្តិការដ៏មានប្រសិទ្ធិភាពបន្ថែមទៀតនៅក្នុងបរិស្ថានឧស្សាហកម្ម និងការអភិវឌ្ឍ ទំនាក់ទំនងក៏ដូចជា ស្តង់ដាដែលរស់នៅក្នុងប្រទេសជាសមាជិក
- រក្សាតំបន់អាស៊ីអាគ្នេយ៍ជាតំបន់គ្មានអាវុធ នុយក្លេអ៊ែរ និងគ្មានអាវុធប្រល័យលោកផ្សេងទៀត ។

៥០. ចូរនិយាយអំពីអាស៊ានបូក និង អាស៊ានដក ។

⇨ និយាយអំពីអាស៊ានបូក និង អាស៊ានដក គឺ ៖

❖ អាស៊ានបូក

- បូក១ : ប្រទេសសមាជិកបូក ឥណ្ឌា
- បូក២ : ប្រទេសសមាជិកបូក អូស្ត្រាលី និង ញូហ្សេឡិន
- បូក៣ : ប្រទេសសមាជិកបូក ចិន ជប៉ុន កូរ៉េខាងត្បូង
- បូក១០ : ប្រទេសសមាជិកបូក ចិន ជប៉ុន កូរ៉េខាងត្បូង អូស្ត្រាលី ញូហ្សេឡិន ឥណ្ឌា កាណាដា រុស្ស៊ី USA និង សហភាពអឺរ៉ុប។

❖ អាស៊ានដក

- ដក៥ : សំដៅលើសមាជិកចាស់ទាំង៥
- ដក៦ : សំដៅលើសមាជិកថ្មីទី៦(ព្រុយណេ)
- ដក៧ : សំដៅលើសមាជិកថ្មីទី៧(វៀតណាម)
- ដក៩ : សំដៅលើសមាជិកថ្មីទី៨-៩(ឡាវ និង ភូមា)
- ដក១០ : សំដៅលើសមាជិកថ្មីទី១០(កម្ពុជា) ។

៥១. ចូររៀបរាប់សម្បត្តិវប្បធម៌ខ្មែរដែលបានបញ្ចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ។

⇨ រៀបរាប់សម្បត្តិវប្បធម៌ខ្មែរដែលបានបញ្ចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោក

❖ ផ្នែករូបិយមានដូចជា:

- តំបន់អង្គរ ៖ ត្រូវបានដាក់បញ្ចូលកាលពីថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ១៩៩២ នៅទីក្រុងសាន់តាហ្វេ សហរដ្ឋអាមេរិក ។
- ប្រាសាទព្រះវិហារ ៖ ត្រូវបានដាក់បញ្ចូលកាលពីថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៨ នៅទីក្រុងកេបិច ប្រទេសកាណាដា ។

- សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ៖ ត្រូវបានដាក់បញ្ចូលកាលពីថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៩ នៅទីក្រុងប្រិចវ៉ោន ប្រទេសបារបាដូស ។
- ប្រាសាទសម្បូរព្រៃគុក ៖ ត្រូវបានដាក់បញ្ចូលកាលពីថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០១៧ នៅទីក្រុងក្រាកូវ ប្រទេសប៉ូឡូញ ។

❖ ផ្នែកអរូបិយមានដូចជា:

- របាំព្រះរាជទ្រព្យ ៖ ត្រូវបានដាក់បញ្ចូលកាលពីថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ២០០៣ នៅទីក្រុងអ៊ីស្តង់ប៊ុល ប្រទេសតួគី ។
- ល្ខោនស្រមោលស្បែកធំ ៖ ត្រូវបានដាក់បញ្ចូលកាលពីថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០០៥ នៅទីក្រុងប៉ារីស ប្រទេសបារាំង ។
- ល្បែងទាញព្រ័ត្រ ៖ ត្រូវបានដាក់បញ្ចូលកាលពីថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ២០១៥ នៅទីក្រុងវិនហុក ប្រទេសណាមីប៊ី ។
- ចាប៉ីដងវែង ៖ ត្រូវបានដាក់បញ្ចូលកាលពីថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ២០១៦ នៅទីក្រុងអាឌីសអាបាបា ប្រទេសអេត្យូពី ។
- ល្ខោនខោន ៖ ត្រូវបានដាក់បញ្ចូលកាលពីថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ២០១៨ នៅទីក្រុងព័រល្វី សាធារណរដ្ឋម៉ូរីស ។
- គុនល្បុក្តោ ៖ ត្រូវបានដាក់បញ្ចូលកាលពីថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ២០២២ នៅទីក្រុងរ៉ាបាត់ ប្រទេសម៉ារ៉ុក ។

៥២. តើទន្លេមេគង្គហូរកាត់ប្រទេសណាខ្លះ?

⇨ ទន្លេមេគង្គហូរកាត់ប្រទេស៖

- ប្រទេសចិន
- ប្រទេសឡាវ
- ប្រទេសវៀតណាម
- ប្រទេសកម្ពុជា ៥០០ គីឡូម៉ែត្រ
- ប្រទេសថៃ
- ប្រទេសមីយ៉ាន់ម៉ា។

“
មនុស្សកាន់តែរៀន
គឺកាន់តែល្ងង់ខ្លៅ។
”
- សូក្រាត